ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Dec-2016, 11:08
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅជំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៤៦៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន  ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena Ghezzi)*

លោកស្រី សែ កុលវុឌ្ឍី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡេ ជុនធី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា ផេហ្គី ឡឺវ៉ាញ (2-TCE-81) | អង់គ្លេស |
| លោកស្រី ប៉ែន សុចាន់ (2-TCCP-298 ) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ៖ កញ្ញា ផេហ្គី ឡឺវ៉ាញ** (2-TCCP-81)


សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ........................................ ទំព័រ ៣

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........................................ ទំព័រ ២៩

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី........................................ ទំព័រ ៣៨


**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី ប៉ែន សុចាន់** (2-TCCP-298)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................ ទំព័រ ៤៨

សួរដោយលោក ពេជ អង្គ ផ្ដើមពី ........................................ ទំព័រ ៤៩

សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្ដើមពី........................................ ទំព័រ ៧៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មអ្នកជំនាញ ផេហ្គី ឡឺវ៉ាញ បញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-298។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែលោក លីវ សុវណ្ណា មេធាវីជាតិការពារក្តីឱ្យលោក នួន ជា អវត្តមាន ដោយមូលហេតុសុខភាព ហើយលោក ពេជ អង្គ មេធាវីជាតិនាំមុខតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី អវត្តមាននៅវគ្គទី១សវនាការព្រឹកនេះ ដោយមូលហេតុផ្ទាល់ខ្លួន។

ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយអ្នកជំនាញដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោកស្រី ផេហ្គ ឡឺវ៉ាញ។ លោកស្រីមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងមកផ្តល់សក្ខីកម្មបន្ទាប់មានរហស្សនាម 2-TCCP-298។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ លោកស្រី សែ កុលវុឌ្ឍី។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គ

ជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅអ.វ.ត.ក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការឈឺចង្កេះ និងវិលមុខនៅពេលអង្គុយ និងបានផ្តល់អនុសាសន៍ សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់ពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសសួរដេញដោលចំពោះអ្នកសាក្សី -- ចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

[០៩:០៣:៣២]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី ខ្ញុំ -- លោកស្រីអ្នកជំនាញ ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាតំណាង

ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះ ជាមួយលោក ពេជ អង្គ ដែលអវត្តមាន។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរបន្តទៅនឹងអ្វីដែលលោកស្រីឆ្លើយបានជាច្រើនរួចមកហើយ ខ្ញុំនឹងសំណួរមួយចំនួនដោយដកស្រង់ឃ្លាមួយចំនួននៃសៀវភៅរបស់លោកស្រី ឬក៏ដកស្រង់ប្រតិចារឹកដែលយើងបានទទួលកាលពីព្រឹកមិញនេះ។ ហើយខ្ញុំសូមជម្រាបអ្នកបកប្រែថា ខ្ញុំនឹងដកស្រង់ជាភាសាអង់គ្លេសដោយសារតែសៀវភៅរបស់អ្នកជំនាញមិនមានបកប្រែជាភាសាបារាំងទេ។ ហើយប្រសិនបើលោកស្រីមានអារម្មណ៍ថាលោកស្រីឆ្លើយរួចមកហើយ លោកស្រីអាចប្រាប់ខ្ញុំ ខ្ញុំនឹងផ្ដល់ឱកាសឲ្យលោកស្រីបញ្ជាក់បន្ថែមនូវសម្ដីដែលលោកស្រីបានឆ្លើយកាលពីម្សិលមិញនោះ ប្រសិនបើមាន។

ដូច្នេះខ្ញុំសូមចាប់ផ្ដើមនូវសំណួរដំបូង ពាក់ព័ន្ធទៅនឹងប្រធានបទ ទាក់ទងនឹងពាក្យដែលលោកស្រីបាននិយាយកាលពីម្សិលមិញ គឺលោកស្រីនិយាយអំពីការលុបបំបាត់ពិធីបុណ្យ។ កាលពីម្សិលមិញនៅម៉ោង ១១:០៥នាទី ខ្ញុំសូមយោងទៅប្រតិចារឹកជាភាសាអង់គ្លេស ព្រោះថាយើងបានទទួលកាលពីព្រឹកមិញហ្នឹងតែជាភាសាអង់គ្លេសទេ។ ខ្ញុំសូមដកស្រង់នូវរបស់លោកស្រី "ការកំណត់អំពីទីតាំងនៃការរៀបការតាមប្រពៃណីដែលមានផលប៉ះពាល់ទៅលើប្រជាពលរដ្ឋទាំងមូល"។ លោកស្រីអាចជម្រាបបានទេថាតើពិធីបុណ្យតាមប្រពៃណីហ្នឹងត្រូវបានគេលុបបំបាត់យ៉ាងម៉េចខ្លះ សូមលោកស្រីពន្យល់ដោយខ្លីបានទេព្រោះថាខ្ញុំមានពេលវេលាតិចតួចនេះ អ៊ីចឹងខ្ញុំដឹងថាតើការលុបបំបាត់ពិធីបុណ្យផ្សេងៗនេះ វាមានឥទ្ធិពលអ្វីខ្លះ វាជះឥទ្ធិពលអ្វីខ្លះទៅលើប្រជាជននោះ?

**កញ្ញា ផេហ្គី ឡឺវ៉ាញ៖**

**ឆ៖** សូមអរគុណច្រើន។ ទាក់ទងទៅនឹងការសិក្សាស្រាវជ្រាវ<របស់ខ្ញុំ>អំពី<ពិធីបុណ្យតាម>ប្រពៃណី <គឺថា>កាលពីថ្ងៃទី១ ខ្ញុំបានពិនិត្យមើល<យ៉ាងផ្ចិតផ្ចង់>អត្ថបទចាស់ៗដែលខ្ញុំបានសម្ភាសប្រជាជន<នៅមុន>ឆ្នាំ១៩៧០។ <ដូច្នេះ គឺខ្ញុំច្បាស់ណាស់អំពីរឿងទាំងអស់នេះ គឺថាមិនមែនត្រឹម>តែអំពី<ពិធីបុណ្យតាមប្រពៃណី>នោះទេ <ប៉ុន្តែក៏ដឹងច្បាស់អំពីលំដាប់លំដោយពិធីបុណ្យតាមប្រពៃណីដែលគេធ្វើឡើង> ហើយថាតើ<ពិធីបុណ្យតាមប្រពៃណី>អ្វីខ្លះត្រូវបានបោះបង់ចោល <កម្មវិធីបុណ្យតាមប្រពៃណីអ្វីខ្លះត្រូវបានបោះបង់ចោល អ្វីដែលត្រូវបានបន្ថែមចូល និងអ្វីដែលមានសក្ដានុពលភាព។ គឺថាមានសក្ដានុពលភាពមួយនៅក្នុងពិធីបុណ្យតាមប្រពៃណី ដោយសារតែមាន>ការផ្លាស់ប្ដូរ<មួយជាញឹកញាប់ រវាង>ប្រជាជន<នៅក្នុងអំឡុងពេលដំណើរការពិធីបុណ្យតាមប្រពៃណីនោះ>។ អ៊ីចឹងខ្ញុំមើលទំនៀមទម្លាប់ប្រពៃណីរៀបការ <គឺខ្ញុំបានមើលទៅលើពិធីភ្ជាប់ពាក្យ គឺថាវាមានសារៈសំខាន់ណាស់

ពីព្រោះវាគឺជាតំណភ្ជាប់មួយដ៏សំខាន់សម្រាប់ការរៀបការ។> ខ្ញុំក៏មើលអំពី<តំណភ្ជាប់នៃពិធីបុណ្យតាម>ប្រពៃណីពាក់ព័ន្ធពេលដែលស្ត្រីមានផ្ទៃពោះ រហូតដល់ពេលស្ត្រីឆ្លងទន្លេ និងក្រោយពេលឆ្លងទន្លេរួច។ ការធ្វើបែបនេះ វាធ្វើឱ្យខ្ញុំពិនិត្យមើល<បានច្រើន>អំពី<ការបែកខ្ញែកនៃពិធីបុណ្យតាម>ប្រពៃណី<បន្ទាប់មកគឺការបែកខ្ញែកនៃ>វប្បធម៌ <ពីព្រោះវប្បធម៌គឺជារបស់ពុំមានទ្រង់ទ្រាយដែលត្រូវសិក្សាឱ្យបានច្រើន។> ហើយអ្វីដែលខ្ញុំបានរកឃើញនោះគឺលំដាប់លំដោយក៏នៃការរៀបការរវាងបុរសនិងស្ត្រី<។ គឺសូម្បីតែនៅក្នុងអំឡុងពេលផ្តល់កំណើត> គឺថាបុរសមានតួនាទី<មួយក្នុងការរកដីដែលមានជីជាតិដើម្បីកប់សុក។> អ៊ីចឹងវាមានសារៈសំខាន់ណាស់ដែលខ្ញុំត្រូវ<មានការប្រុងប្រយ័ត្ន ពាក់ព័ន្ធទៅនឹងអ្វីខ្លះដែលជាតួនាទី ហើយអ្វីខ្លះដែលជាតួនាទីទៅវិញទៅមក។> ហើយអ្វីដែលខ្ញុំបានរកឃើញៗគឺមានការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងរចនាសម្ព័ន្ធនៃ<ពិធីបុណ្យតាម>ប្រពៃណី <និងក្នុងដំណើរការ>ដែលប្រជាជន<ត្រូវតែប្រតិបត្តិពិធីបុណ្យតាមប្រពៃណីជាផ្លូវការនោះ។ មនុស្សភាគច្រើនស្វះស្វែងធ្វើពិធីបុណ្យតាមប្រពៃណីដោយសម្ងាត់> ហើយជួនកាល<ធ្វើឡើង>ដោយ<សារតែមានអារម្មណ៍>ភ័យខ្លាច។ ហើយចំណែកការមិនធ្វើពិធីបុណ្យតាមប្រពៃណី សម្រាប់ការពារខ្លួន វាគឺជារឿងដែលខ្ញុំចាប់អារម្មណ៍ ថាតើអ្វីជាពិសេសនៃអារម្មណ៍ ឬក៏ប្រភេទនៃការព្រួយបារម្ភ ដែលប្រជាជនគាត់មានបទពិសោធន៍ ដោយមិនមានការធ្វើនូវប្រភេទនៃ>ការការពារ<បែបនេះ ដែលវាត្រូវបានចាក់ឫស>វាប់សតវត្សរ៍នៅក្នុងប្រទេសកម្ពុជានេះ។ ហើយខ្ញុំក៏មើលឃើញ ក៏ពិនិត្យមើលទៅលើភាពខុសគ្នារវាង<ពិធីបុណ្យតាមប្រពៃណី>ដែលមាននៅតាមទីជនបទនិងទីប្រជុំជន។ ដូច្នេះ ខ្ញុំអាចចាត់<ថ្នាក់>លំដាប់លំដោយ<នៃសារៈសំខាន់របស់ពិធីបុណ្យតាមប្រពៃណី>។

[០៩:០៩:១៣]

នៅពេលដែលប្រជាជនដែលរស់នៅជនបទ<> ហើយក្រោយមកគាត់មកនៅទីប្រជុំជន ថាតើគាត់បានទទួលអ្វីខ្លះ<។ ហើយដូចគ្នានេះផងដែរ គឺនៅពេលដែលពួកគេត្រូវបាន>ផ្លាស់ប្តូរពីភូមិភាគមួយទៅភូមិភាគមួយ ដែលមិនស្គាល់អំពីទីតាំងភូមិសាស្ត្រ <និងភូមិ>សាស្ត្រ ហើយ<ភាពខុសគ្នាខ្លះនៅ>ក្នុងការប្រតិបត្តិជាក់ស្តែង តើវា<មានន័យ>យ៉ាងដូចម្តេចដែរ<សម្រាប់ពួកគេ>? ហើយខ្ញុំបានរកឃើញយ៉ាងច្រើននៅក្នុងការសិក្សាស្រាវជ្រាវរបស់ខ្ញុំនេះ ហើយខ្ញុំរកឃើញថា អ្នកឆ្លើយនេះគឺថា មានការមិនពេញចិត្តយ៉ាងខ្លាំងនៅពេលដែលយើងនិយាយអំពីការរៀបការ ឬក៏ការផ្តល់កំណើត។ តើទំនៀមទំលាប់អ្វីខ្លះដែលគាត់មិនបានទទួល ឬក៏ទំនៀមទំលាប់អ្វីខ្លះដែល<ពួកគេលបលួចស្វែងរក ឬក៏>ក្រុម

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

គ្រួសារហ្នឹងព្យាយាមលបលួច លបលាក់ ដើម្បីគោរពតាមទំនៀមទំលាប់នេះ។

**សៈ** សូមអរគុណ។ លោកស្រីបានប្រៀបធៀបទៅនឹង នៅក្នុងសៀវភៅរបស់លោកស្រី ហើយលោកស្រីក៏បាននិយាយនៅក្នុងសវនាការនេះផងដែរ រវាងការបាត់បង់នូវពិធីសែនព្រេនផ្សេងៗ ហើយនិងកង្វះនូវការគាំពារ ហើយនៅក្នុងសៀវភៅរបស់លោកស្រី លោកស្រីយកពាក្យភ័យខ្លាចយកមកប្រើ ហើយលោកស្រីបានបញ្ជាក់ថា តើភាពភ័យខ្លាចនេះវាជាផលវិបាកនៃការបាត់បង់នូវការការពារយ៉ាងម៉េចខ្លះ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកស្រីពន្យល់ជូនតុលាការនូវទស្សនទានមួយនេះ ថាតើវាជាទស្សនទានពិតប្រាកដ ឬក៏វាជារោគសញ្ញាអ្វីមួយ ហើយលោកស្រីមានបានកត់សម្គាល់ឃើញទេ នៅពេលដែលលោកស្រីសម្ភាសជាមួយនឹងអ្នកដែលផ្ដល់ចម្លើយហ្នឹង ហើយជាពិសេសពេលដែលលោកស្រីពិគ្រោះជំងឺនោះ? យើងដឹងថា លោកស្រីធ្លាប់ផ្ដល់ការពិគ្រោះជំងឺទៅលើអ្នកជំងឺមួយចំនួននៅអាមេរិក ក៏ដូចជានៅគ្លីនិកនៅតាខ្មៅជាដើមនោះ។ អ៊ីចឹងលោកស្រីអាចពន្យល់ពាក្យថា ពាក្យ “ភ័យខ្លាច” នេះ តើវាជាអារម្មណ៍ ជារោគសញ្ញាយ៉ាងម៉េចខ្លះ? ហើយវាមានផលប៉ះពាល់អ្វីខ្លះទៅលើប្រជាជនជាទូទៅនោះ?

**ឆៈ** ជាយុទ្ធសាស្ត្រ ខ្ញុំ<បានជ្រើសរើស>យកពាក្យ <“ភ័យខ្លាច>” សម្រាប់ដាក់ជាចំណងជើងសៀវភៅរបស់ខ្ញុំ ដោយសារថា <ខ្ញុំគិតថា> ពាក្យនេះវា<មានន័យច្រើន ក្នុង>រៀបរាប់អំពីបទពិសោធន៍ដែលប្រជាជនបាននិយាយ<>ច្រើន <ជា>ជាង<ពាក្យវេជ្ជសាស្ត្រមួយគឺ “ការថប់អារម្មណ៍” ឬ “>ជំងឺបាក់ស្បាត<” ហើយជាភាសាបារាំង គឺ “អាំប៉ាហ្វេ”។ វាបានវិវត្តតាមពេលវេលា>។ ពាក្យខ្មែរគឺមិនដឹងថាវារៀបរាប់បានចំល្អឬយ៉ាងណាទេ ប៉ុន្តែពាក្យថា “<ភ័យខ្លាច>” នេះ គឺជាពាក្យមួយយើងគិតថា ដូចជាពាក្យមួយដែលតាមលងប្រជាជនអ៊ីចឹង។ <គ្រប់គ្នា>ដែលខ្ញុំ<បាន>និយាយ<ទៅកាន់គាត់ គឺ>គាត់បានឃើញសាកសព <គឺពួកគេមិនបាននិយាយថា ពួកគេបានឃើញ>មនុស្ស<ដែលត្រូវគេសម្លាប់នោះទេ ប៉ុន្តែពួកគេបានឃើញសាកសព>។ បើទោះបី វាជាការអោប>ឪពុក<ដែល>ស្លាប់ដោយសារភាពអត់ឃ្លាន<ក៏ដោយ ឬក៏ការដើរតាមផ្លូវ ហើយបាន>ឃើញសាកសពអណ្ដែតទឹក<គឺប្រជាជននិយាយថា បានឃើញសាកសពមនុស្សស្លាប់។ ហើយនៅពេលដែលពួកគេឃើញសាកសពមនុស្សស្លាប់ទាំងអស់នោះ> គឺជាបទពិសោធន៍គួរឲ្យភ័យខ្លាចរន្ធត់មែនទែន <ប៉ុន្តែសម្រាប់អ្នកដែលមិន>ទទួលបាននូវការការពារ <និងមិនដឹង>ថាអ្នកដែលស្លាប់ទៅនោះ អ្នកដែលស្លាប់ទៅដោយសារតែអំពើហិង្សាបែបនេះ តើវាមានអ្វីកើតឡើងទៅដល់ព្រលឹងអ្នកដែលស្លាប់នោះដែរ? <ការព្រួយបារម្ភនេះគឺវាធំធេងណាស់។> អ៊ីចឹង<រាល់អ្នកដែលខ្ញុំបាននិយាយជាមួយ សម្រាប់ការសិក្សាស្រាវជ្រាវរបស់ខ្ញុំ

រួមទាំង>អ្នកដែលខ្ញុំបានសម្ភាសជាមួយ <ដែលមិនមែនស្ថិតនៅក្នុងមនុស្សផ្លូវការ គឺធ្វើដូច្នេះ> ធ្វើឲ្យខ្ញុំអាចកំណត់បាន<រូបភាព>ជំនឿទំនៀមទម្លាប់ប្រពៃណីនេះ <ដែលជាគោលបំណងនៅក្នុងកិច្ចសម្ភាសន៍ទាំងនោះ ដែលពួកគេបាននិយាយអំពីប្រភេទលក្ខណៈនៃ>ការភ័យខ្លាច <ដែលមានប្រចាំថ្ងៃ>។

[០៩:១៤:១៥]

**ស៖** សូមអរគុណ។ នៅទំព័រទី៥ នៃសៀវភៅរបស់លោកស្រី លោកស្រីបាននិយាយអំពីទំនាក់ទំនងគ្រួសារត្រូវបានកែប្រែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមអានជាភាសាអង់គ្លេសនៅឃ្លាដ៏ខ្លីមួយ៖ "ជំនឿទុកចិត្តទៅលើគ្រួសារ មិត្តភក្តិ និងអ្នកជិតខាង គឺថាវាក្លាយទៅជាលក្ខខណ្ឌមួយទៅហើយ ហើយប្រជាជនជាច្រើនមានការយល់ច្រឡំរវាងភាពស្មោះត្រង់ និងភាពមិនស្មោះត្រង់នៅពេលណាមានការបាក់បែកគ្នា ឬបំបែកចេញពីគ្រួសារ។"

លោកស្រីអាចជម្រាបជូនតុលាការបានទេ ថាតើទំនាក់ទំនងគ្រួសារនេះ ត្រូវបានបំផ្លិចបំផ្លាញយ៉ាងដូចម្តេចខ្លះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? ហើយតើនៅពេលដែលមានការផ្លាស់ប្តូរទំនាក់ទំនងនៃសេចក្តីទុកចិត្តបែបនេះ តើវាមានផលប៉ះពាល់យ៉ាងម៉េចខ្លះទៅលើសំណាក់គំរូ ដែលលោកស្រីបានសម្ភាស ហើយនិងទៅលើប្រជាជនជាលក្ខណៈទូទៅនោះ?

**ឆ៖** បញ្ហានៃជំនឿទុកចិត្តនេះ គឺថាមានភាពស្មុគស្មាញ។ ការមន្ទិលសង្ស័យ គឺវាជារឿងមួយដែលចាំបាច់ណាស់ដើម្បីរស់រានមានជីវិតទៅបាន។ ឧទាហរណ៍ ខ្ញុំសូមពន្យល់អំពីភាពស្មុគស្មាញ<ពីព្រោះវាមិនជារឿងសាមញ្ញនោះទេ ដែល">ខ្ញុំមិនទុកចិត្តអ្នកជិតខាងខ្ញុំទេ <ពួក>គាត់អាច<ប្រឆាំងនឹងខ្ញុំ"។ នេះគឺជាពាក្យវាក្យសព្ទរបស់អូស្ត្រាលី គឺពួកគេអាចដាក់ឈ្មោះរបស់ខ្ញុំដើម្បីរិះគន់>។ ខ្ញុំសូមលើកឡើងអំពីស្ត្រីក្មេងពីរនាក់ គឺបងប្អូនស្រីពីរនាក់ បានដើរចេញពីភ្នំពេញ<ជាមួយគ្នា។ ម្នាក់ចាស់ម្នាក់ទៀតក្មេង>។ ស្ត្រីម្នាក់គឺថា គាត់ឆ្លាតវាងវៃ គាត់<យល់ដឹង វាអាចមានសារៈសំខាន់ក្នុងការបង្កើត>រឿងរ៉ាវ<ជីវិតពីអតីតកាលរបស់ពួកគេ ដោយសារតែពេលឥឡូវនេះពួកគេបានកំពុងដើរ>ចេញ<>ពីភ្នំពេញ<។ ដូច្នេះប៉ុន្មានថ្ងៃមក បងស្រីបាននិយាយរឿងរ៉ាវមួយនៃជីវិតអតីតកាលរបស់ពួកគេ >ហើយឲ្យប្អូនស្រីរបស់គាត់នោះ គឺថាសមរៀបរាប់រឿងហ្នឹង ឲ្យម្តងហើយម្តងទៀតៗ ឲ្យចាំបានល្អ។ហើយ<ខ្ញុំគិតថាពួកគេធ្វើបានល្អ ពីព្រោះពួកគេបានដឹងរឿងនេះដោយឆ្លងកាត់នៅក្នុងរបបនោះ។> ប៉ុន្តែបងស្រីនោះ គាត់មានការ<ភ័យខ្លាច> មិនទុកចិត្ត<បន្តិចបន្តួច> មិនមែនមិនទុកចិត្ត រឿងមិនទុកចិត្តប្អូនស្រីទេ។ គាត់មិនទុកចិត្តថា ខ្លាចប្អូននឹងរៀបរាប់ដំណើររឿងដែលគាត់រៀបចំនេះ គឺថាវាៗ

មិនបានចាំបានល្អ។

[០៩:១៧:២៩]

ហើយដូច្នេះ <ខ្ញុំគិតថា វាគឺជាការចង្អុលបង្ហាញមួយ ថាតើការយល់ឃើញនៃការសង្ស័យនេះវាមានលក្ខណៈពិបាករបៀបណានៅក្នុងរបបនោះ ហើយ>ប្រជាជនហ្នឹងគឺមានកត់សម្គាល់គ្នាខ្លាំងៗ។ <យ៉ាងហោចណាស់> អ្នកដែលខ្ញុំបាននិយាយជាមួយហ្នឹង គឺមាន<បញ្ញាញាណខ្ពស់ក្នុងការត្រៀមខ្លួនជាស្រេចដើម្បីធ្វើអ្វីមួយ ដែលអាចនឹងកើតឡើង> ដូចជា<ជំហាន>ជើងរបស់មនុស្សដែលដើរសំដៅទៅរកអ្នកណាម្នាក់អ៊ីចឹង <បើសិនជាជំហាននោះផ្លាស់ប្តូរ។ ប្រជាជនប្រាកដជាចាប់ផ្តើមយល់ គឺនៅពេលដែលជំហាន>ដានជើងនេះ វាមានអាចមានន័យ<ថា ពួកគេនឹងត្រូវបញ្ជូនទៅធ្វើការធ្ងន់ ដោយអ្នកដែលដើរមករកពួកគេ ដោយអាស្រ័យទៅលើជំហានដើរនោះ។ ដូច្នេះ អ្វីគ្រប់យ៉ាង គឺវាមានទម្ងន់ខ្ពស់ណាស់ ហើយខ្ញុំគិតថា វាគឺជាទិដ្ឋភាពមួយដ៏សំខាន់>។

**សៈ** <>ការសង្ស័យ ដូចដែលលោកស្រីបានរៀបរាប់នេះ <តើយើងអាចរក>វា<ឃើញ>នៅក្នុងរឿងរ៉ាវរបស់អ្នកដែលលោកស្រីបានសម្ភាសនោះ<ទេ ឬក៏>តើលោកស្រីអាចរៀបរាប់ជាលក្ខណៈទូទៅបានទេ ថាតើបរិយាកាសនៃការសង្ស័យនេះ វាមានជាទូទៅទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆៈ** <ខ្ញុំអាចនិយាយថា> វាមានការកើនឡើងយ៉ាងខ្លាំង។ <ប៉ុន្តែ>ខ្ញុំក៏សូមបន្ថែមផងដែរ <អំពីទិដ្ឋភាពផ្សេងដែល>បានបង្ហាញ<ដោយ>មេធាវីការពារក្តីបង្ហាញមិត្តរួមមិញ គឺវាជាទស្សនៈ<របស់>អង្គការ ដែលកន្លែងហ្នឹងគឺធ្វើឲ្យមានការភ័យខ្លាច ហើយនិង<>មន្ទិលសង្ស័យ។

**សៈ** ខ្ញុំនឹងត្រឡប់មកនិយាយអំពីអង្គការនេះ នៅពេលបន្តិចទៀត។ ប៉ុន្តែឥឡូវនេះ ខ្ញុំចង់និយាយអំពីផលវិបាកនៃការបាត់បង់ពិធីសែនព្រេនផ្សេងៗ ទៅលើការរៀបអាពាហ៍ពិពាហ៍។ លោកស្រីបាននិយាយនៅក្នុងសៀវភៅរបស់លោកស្រីនៅក្នុងទំព័រទី៣១ ខ្ញុំសូមនិយាយជាភាសាអង់គ្លេស។

[០៩:១៩:៣៣]

(ការអានជាភាសាអង់គ្លេស៖) "ចំណុចដែលខ្ញុំរកឃើញនៃការលុបបំបាត់ទំនៀមទម្លាប់ប្រពៃណី គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ហើយខ្ញុំសូមបញ្ជាក់ថា ការលុបបំបាត់ទំនៀមទម្លាប់ប្រពៃណីនេះ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងវប្បធម៌ហើយ។"

លោកស្រីអាចពន្យល់ឲ្យបានលម្អិតបន្តិចបានទេ មានន័យថាម៉េច ពាក្យថា "ឧក្រិដ្ឋកម្មប្រឆាំង

នឹងវប្បធម៌" នេះ? ហើយតើឧក្រិដ្ឋកម្មប្រឆាំងនឹងវប្បធម៌ នេះមានផលប៉ះពាលអ្វីខ្លះទៅលើបុរសនិងស្ត្រី ដែលបានរស់នៅនិងរៀបអាពាហ៍ពិពាហ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ដោយសារទំនៀមទម្លាប់ជាមូលដ្ឋានមួយដ៏ចម្បងសម្រាប់វប្បធម៌ <ហើយជាភាគល្អិតៗ របស់វប្បធម៌ ក៏ដូចជាវប្បធម៌បែបម៉ាក្រូ។ ប៉ុន្តែ>ខ្ញុំមើលទៅលើវប្បធម៌បែបម៉ាក្រូនៅទីនេះ <ការបែកខ្ញែក>មូលដ្ឋាននៃទំនៀមទម្លាប់ប្រពៃណី <និង>អំពីលទ្ធភាពក្នុងការទទួលបាន<វានៅក្នុង>ដំណាក់កាល<វិវត្តន៍ពិសេសមួយរបស់ជីវិតមនុស្សម្នាក់។ វាគឺរឿងសំខាន់ណាស់>។ ហើយខ្ញុំយល់ថាហ្នឹងជាឧក្រិដ្ឋកម្មប្រឆាំងនឹងវប្បធម៌ហើយ។ ខ្ញុំដូចភ្លេចផ្នែក<មួយផ្សេងទៀត>នៃសំណួររបស់លោកស្រី។

**ស៖** ខ្ញុំចង់ដឹងថាតើ "ឧក្រិដ្ឋកម្មប្រឆាំងនឹងវប្បធម៌" នេះមានផលប៉ះពាល់អ្វីខ្លះទៅលើបុរសស្ត្រី ដែលបានរៀបអាពាហ៍ពិពាហ៍នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

[០៩:២១:៣៤]

**ឆ៖** ចាស ខ្ញុំ<នឹង>ពន្យល់<បន្តិចទៀតចំពោះ>ចម្លើយរបស់ខ្ញុំនេះ ដោយសារថាវាសំខាន់ណាស់សម្រាប់ខ្ញុំ<ត្រឡប់>ទៅនិយាយអំពី<ការភ្ជាប់ពាក្យ។ ខ្មែរក្រហម បានបង្កើតលក្ខណៈពិសេសនៃការចងចាំការភ្ជាប់ពាក្យ សម្រាប់ប្រជាជន ដែលវាគឺជាពេលវេលាដ៏ខ្លី។> តាមបែបប្រពៃណី <ការភ្ជាប់ពាក្យគឺមាន>ជាយូរយាណាស់មកហើយ <>ការរៀបការឲ្យគូស្រករហ្នឹង<គឺអាចនឹងត្រូវបានផ្គូផ្គង ហើយនៅពេលដែលការរៀបការត្រូវបានគេ>ផ្គូផ្គងគ្នានេះ រៀបចំនេះ គឺអាចមានរយៈពេលមួយឆ្នាំឯណោះដែលគូដណ្តឹងហ្នឹងគឺថាអាច<>នៅជិតគ្នា <ចំណាយពេលច្រើននៅជាមួយគ្នា> ហើយសហគមន៍ទទួលស្គាល់ អ្នកស្រុក អ្នកភូមិទទួលស្គាល់។ ដូច្នេះមូលហេតុនៃការទទួលដើម្បីឲ្យអ្នកដទៃទទួលស្គាល់ ដែលទាក់ទងទៅនឹងទំនាក់ទំនងទៅថ្ងៃមុខ ហើយក៏ជាពេលមួយដែលឪពុកម្តាយទាំងសងខាងហ្នឹង គឺយកពេលវេលានេះ ដើម្បីវាយតម្លៃអ្នកទាំងពីរផងដែរ កត់សម្គាល់ គឺទាំងឪពុកម្តាយខាងស្រីខាងប្រុស ក៏ដូចជាសមាជិកនៅភូមិស្រុកនោះ នៅសហគមន៍នោះធ្វើការវាយតម្លៃដែរ។ អ៊ីចឹង <ខ្ញុំគិតថាវាជាការសំខាន់ណាស់ ដែលការភ្ជាប់ពាក្យ> និងការរៀបការនេះគឺមិនមែនសំដៅតែទៅលើការពង្រីកនូវសមាជិកគ្រួសារតែប៉ុណ្ណោះទេ។

ម្សិលមិញ ខ្ញុំត្រូវបានសួរសំណួរ<មួយ ដែលខ្ញុំបានសួរនៅក្នុងការសិក្សាស្រាវជ្រាវរបស់ខ្ញុំ ថាតើការរៀបការហ្នឹងពិតដែរទេ>។ ប្រហែល<នេះគឺជាពេលវេលា ដែល>ខ្ញុំត្រូវបង្ហាញនូវចម្លើយរបស់ខ្ញុំទៅនឹងសំណួរ<>នោះ ហើយ<ខ្ញុំរីករាយនឹងធ្វើដូច្នេះ ពីព្រោះវាបាននាំឲ្យត្រឡប់ទៅកាន់កំណត់ត្រា

01365388



ការងារសិក្សាស្រាវជ្រាវរបស់ខ្ញុំ។ អ៊ីចឹង>សំណួរនេះសួរឡើងដោយសហព្រះរាជអាជ្ញា<> គឺថា តើពាក្យហ្នឹង ពាក្យ “*រៀល*” – ពាក្យ “ពិតប្រាកដ<” មានន័យយ៉ាងដូចម្ដេច។> តុលាការអាចថតចម្លងឯកសាររបស់ខ្ញុំ <ខ្ញុំមានជាភាសាខ្មែរ។ ហើយខ្ញុំ>មានពាក្យចំនួនបីដែលយោងទៅលើពាក្យថា “*រៀល*” នេះ – គឺ “ពិតប្រាកដ<”>។ “ពិតប្រាកដ” មានន័យថាមិនក្លែងក្លាយ មានន័យថាត្រូវបានគេទទួលស្គាល់ មានន័យថាផ្លូវការ។ ដូច្នេះសំណួរ<នេះបានផ្ដល់នូវកញ្ចក់ ដែល>អនុញ្ញាតឲ្យខ្ញុំ<ចាប់យកទិដ្ឋភាពវប្បធម៌>នៅក្នុងការរៀបការ ហើយ<វាក៏បានធ្វើឲ្យខ្ញុំយល់ដឹងផ្សេងទៀតអំពីការបកស្រាយរបស់ប្រជាជន ឬក៏>ថាតើពួកគាត់ហ្នឹងបកស្រាយការរៀបការហ្នឹង វាជាការរៀបការពិត<>ដោយរបៀបណា។ <អ្វីដែលខ្ញុំចង់ធ្វើនោះ គឺយល់ដឹងអំពីរឿងនេះ។>

[០៩:២៤:៥៦]

<អ៊ីចឹងខ្ញុំគិតពិចារណាទៅលើកិច្ចសម្ភាសន៍មួយ> នៅពេលដែលខ្ញុំពិនិត្យមើលទៅលើការសិក្សាស្រាវជ្រាវរបស់ខ្ញុំកាលពីយប់មិញនេះ <ហើយខ្ញុំក៏មានវាមួយច្បាប់នៅទីនេះដែរ> គឺខ្ញុំចង់និយាយថា ការរៀបការមិនមែនគ្រាន់តែ<>ជាការពង្រីកសមាជិកគ្រួសារនោះទេ។ <ខ្ញុំសូមដកស្រង់៖ “ការរៀបការ គឺត្រូវបានទទួលស្គាល់> ដោយសារថាប្រធានភូមិ ប្រធានឃុំ <ឪពុកម្ដាយ> បងប្អូន ប្រុសស្រី មីងពូ បានទទួលស្គាល់អ្នកទាំងពីរថាជាគូស្រករ ទោះបីមិនបានទៅចូលរួមក្នុងពិធីការនោះ ការរៀបការនោះក៏ដោយ។ <ដូច្នេះគូស្រករជាផ្លូវការ យើងអាចរួមរស់នៅជាមួយគ្នាបាន”។> ហើយ<ខ្ញុំដឹងថា> នៅក្នុងសម្រង់នេះគឺថាវាមានអត្ថន័យច្រើនណាស់ <ប៉ុន្តែមូលហេតុដែលខ្ញុំដកស្រង់>សម្រង់នេះគឺថាវាសំខាន់ណាស់សម្រាប់ខ្ញុំ។ ខ្ញុំសូម<ចាកចេញពីប្រធានបទនេះ>បន្តិច <សំណួរទី១ដែលសួរមកខ្ញុំ គឺ> ថាតើការរៀបការហ្នឹងពិត ឬ<? ហើយបុគ្គលនោះបាននិយាយថា វាគឺ>ជាការរៀបការផ្លូវការ<។ ហើយសំណួរខ្ញុំបន្ទាប់មកទៀត គឺ “សូមប្រាប់ខ្ញុំអំពីចម្លើយរបស់អ្នក?”>។ អ៊ីចឹងខ្ញុំ<គ្រាន់តែចង់ឲ្យលោកដឹងថា តើខ្ញុំអាចសុំការឆ្លើយតបអំពីចម្លើយដែលខ្ញុំទើបតែផ្ដល់ឲ្យ>ដោយរបៀបណានោះ។ ដូច្នេះនៅពេលដែលយើង<មើលទៅលើទំនៀមទម្លាប់ប្រពៃណី និងការបែកខ្ញែក>ទំនៀមទម្លាប់ប្រពៃណីនេះ គឺវាមានសារៈសំខាន់ណាស់សម្រាប់ខ្ញុំ ក្នុងការ<បង្កើតនូវវង្សក្រោម>សង្គម<មួយ> ថាតើទំនៀមទំលាប់<ប្រពៃណីណាដែលបានធ្វើឡើង និងមិនបានធ្វើឡើង>នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ<។ វាមានន័យថា ខ្ញុំត្រូវតែបញ្ចូលនូវតួអង្គនៅក្នុងនោះ។ ពេលនេះ អ្វីដែលបានកើតឡើង គឺតួអង្គ>ខ្លះហ្នឹងគឺ<ត្រូវបាន>ផ្លាស់ប្ដូរគ្នា<ជាមួយតួអង្គផ្សេងទៀត ដែលបានស្ថិតនៅក្នុងកន្លែងជាទម្លាប់ប្រពៃណីស្រាប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

។ សំណួរសម្រាប់ខ្ញុំ ដែលជា>អ្នកសិក្សាស្រាវជ្រាវ<ម្នាក់> គឺថាតើ<>ការផ្លាស់ប្តូរ<បុគ្គល>នៅក្នុង<>តួនាទី<ណាមួយជាក់លាក់ នាំឲ្យអ្នកណាម្នាក់ជឿជាក់អំពី>ការរៀបការ <ដែលពួកគេមានដែរឬទេ>។ អ៊ីចឹង<ម្តងទៀត គឺថា>ទំនៀមទំលាប់ប្រពៃណីមិនមែនពាក់ព័ន្ធតែមនុស្សម្នាក់ទេ គឺវាពាក់ព័ន្ធទៅនឹងបរិបទទាំងមូលតែម្តង។

[០៩:២៧:២០]

**ស៖** សូមអរគុណ។ ខ្ញុំនឹងចូលទៅនិយាយអំពីតួនាទីរបស់អង្គការនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដូចដែលលោកស្រីបានលើកឡើងការពីម្សិលមិញ។ លោកស្រីបាននិយាយអំពីភាពអស្ចារ្យរបស់អង្គការនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ម៉ោង ១១:០៦នាទី កាលពីម្សិលមិញ លោកស្រីបាននិយាយថា អ្នកខ្លះបានចាត់ទុកអង្គការហ្នឹងថាមានអំណាចខ្ពស់ ហើយមើលមិនឃើញទេអង្គការ គឺជាដូចជាអរូបិយអ៊ីចឹង។ <ខ្ញុំនឹងដកស្រង់ជាភាសាអង់គ្លេស៖> "ដូច្នេះ នៅពេលអ្នកណាម្នាក់<ត្រូវបានគេប្រាប់ថា> អង្គការបានស្នើសុំឲ្យ<គេ>រៀបការ គឺថាអ្នកនោះ<>ត្រូវតែយល់ព្រមតាមការស្នើរបស់អង្គការ។" នៅក្នុងសៀវភៅរបស់លោកស្រី លោកស្រីបាននិយាយយ៉ាងវែងអំពីអង្គការ ហើយលោកស្រីបានប្រើពាក្យជាភាសាអង់គ្លេសនៅទំព័រទី១៣ ការមិនទុកជា ការភ័យខ្លាច ការមន្ទិលសង្ស័យ ហើយនិងការប្រុងប្រយ័ត្នខ្ពស់។

តើលោកស្រីអាចរៀបរាប់លម្អិតបន្តិចបានទេ <តើលោកស្រីចង់បានន័យថាម៉េច?> លោកស្រីមើលរកឃើញទេអម្បាញ់មិញនេះខ្ញុំដកស្រង់ទំព័រទី១៣ នៅសៀវភៅរបស់លោកស្រី។ ជាទូទៅខ្ញុំបានរកឃើញថាការមិនទុកចិត្តគ្នា ការភ័យខ្លាច ហើយនិងការប្រុងប្រយ័ត្នខ្ពស់បំផុត គឺនៅពាក់ព័ន្ធទៅនឹងបទពិសោធន៍របស់អ្នកខ្ញុំសម្ភាសទៅនឹងអង្គការដែលជាកម្លាំងមួយថា អាចជាកម្លាំងមួយកម្លាំងបំផ្លិចបំផ្លាញមួយ ដែលអាចកើតឡើងពេលណាក៏បាន។

លោកស្រីបានបន្ថែមទៀតថា អង្គការគឺជាអំណាចដ៏ធំធេងមួយដែលប្រជាជន<ភ័យខ្លាចក្នុងការ>គិត <ខ្លាច>អង្គការនេះអាចដឹងថាពួកគាត់កំពុងតែគិតស្អីនៅក្នុងខួរក្បាលរបស់ពួកគាត់។ កាលពីម្សិលមិញលោកស្រីបាននិយាយរួចមកហើយ អ៊ីចឹងថ្ងៃនេះខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ឲ្យបានច្បាស់បន្តិចថាតើអង្គការនេះមានតួនាទីយ៉ាងម៉េចខ្លះ? ជាពិសេសហ្នឹងតើមនុស្សដែលលោកស្រីបានសម្ភាសហ្នឹងហើយនិងជាប្រជាជនជាលក្ខណ:ទូទៅហ្នឹង គាត់យល់ឃើញយ៉ាងម៉េចចំពោះតួនាទីរបស់អង្គការនៅក្នុងការរៀបអាពាហ៍ពិពាហ៍នោះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំឮសួរសំណួរពីរគឺតួនាទីរបស់ការ<អង្គការ> និងតួនាទីរបស់អង្គការនៅក្នុងការរៀបការ<របស់ប្រជាជន>។ តើលោកស្រីចង់ឲ្យខ្ញុំឆ្លើយទៅនឹងសំណួរទាំងពីរ?

[០៩:៣០:៣១]

**សៈ** ឥឡូវយើងចាប់ផ្តើមពីតួនាទីរបស់អង្គការនៅក្នុងការរៀបអាពាហ៍ពិពាហ៍។

**ឆ៖** នៅពេលដែលខ្ញុំធ្វើការសម្ភាស ពាក្យ "អង្គការ" ហ្នឹងគឺថាបានលេចឡើងមកជាញឹកញាប់ ដែលខ្ញុំមិនមែន<ចង់>គ្រាន់តែ<កំណត់ថាជាអង្គការសម្រាប់ពាក្យនេះទេ>។ ខ្ញុំក៏ចង់ដឹងថា អង្គការហ្នឹងជាអ្វី។ ហើយខ្ញុំ<ព្យាយាម>គិតអំពីរូបភាព <ថាតើ>អង្គការហ្នឹង<មានរូបរាងយ៉ាងម៉េចនៅក្នុងចិត្តរបស់ប្រជាជន ពីព្រោះ>អង្គការជាតំណាងឲ្យអំណាចណាមួយ ដែលគ្រប់គ្រង<រឿងច្រើន>ដែលកំពុងតែកើតមានឡើង។ ដូចខ្ញុំបានជ្រាបពីម្សិលមិញ មិនមានទីបញ្ជាការណាមួយដែលប្រជាជនអាចចូលទៅដល់ទីបញ្ជាការរបស់អង្គការបានទេ មិនមានទីស្នាក់ការធំ។ <ពួកគេមានការពិបាកក្នុងការកំណត់ថា>តើរឿងអ្វីៗទាំងអស់វាកើតឡើងដោយរបៀបណា? ហើយនៅពេលដែលគេប្រើពាក្យថា "អង្គការ"នេះ គឺថារឿងរ៉ាវ<>កើតកាន់តែច្រើន ដែលជាប់ពាក់ព័ន្ធទៅនឹងអង្គការ ទៅនឹងច្បាប់ទម្លាប់របស់អង្គការ។ ប្រជាជនជាច្រើនៗ <ចាប់ផ្តើមឃើញរូបរាងមិនច្បាស់លាស់ គឺខ្ញុំសូមកំណត់ឲ្យបានច្បាស់ថា គឺវាពុំមានភេទ>ទេ គឺថាវាហាក់បីដូចជា<ការទាក់ទងគ្នាទៅវិញទៅមក នៅមុនពេលដែលមានទស្សនៈវិញ្ញាណនៅក្នុងវប្បធម៌ ដែល>មានទំនៀមទម្លាប់ប្រពៃណីហ្នឹងច្រើននៅជុំវិញ<ទស្សនៈលោកធាតុ>។ ដូច្នេះ ខ្ញុំក៏ចាប់ផ្តើមប្រមូលតាមដែលអាចធ្វើទៅបាននូវការរៀបរាប់របស់ប្រជាជនអំពីពាក្យ "អង្គការ"នេះ។ ដូចខ្ញុំបានឆ្លើយពីម្សិលមិញ <ដំបូង ការរៀបរាប់ទាំងអស់នោះគឺ>មិនមែនលេចចេញមក<ភ្លាមៗ>ក្នុងកិច្ចសម្ភាសន៍លើកទី១ ទេ <ប៉ុន្តែដោយសារតែខ្ញុំបានជួបប្រជាជនពីរបីដង និងបាន>ធ្វើដំណើរជាមួយ<ពួកគាត់ ខ្ញុំក៏បានស៊ាំនឹងវិធីដែលគេពន្យល់បង្ហាញអំពី>ពាក្យ "អង្គការ" <ហើយយើងបានសន្ទនាគ្នា>អំពីទស្សនៈនៃពាក្យថា "អង្គការ"នេះ។ <មានបុគ្គលម្នាក់បានប្រាប់ខ្ញុំថា>បើសិនណាជាដួងព្រលឹងរបស់ដូនតាដែលបានស្លាប់ទៅនោះ<បានដើរត្រាច់ចរគ្រប់ទីកន្លែង> គឺថា អង្គការក៏ត្រូវមានលទ្ធភាពធ្វើដូចដែលជាដួងព្រលឹងរបស់ដូនតានោះដូច្នោះដែរ<។ ដូច្នេះការយល់ឃើញនេះ ដែល>កម្លាំងខ្លះៗដែលវាធ្វើឲ្យមានរឿងរ៉ាវ<កើតឡើង ហើយអ្នកខ្លះបាននិយាយថា ពួកគេមិនដឹងថាអ្វីជាអង្គការនោះទេ។ កម្លាំងខ្លះបានបង្កើតរឿងរ៉ាវឡើង> ហើយបង្កើតឲ្យមានភាពច្របូកច្របល់អាណាធិបតេយ្យដែលប្រជាជន<ព្យាយាមក្នុងការសម្របខ្លួនជាមួយ។ តើរឿងមួយដែលធ្វើឲ្យវាសម

ហេតុផលដោយរបៀបណា? វា>ហាក់បីដូចជាមានលក្ខណៈសមហេតុសមផល<ណាស់> បើ<សិនជាអ្នកមិនអាចធ្វើអារម្មណ៍ឱ្យសមហេតុផលចំពោះរឿងអ្វីមួយនោះ។ គឺថាវាតាំងពីមុនពេលមាន>ប្រព័ន្ធនៃមូលដ្ឋាន<មួយ>ដែលប្រជាជន<យល់ឃើញថាមានវិញ្ញាណដើរត្រាច់ចរគ្រប់ទីកន្លែង ការគ្រប់គ្រងវិញ្ញាណ ការផ្លាស់ប្តូរវិញ្ញាណ វិញ្ញាណបោកបញ្ឆោត វិញ្ញាណដែលអាចបោកបញ្ឆោតអ្នក។ វាគឺជារឿងមួយដែលសមហេតុផល ដែលប្រជាជនអាចចាប់ផ្តើមមានបទពិសោធន៍ជាក់លាក់មួយក្នុងការ>ភ័យខ្លាច <ដែលពួកគេបានស៊ាំរួចទៅហើយ គឺនៅពេលដែលពួក>គាត់មិនអាចគិតឃើញថា តើមានអ្វីដែលកំពុងតែកើតឡើងនេះ។ ហើយអង្គការនេះ អាចមានកម្លាំងអ្វីមួយដែលយើងមើលមិនឃើញនេះ កម្លាំងមួយដែលវាកើតមានខ្លាំងឡើងៗពីពេលមួយទៅពេលមួយ។

[០៩:៣៥:០៤]

ពាក់ព័ន្ធទៅនឹង<ផ្នែកនៃសំណួររបស់អ្នក អំពី>តួនាទីរបស់អង្គការនៅក្នុងការរៀបការ ខ្ញុំថាវាមានភាពច្របូកច្របល់បន្តិចសម្រាប់ប្រជាជនយើង ដោយសារថា ម្យ៉ាងនោះប្រជាជនអាចនិយាយថាអង្គការបានរៀបចំការរៀបការរបស់យើង។ ប៉ុន្តែគេដឹងហើយអ្នកដែលរៀបចំការរៀបការឱ្យពួកគាត់ហ្នឹង គាត់ដឹង គឺមនុស្សហ្នឹងហើយជាអ្នករៀបចំឱ្យគាត់<។ ដូច្នេះហើយ គឺវាមានភាពទាក់ទងមួយជាមួយនឹងរូបវន្តបុគ្គល។> ប៉ុន្តែក្រោយពេលការរៀបការរួចមក ហើយខ្ញុំ<សូមឱ្យឧទាហរណ៍អំពី>គូស្រករដែលដើរ ដែលគាត់ដើរជាមួយគ្នានៅពេលយប់ <ហើយពួកគាត់មានការភ័យខ្លាចសូម្បីតែគិត> ពីព្រោះថា អង្គការមាននៅគ្រប់កន្លែងទាំងអស់។ <>

**សៈ** សូមអរគុណ។ អង្គជំនុំជម្រះនឹងសម្រេចថា តើបរិបទនៃការភ័យខ្លាច ដូចដែលលោកស្រីបានរៀបរាប់តាំងពីព្រឹកមិញហ្នឹង តើវាមានលក្ខណៈគំរាមកំហែងយ៉ាងម៉េចខ្លះនោះ <ដោយសារថាវាជាមូលដ្ឋាននៃការសម្រេចថាតើ>ការរៀបការ <ដែលលោកស្រីបាននិយាយយោងតាំងពីពេលចាប់ផ្តើមសវនាការរបស់លោកស្រីនោះ> អាចចាត់ទុកថាជាឧក្រិដ្ឋកម្ម។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីពាក្យថា កាតព្វកិច្ចយោធានេះ លោកស្រីបានប្រើពាក្យហ្នឹង *ខន់ស្រ្តីបសិន* នេះ។ អ៊ីចឹង ខ្ញុំនឹងដកស្រង់ឃ្លាមួយនៅសៀវភៅរបស់លោកស្រី គឺទំព័រ២៩ ជាភាសាអង់គ្លេស។ លោកស្រីបានរៀបរាប់ដូចតទៅ៖ "អាពាហ៍ពិពាហ៍តាមកំណែនបានក្លាយទៅជាកាតព្វកិច្ចមួយនៅក្នុងប្រទេស ដែលឱ្យប្រទេសនេះឃោសនាជាផ្លូវការអំពីគោលនយោបាយរបស់កុម្មុយនីស្ត"។<តើ>លោកស្រីអាចរៀបរាប់លម្អិតអំពីសញ្ញាណនេះបានទេ ពីព្រោះថា លោកស្រីហាក់ដូចជាប្រើពាក្យ *"ខន់ស្រ្តីបសិន"* ហ្នឹង ពាក្យថា "កាតព្វកិច្ច" ហ្នឹង

ដូចជា ការឃោសនារបស់រដ្ឋកុម្មុយនីស្តនេះ? អ៊ីចឹងខ្ញុំចង់ដឹងថា តើពាក្យថា *"ខន់ស្រ្តីបសិន"* ហ្នឹងវាជាការ វាជាគម្រោងនៃការឃោសនារបស់រដ្ឋកុម្មុយនីស្តមែនទេ? <តើនោះជាគោលបំណងនៃអ្វីដែលលោកស្រីនិយាយថា ជាកាតព្វកិច្ចក្នុងការរៀបការ ឬក៏តាមរយៈការរៀបការនោះឬ?>

[០៩:៣៧:៤៨]

**ឆ៖** ចំពោះខ្ញុំ វាមិនមែនពាក់ព័ន្ធទៅនឹងការ<បង្កើតកូនចៅ នោះទេ>។ វាពាក់ព័ន្ធទៅនឹងការបង្កើតរចនាសម្ព័ន្ធដែលនាំទៅដល់កើតមានជំរំរួមរស់នៅរួបរួមគ្នា។ បានន័យថា ជំរំនេះមានការជ្រើសរើសប្រជាជនឲ្យរស់នៅ នៅក្នុង នៅកន្លែងនោះ។

**ស៖** សូមអរគុណ នៅក្នុងឃ្លាដែលខ្ញុំទើបតែអាននោះ លោកស្រីបាននិយាយសំដៅទៅលើរដ្ឋកុម្មុយនីស្ត ដែលអាចទាញឲ្យមានការ ទាញសន្និដ្ឋានមួយ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកស្រីឯកភាព ឬក៏អត់? បើខ្ញុំយល់មិនច្រឡំទេ ចំពោះទស្សនៈរបស់លោកស្រីទៅលើពាក្យថា *"ខន់ស្រ្តីបសិន"* នេះ លទ្ធផលនៃការស្រាវជ្រាវរបស់លោកស្រីហ្នឹង បានធ្វើឲ្យលោកស្រីថា លោកស្រីរកឃើញថា ប្រជាជនហ្នឹងត្រូវបានគេដាក់កំណត់កាតព្វកិច្ចឲ្យរៀបការ ហើយអាហ្នឹងវាជាកាតព្វកិច្ចមួយដែលកំណត់ដោយរដ្ឋកុម្មុយនីស្តតាមពាក្យរបស់លោកស្រីហ្នឹង។ អ៊ីចឹងមានន័យថា ពាក្យថា*"ខន់ស្រ្តីបសិន"* ឬក៏ថាកាតព្វកិច្ចឲ្យរៀបការហ្នឹង វាជាគោលនយោបាយរបស់រដ្ឋមែនទេ?

**ឆ៖** ខ្ញុំមិនអាចនិយាយបញ្ជាក់ថា ឲ្យច្បាស់ទេ ត្រង់ចំណុចហ្នឹង។

[០៩:៣៩:២២]

**ស៖** អ៊ីចឹងនៅក្នុងសៀវភៅរបស់លោកស្រី នៅពេលដែលលោកស្រីនិយាយនៅទំព័រ២៩ថា ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសតទៅទៀត៖ "កាតព្វកិច្ចរបស់រដ្ឋក្នុងការឃោសនារដ្ឋកុម្មុយនីស្ត" អ៊ីចឹងលោកស្រីប្រើពាក្យថា "រដ្ឋកុម្មុយនីស្ត" នេះ អ៊ីចឹងលោកស្រីអាចពន្យល់បានទេ ក្នុងនេះដូចជាមានភាពផ្ទុយគ្នា? ទី១ លោកស្រីនិយាយថា វាជាគោលនយោបាយរបស់រដ្ឋ ហើយថ្ងៃនេះ លោកស្រីថា មិនមែនទេ កុំនិយាយជាលក្ខណៈទូទៅអ៊ីចឹង។ អ៊ីចឹងវាដូចជាមានភាពចម្រូងចម្រាសគ្នា។ អ៊ីចឹងសូមលោកស្រីបញ្ជាក់ត្រង់ចំណុចនេះបន្តិច។

**ឆ៖** ចម្លើយរបស់ខ្ញុំមុន គឺពាក់ព័ន្ធទៅនឹងពាក្យថា "គោលនយោបាយ"។ ខ្ញុំគិត <ដោយគូសព្រាង>ពេលវេលានិងទីកន្លែងចំពោះអាពាហ៍ពិពាហ៍ <និងកន្លែងកំណើត ដោយ>ខ្ញុំបានមើលលើគោលនយោបាយ<មួយក្នុងការបង្កើតកូនចៅ។ វាគឺជារឿងគួរឲ្យចាប់អារម្មណ៍។> ខ្ញុំពិតជាបានពិនិត្យមើល

ការស្រាវជ្រាវរបស់ខ្ញុំកាលពីយប់មិញ ហើយខ្ញុំបាន<ដកយកនូវក្រុមមនុស្សដែលខ្ញុំធ្វើការស្រាវជ្រាវក្នុងឆ្នាំ១៩៧៩។ ខ្ញុំចាប់អារម្មណ៍ក្នុងការមើលថាតើមានអ្វីកើតឡើង ជាមួយចំនួនជាភាគរយរបស់ប្រជាជនដែលគេបានបង្ខាប់បញ្ជាឲ្យរួមភេទនោះ ពីព្រោះថាដើមឡើយ ចំនួន៣៩ភាគរយ គឺជាតួលេខតំណាងដ៏ធំជាងគេ នៅពេលដែលខ្ញុំធ្វើស្រាវជ្រាវលើក្រុមមនុស្សក្នុងឆ្នាំ១៩៧៩នោះ>។ ខ្ញុំបានធ្វើការសិក្សា<មួយពាក់ព័ន្ធនឹង>អាពាហ៍ពិពាហ៍ ដែលត្រូវបានផ្សំផ្គុំ ឬរៀបចំ ដោយភ្នាក់ងាររបស់ខ្មែរក្រហម <គឺខ្ញុំធ្វើការស្រាវជ្រាវនៅក្នុង>ឆ្នាំ១៩៧៩។ <ដូច្នេះខ្ញុំបានតាមដានពិនិត្យមើលក្រុមតំណាងនោះ។ ប៉ុន្តែនៅពេលដែលខ្ញុំដកយកក្រុមតំណាងនៃការស្រាវជ្រាវក្នុងឆ្នាំ១៩៧៩ មកពិនិត្យមើល គឺវាមិនមានអ្វីខុសគ្នាច្រើននោះទេ គឺថាតួលេខចំនួន>៣៩ភាគរយ <គឺមកមានត្រឹមចំនួន៣៨ភាគរយវិញ។ ឥឡូវនេះ> អ្វីដែលសំខាន់ចំពោះខ្ញុំក្នុងការ<គិតប្រមើលមើល>ទៅលើអាពាហ៍ពិពាហ៍នេះ <គឺខ្ញុំបាន>មើលឃើញ<ច្បាស់ណាស់>អំពីការវិវត្តន៍នៃគោលនយោបាយ<មួយនៅចុង>ឆ្នាំ៧៨ <ចូលដល់ឆ្នាំ>៧៩ ដោយសារតែនៅពេលនោះ រឿងរ៉ាវទាំងឡាយ វាកាន់តែកើតឡើងជាក់លាក់ ហើយវាបានបង្ហាញ<អំពីភាពស៊ីសង្វាក់គ្នាទៅនឹងដំណើរការរៀបចំការរៀបការ ថាតើរឿងរ៉ាវកើតឡើងដោយរបៀបណា និងការបង្ខាប់បញ្ជានៅតំបន់ផ្សេងៗគ្នា>។ អ៊ីចឹង <ឧទាហរណ៍ គំរូដ៏ធំនៃតំបន់ គឺ>ខេត្តកណ្តាលហ្នឹង គឺ<នៅពេលដែលខ្ញុំបានដកយកនូវគំរូពីការស្រាវជ្រាវក្នុងឆ្នាំ៧៩ គឺគំរូខេត្តកណ្តាល> ឃើញថាអ្នកដែលឆ្លើយហ្នឹង ១០០ភាគរយ គឺថាបាន<ឆ្លើយថា ពួកគាត់ត្រូវបានបង្ខាប់បញ្ជាឲ្យរួម>ភេទ។

<ដូច្នេះ ភាគច្រើននៃដំណើការ>ការងារស្រាវជ្រាវរបស់ខ្ញុំ គឺ<គូសគំនូសតាង និងយល់ពី>អ្វីកើតឡើង <វាកើតឡើងដោយរបៀបណា> នៅពេលណា នៅទីកន្លែងណា នៅពេលណា ហើយកើតឡើងចំពោះបុគ្គលណា។

[០៩:៤២:៥២]

**សៈ** ជាមូលដ្ឋានគ្រឹះនោះ លោកស្រីបាននិយាយអំពីសម្មតិកម្មនៃកាតព្វកិច្ចជាតិ ដូចជាកាតព្វកិច្ចយោធាអ៊ីចឹង។ អ៊ីចឹងលោកស្រីបាននិយាយថា នេះជារបៀបនៃរដ្ឋកុម្មុយនីស្ត ដែលផ្សព្វផ្សាយអំពីគម្រោងបដិវត្តន៍របស់ខ្លួន។ អ៊ីចឹងយើងអាចនិយាយថា កាតព្វកិច្ចជាតិនេះ វាអាចជាប់ព័ន្ធទៅនឹងការបង្កើតនៃគោលនយោបាយនេះទេ? នៅពេលដែលលោកស្រីខ្លួនឯងផ្ទាល់និយាយអំពីកាតព្វកិច្ចជាតិនេះ គឺថា បានន័យថាលោកស្រីមិនបានបញ្ជូល<មេដឹកនាំជាន់ខ្ពស់នៃរដ្ឋនោះថាជាអ្នកផ្តួចផ្តើមគំនិតនោះ> ទេ<ឬ>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំកំពុងតែគិតទៅចំណុចនេះ។ ខ្ញុំនៅតែមានភាពងឿងឆ្ងល់ <ហើយមូលហេតុនោះគឺ> ដោយសារតែយើងឃើញថាវាមិនមាន<សង្គត>ភាព<ក្នុងរបៀបដែលប្រជាជនត្រូវបាន>ជ្រើសរើស <សម្រាប់ប្រើប្រាស់ក្នុងការងារ>។ ពួកគាត់ត្រូវបានគេជ្រើសរើសឲ្យរៀបអាពាហ៍ពិពាហ៍ គឺយើងឃើញកើតឡើងច្បាស់លាស់ ហើយអាពាហ៍ពិពាហ៍នោះគឺត្រូវតែមានការយល់ស្រប<។ ជាញឹកញាប់> ឈ្មោះរបស់អ្នកទាំងអស់នោះត្រូវបានគេបញ្ចូលនៅក្នុងបញ្ជី<មួយ។ មេ>ក្រុមខាងនារី និង <មេក្រុមខាង>បុរសហ្នឹងជួបប្រជុំគ្នា ហើយធ្វើការជ្រើសរើសបញ្ជីឈ្មោះអ្នកដែលណាដែលសម និងរៀបការជាមួយនឹងគ្នា។ ហើយបន្ទាប់មកគឺបញ្ជូនទៅថ្នាក់ឃុំ ហើយបន្ទាប់មកការងារជាច្រើនបានកើតឡើងក្រោមកាតព្វកិច្ចតួនាទីរបស់បុគ្គលរៀងៗខ្លួន និងអ្នកដែលជាប្រធាន ជាអ្នករៀបចំ ឬក៏ជាអធិបតីនៅក្នុងកិច្ចអាពាហ៍ពិពាហ៍ គឺជា<អាចជាថ្នាក់ដឹកនាំស្រុក ថ្នាក់ដឹកនាំឃុំ ថ្នាក់នាំភូមិ ឬអាចជាកម្មាភិបាលដែលប្រាប់ឲ្យអ្នកណាម្នាក់រួមភេទ។ វាមានលក្ខណៈខុសៗគ្នា។>។

[០៩:៤៥:០៥]

<ក៏ប៉ុន្តែ គឺមានកន្លែងខ្លះ រឿងរ៉ាវបាន>កើតឡើងតាមទម្រង់<ដូចគ្នា។ ដូច្នេះអ្វីដែលហាក់បីដូចជាត្រូវនិយាយនោះ គឺសម្រាប់ខ្ញុំ វាទាំងអស់នេះ គឺជាសម្មតិកម្ម គឺ>ថាមាន<អ្នក>ដែលស្ថិតនៅក្នុងតំបន់មួយចំនួនដែលខ្ញុំ<មិនដឹងថាតើ>ពួកគាត់មានតំណែង ឋានៈអ្វីនោះទេ ដែលអ្នកទាំងអស់នេះមានតួនាទី<មួយ>នៅក្នុងតំបន់<មួយ>ក្នុងការបំពេញការងារ<>ដោយមិនមានផែនការជាក់ស្តែង ក៏ប៉ុន្តែ <ការងារដែល>ត្រូវ<ធ្វើនោះ គឺ>រៀបចំការរៀបអាពាហ៍ពិពាហ៍ <ដែលនៅទីបំផុត វានឹងនាំឲ្យ> ប្រជាជន<លែងនៅ>តាមកងចល័ត<ទៀតហើយ គឺប្រជាជន>ស្នាក់នៅកន្លែងជាក់លាក់ណាមួយ។ <ខ្ញុំបានន័យថា វាគឺជាលទ្ធភាពមួយក្នុងការចុះទៅមើលតាមភូមិ និងជួបប្រជាជន ដែលនៅរស់រានមានជីវិតនៅទីនោះ ដែលពួកគាត់>ត្រូវបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងក្រុម<ដូចគ្នា ឬជាមួយនឹងក្រុម>ផ្សេង<ៗគ្នា។ នេះគឺជាលទ្ធភាពមួយដែលប្រជាជនត្រូវបានជ្រើសរើសយ៉ាងសំខាន់សម្រាប់ភូមិមួយ។> នេះ<គឺជា>លទ្ធភាព<មួយ>។

**ស៖** ខ្ញុំសូមអរគុណ។ ឥឡូវខ្ញុំនឹងចូលនិយាយដោយខ្លីអំពីចំណុចរួមដែលលោកស្រីបាននិយាយនៅក្នុងសៀវភៅរបស់លោកស្រី។ លោកស្រីនិយាយនៅទំព័រ១៧៦ វាដូចអ្វីដែលលោកស្រីទើបតែនិយាយដែរ ក៏ប៉ុន្តែលោកស្រីហាក់ដូចជាធ្វើការសន្និដ្ឋានថាមានចំណុចរួម ចំណុចដូចគ្នានៅក្នុងពិធីរៀបការក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ ជាអង់គ្លេសទំព័រ១៧៦ ខ្ញុំដកស្រង់៖"ក៏ប៉ុន្តែនៅត្រឹមចុងឆ្នាំ

១៩៧៧ សមាសភាពរួមបានចូលរួមនៅក្នុងការរៀបអាពាហ៍ពិពាហ៍ទៅទូទាំងតំបន់ ដូចជាសុន្ទរកថាមានលក្ខណៈស្រដៀងគ្នា -- ខ្លឹមសារសុន្ទរកថាមានលក្ខណៈស្រដៀងគ្នា ហើយនិងរបៀបនៃការប្ដេជ្ញាជូនអង្គការ ក៏មានលក្ខណៈស្រដៀងគ្នាទៅនឹងការរៀបការនាពេលក្រោយមក"។ តើលោកស្រីអាចនិយាយអធិប្បាយបន្តិចបានដែរឬទេ អំពីការសន្និដ្ឋានរបស់លោកស្រី ដែលថាក្នុងការរៀបការនោះ ចាប់ពីឆ្នាំ១៩៧៧ទៅគឺមានលក្ខណៈដូចគ្នា ហើយនិងមានការសន្យាប្ដេជ្ញាចិត្តដូចគ្នាគ្រប់កន្លែងទាំងអស់ មានលក្ខណៈដូចគ្នា។ អ៊ីចឹងសូមឲ្យលោកស្រីបញ្ជាក់បន្តិចមើល និយាយអត្ថាធិប្បាយបន្តិចមើលអំពីភាពស្រដៀងគ្នាចាប់ពីចុងឆ្នាំ១៩៧៧ ទៅនោះ នៅក្នុងរាល់គ្រប់ពិធីរៀបការហ្នឹងគឺមានលក្ខណៈដូចៗគ្នា?

[០៩:៤៨:២៥]

**ឆ៖** ពាក់ព័ន្ធទៅនឹងសុន្ទរកថា<ទាំងអស់នេះ គឺវា>មានលក្ខណៈស៊ីសង្វាក់គ្នា <ទៅនឹងអ្វីដែលជា>ខ្លឹមសារ<នៅក្នុងការប្ដេជ្ញា។> ភាពភក្ដីភាពគឺ<ប្រហែលស្ថិតនៅក្នុងលេខ១> ហើយ<សេចក្ដីស្រឡាញ់ និងរស់>នៅជាមួយគ្នាអស់មួយជីវិត<គឺប្រហែលនៅក្នុងលេខ២។ មានការ>រៀបការ<ច្រើននៅចុងឆ្នាំ>៧៦ និងដើមឆ្នាំ៧៧ <ដែលប្រជាជនត្រូវបានស្នើឲ្យផលិតចំនួនស្រូវឲ្យបានតាមការកំណត់ជាក់លាក់មួយ។ នៅក្នុងសុន្ទរកថា>ចុងឆ្នាំ៧៧ និង៧៨ <គឺមាននិយាយអំពីការផលិតបានតិចតួច។ មូលហេតុដែលខ្ញុំចាប់អារម្មណ៍ចំពោះ> ភូមិភាគនិរតី <គឺដោយសារតែរឿងរ៉ាវដែលបានកើតឡើងពាក់ព័ន្ធទៅនឹង>ការបោសសម្អាត<ឬក៏រឿងរ៉ាវផ្សេងដែលបានកំពុង>កើតឡើងនៅក្នុងប្រទេស។ វាហាក់ដូចជា <ប្រសិនណាធ្វើឲ្យមានឡើងវិញនូវប្រពៃណីទំនៀមទម្លាប់នៅក្នុង>អាពាហ៍ពិពាហ៍<ដែលបានធ្វើឡើងនៅក្នុង>នៅក្នុងភូមិភាគនិរតី ហើយវារីករាលដាលរហូតទៅដល់ខាងភូមិភាគបូព៌ា។ តាមពិតទៅ <ខ្ញុំអាចនិយាយតែទៅលើក្រុមគំរូនៅក្នុងការស្រាវជ្រាវរបស់ខ្ញុំ ដោយសារតែខ្ញុំមិនមានការ>សិក្សាស្រាវជ្រាវការរៀបការណាមួយក្រៅពីខេត្តបាត់ដំបង <នៅមុនឆ្នាំ១៩៧៨>នោះទេ។ <ដូច្នេះហើយ> ខ្ញុំអាចមើលឃើញ<ពាក់ព័ន្ធនឹងពេលណាដែលរឿងរ៉ាងកើតឡើង។ សម្រាប់តំបន់នេះ ហាក់បីដូចជាធ្វើតាមប្រពៃណីទំនៀមទម្លាប់យ៉ាងល្អភ្លាមៗ ហើយការប្ដេជ្ញាទាំងអស់នេះ គឺមានធ្វើឡើងនៅក្នុងតំបន់នេះ>។ ចំពោះខ្ញុំវាហាក់ដូចជា <ប្រសិនបើមានការហាត់សមថ្លែងការណ៍ប្ដេជ្ញា>ទុកជាមុនហើយ<មានមធ្យោបាយមួយចំនួនក្នុងការព្យាយាមដើម្បីធ្វើឲ្យប្រព័ន្ធដំណើរការហ្នឹងទៅបានយ៉ាងឆាប់រហ័ស ហេតុដូច្នេះហើយយើងអាច>បង្កើតឃុំ<ទាំងអស់នោះភ្លាមៗ នៅ>ក្រោយ<ពេល>បោសសម្អាត<មនុស្ស>ដែល<យើង>មិនចង់ទុក<នៅទីនោះ> ហើយ<យើងអាច នាំយក>ប្រជាជន

01365396



<ដែលយើងចង់ឲ្យមករស់នៅទីនោះវិញ>។ វាហាក់ដូចជាដំណើរការនៃគ្រឿងម៉ាស៊ីនដូចគ្នានោះឯង។

[០៩:៥០:៤២]

**ស៖** ខ្ញុំសូមអរគុណ។ នៅក្នុងសៀវភៅរបស់លោកស្រីនៅទំព័រ១៩៤ -- ១៧៤ (សុំទោស) គឺថានៅកន្លែងខ្លះនៅក្នុងប្រទេសកម្ពុជា គឺថាមានការកើនអត្រាកំណើតហ្នឹងកើនឡើងនៅឆ្នាំ១៩៧៧។ <ខ្ញុំមិនដឹងថាតើលោកស្រីរកបានឯកសារយោងឬយ៉ាងណានោះទេ។> លោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើចាប់ពីឆ្នាំ១៩៧៧ឡើងទៅ អត្រាកំណើតហ្នឹងកើនឡើង អាចពន្យល់ពីមូលហេតុបានដែរឬទេ? ហើយម្សិលមិញហ្នឹងយើងបាននិយាយអំពីគោលនយោបាយ របស់កម្ពុជាប្រជាធិបតេយ្យដែលចង់បង្កើនអត្រាកំណើតនៅសម័យនោះ។ អ៊ីចឹងតើលោកស្រីមានឃើញថា មានទំនាក់ទំនងគ្នា <រវាងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ> ជាមួយនឹង<គោលបំណងរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការបង្កើតប្រជាពលរដ្ឋ ហើយនិងសីលធម៌ប្រការទី៦ ដែលថា ការរួមភេទដែលមិនមានលក្ខណៈជាប្ដីប្រពន្ធនឹងគ្នាគឺត្រូវហាមឃាត់ ដូច្នេះគេត្រូវ>រៀបអាពាហ៍ពិពាហ៍<ដើម្បីអាចរួមភេទបាន>? <ហើយនៅក្នុងតំបន់ខ្លះ>ក្នុងឆ្នាំ១៩៧៧នេះយើងឃើញថា មានចំនួនកុមារកើនឡើងច្រើន។ <នៅក្នុងមុខវិជ្ជាដែលលោកស្រីស្រាវជ្រាវ អាន និងធ្វើការ តើលោកស្រីចាត់ទុកថា លោកស្រីអាចបង្កើតទំនាក់ទំនងរវាងទាំងពីរនេះបានទេ ឬក៏មិនបាន>ទេ?

[០៩:៥២:២៦]

**ឆ៖** ខ្ញុំបានធ្វើការពិនិត្យ<>មើលកំណើននៅក្នុង<រចនាសម្ព័ន្ធឃុំ> ហើយខ្ញុំបានពិនិត្យ<តាមដាន>មើលមុខងាររបស់<ឃុំទាំងអស់នោះ ឬក៏>ទីការដ្ឋាននៅតាមឃុំដែល<>ប្រជាជន<ត្រូវបានគេរៀបការឲ្យជាក្រុម និងរស់នៅក្នុងតំបន់ទាំងអស់នោះដើម្បីបង្កើត>ជាសហគមន៍<មួយ>។ ខ្ញុំមិនអាចនិយាយដោយគ្មានមូលដ្ឋាននោះទេ។ ក៏ប៉ុន្តែវាហាក់ដូចជាបង្ហាញឲ្យខ្ញុំឃើញថា ការបោសសម្អាត <លើកទី១>គឺដើម្បីកម្ទេចខ្មាំង ហើយរកអ្នកដែលមិនអាចទុកចិត្តបាន មិនអាចជឿជាក់បាន និងដើម្បីបង្កើតរចនាសម្ព័ន្ធ និងប្រព័ន្ធមួយដែលប្រជាជនអាចរស់នៅក្នុងកន្លែងនោះ ហើយបន្ទាប់មក ត្រូវបង្កើតកូនចៅ។ ចំពោះខ្ញុំ អ្វីដែលខ្ញុំឃើញ ការបង្កើតរចនាសម្ព័ន្ធសមូហភាព ឬឃុំនោះ វាគឺជាអាទិភាពមួយថាតើគេជំរុញឲ្យរចនាសម្ព័ន្ធនោះ វាទៅមុខដោយរបៀបណានោះ យើងឃើញថាវា<មិនតែងតែ>ស៊ីសង្វាក់គ្នា<នោះទេ>។ ខ្ញុំបានសួរសំណួរមួយនៅ<ផ្នែកខាង>លើទំព័រ<៧៤> ឬក៏<ប្រហែលជានៅផ្នែកខាងក្រោមនៃ>ទំព័រ៧៣ តើខ្មែរក្រហមគូសរៀបចំរចនាសម្ព័ន្ធឃុំដើម្បីគ្រប់គ្រងទៅលើផ្លូវភេទ

និង<លុបបំបាត់ចោលប្រពៃណីតួនាទីយេនឌ័រ និង>រចនាសម្ព័ន្ធ<គ្រួសារ>ដែរឬទេ? ឬ<ថាតើ>ការបញ្ជាដោយផ្ទាល់មាត់នោះ ឲ្យរួមភេទ<ក្រោយការរៀបការ គឺនាំឲ្យមានរចនាសម្ព័ន្ធឃុំនោះ> គឺ<បាន>បំផ្លាញទៅលើទំនៀមទម្លាប់<ដែលមាន>តាំងពីដើម<ដែរឬទេ? ប្រសិនបើខ្ញុំនៅតែប្រកាន់ភាពត្រឹមត្រូវនៃ>ការសិក្សារបស់ខ្ញុំ <អំពីការគូសបង្ហាញរចនាសម្ព័ន្ធ និងមុខងាររបស់>អាពាហ៍ពិពាហ៍ និងកំណើត<តាមពេលវេលា និងទីកន្លែង។ សម្រាប់ខ្ញុំ ការចូល>មកដល់ឆ្នាំ៧៩ <អ្វីដែល>ខ្ញុំបានរកឃើញអ្វីខ្លះនោះ ថាយើងឃើញមានថារចនាសម្ព័ន្ធនេះវាកើតឡើងមុន។ តែពីដំបូង <ការវិវត្តន៍>រចនាសម្ព័ន្ធ<នេះគឺ>មានលក្ខណៈច្របូកច្របល់ ហើយមិន <អាចទស្សន៍ទាយបានទេ។ ហើយខ្ញុំគិតថាត្រឹមចុង>ឆ្នាំ៧៨ រចនាសម្ព័ន្ធ<បានចាប់ផ្តើមបង្កើតឡើង ហើយប្រព័ន្ធនៃការដ្ឋានឃុំប្រព្រឹត្តឡើងដោយរបៀបណានោះ គឺ>វាមានភាពជឿនលឿន។ ប្រជាជនរស់នៅជួបជុំគ្នា <មានការតាំងចិត្តមួយចំពោះគ្នាទៅវិញទៅមក> ហើយមានធម្មានុរូប។ ដោយសារតែយើងនិយាយអំពីរបប<បរិសុទ្ធ>មួយដែលមានធម្មានុរូប <ហើយបន្ទាប់មកគឺត្រូវបានគេ>ទទួលស្គាល់នៅក្នុង<នៅក្នុងសហគមន៍ថាជា> អ្នកដែលគាត់រៀបអាពាហ៍ពិពាហ៍<រួច>ហើយ<។ នេះគឺជារឿងដែលសំខាន់ ហើយ>បន្ទាប់មកគឺ<> ដំណើរជីវិតរបស់ពួកគេទៅមុខ ដើម្បីបង្កើតកូនចៅ។ នៅក្នុង*សេមថ្លូរ*របស់ខ្ញុំ ខ្ញុំអាចទៅពិនិត្យមើលឆ្នាំ និងទីកន្លែងឡើងវិញ ដោយសារខ្ញុំអត់ចាំ។ ខ្ញុំ<មានបុគ្គលម្នាក់ នៅក្នុងគំរូរបស់ខ្ញុំ គឺខ្ញុំអាចស្វែងរកបាននៅពេលសម្រាក ពាក់ព័ន្ធនឹងឆ្នាំ និងទីកន្លែង ពីព្រោះឥឡូវនេះខ្ញុំមិនមានវានោះទេ។ បុគ្គលម្នាក់នោះបាននិយាយថា --> ខ្ញុំជឿថា <ករណីនេះគឺពាក់ព័ន្ធនឹងអង្គការ។> អង្គការគេប្រាប់ថាឲ្យបង្កើតកូនមួយក្នុងមួយឆ្នាំ។ ខ្ញុំបានរកឃើញនៅក្នុងករណីមួយ ដូច្នេះ<វាមានការពិបាក សម្រាប់ខ្ញុំក្នុងការធ្វើសេចក្តី>សន្និដ្ឋាន<មួយ ដោយពឹងផ្អែកតែទៅលើករណីមួយនេះ>។

[០៩:៥៦:២៩]

**ស៖** ខ្ញុំសូមអរគុណ។ ខ្ញុំសូមជម្រាបជូនតុលាការថា ខ្ញុំត្រូវការរយៈពេលប្រហែលជា១៥នាទីទៀត។ អ៊ីចឹង វាត្រូវនឹងពេលវេលាដែលចៅក្រមចែកឲ្យខ្ញុំហើយ។ លោកស្រីបាននិយាយពីការរៀបការដោយទ្រង់ទ្រាយធំនៅក្នុង នៅចុងឆ្នាំ១៩៧៨ នៅតាមការដ្ឋានជីកប្រឡាយ។ តើការរៀបការហ្នឹង មានលក្ខណៈខុសគ្នាដែរឬទេ? មានជំនាញម្នាក់<ដែលយើងបានពិភាក្សាកាលពីម្សិលមិញ>នោះ<គាត់បានមកផ្តល់សក្ខីកម្មមុនលោកស្រី គាត់បានបែងចែកដាច់ពីគ្នារវាងលក្ខខណ្ឌនៃការរៀបការដែលប្រព្រឹត្តិទៅហើយនិង>ការរៀបការ<ផ្សេងៗទៀតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ>។ តើ<នេះជាសេចក្តីសន្និដ្ឋាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែល>លោកស្រី<រកឃើញដោយខ្លួនឯង ដែល>ថា ការរៀបការច្រើនគូនេះនៅចុងរបបហ្នឹង <រួមទាំង>លក្ខណៈពិសេស<>ដែលអាចឱ្យលោកស្រីបែងចែកឱ្យដាច់ពីការរៀបការជាទូទៅនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងដែរឬទេ?

**ឆ៖** ពាក់ព័ន្ធគំរូបែបបទ<នៃចំនួនដ៏ច្រើននេះ គឺថាភាគច្រើន គឺប្រើការបានជាប្រយោជន៍ច្រើន។ យើងមានមនុស្សច្រើននៅក្នុងការដ្ឋានការងារមួយ ហើយយើងបានរៀបការឱ្យមនុស្សជាច្រើននៅក្នុងការដ្ឋានការងារនោះ។ អ្នកខ្លះត្រូវបានរៀបការនៅតាមផ្លូវ>។ ខ្ញុំបានពិនិត្យមើលការរៀបការនៅក្នុងឆ្នាំ៧៩។ ចុងឆ្នាំ៧៨ និងដើមឆ្នាំ៧៩ យើងឃើញថាមានការថយចុះនៅតាមទីកន្លែងជាច្រើន។ ក៏ប៉ុន្តែវា<គ្រាន់តែជាបញ្ហាមួយ>ពាក់ព័ន្ធទៅនឹង<ភាពងាយស្រួលក្នុង>ការជ្រើសរើស<ចំនួនតែប៉ុណ្ណោះ។ ខ្ញុំដឹង គេនិយាយថា> ការរៀបការ ចាប់ផ្តើមពី<គូស្រករពីរ>គូ ហើយខ្ញុំមាន<រឿងរ៉ាវមួយចំនួន ដែលខ្ញុំបានរកឃើញ មានគូស្រករតែមួយគូត្រូវបានគេ>រៀបការ<ឱ្យ> ដោយសារតែតំបន់នោះ វានៅដាច់ស្រយាល<។ ហើយខ្ញុំអាចគិតទៅដល់គូស្រករ>ពីរគូ នៅក្នុងការស្រាវជ្រាវរបស់ខ្ញុំក្នុងឆ្នាំ៧៩ គឺនៅតំបន់ដាច់ស្រយាលក្នុងភូមិភាគឧត្តរ។ គឺថា>មិនមាន<មនុស្សរស់នៅច្រើន>នៅជុំវិញ<ពួកគាត់ទេ។ ហេតុដូច្នេះហើយ ប្រធានឃុំបានសម្រេចចិត្តរៀបការតែមួយគូប៉ុណ្ណោះ។ ខ្ញុំគិតថា ចំពោះចំនួននៃការរៀបការមានច្រើន គឺវាពាក់ព័ន្ធទៅនឹងភាពងាយស្រួល និងចំនួនប្រជាជនច្រើននៅទីនោះ ទើបអាចធ្វើរឿងទាំងអស់នោះបាន>។

[០៩:៥៨:៥៦]

**សៈ** មុននឹងនិយាយអំពីផលប៉ះពាល់នៃការបាត់បង់វិធីសែនព្រេន និងអ្វីដែលលោកស្រីបាននិយាយពីដើមដំបូងនៃការផ្តល់សក្ខីកម្មរបស់លោកស្រី ទៅលើអ្នកដែលរស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ <និងលទ្ធផលនៃរបបនោះ ព្រោះថានោះជាផ្នែកសំខាន់នៅក្នុងសៀវភៅរបស់លោកស្រី>។ ឥឡូវហ្នឹង ខ្ញុំសូមត្រឡប់មកនិយាយអំពីចំណុច ពីពាក្យមួយ និយាយពីពាក្យមួយ ដូចថាពាក្យថា មានន័យថា "បង្ខំ" ពាក្យបង្ខំនោះ។ ខ្ញុំសូមចែករំលែកជាមួយលោកស្រី ដោយការពិចារណាមួយ។ លោកស្រីបានសរសេរជំពូកមួយនៅក្នុងសៀវភៅរបស់លោកស្រី។ លោកស្រីនិយាយ ចំណងជើងថា "តើការរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ជាការរៀបការដោយបង្ខំ ឬក៏អត់?" លោកស្រីបានបញ្ជាក់<នៅពេលដំបូងនៃសវនាការនេះថា ការរៀបការ>នៅក្នុង<របបកម្ពុជាប្រជាធិបតេយ្យ> មិនមែនជាការរៀបការដោយបង្ខំទេ ហើយ<នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់>លោកស្រី<> លោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្រីមិនប្រើពាក្យច្បាប់ទេ ហើយក៏ប៉ុន្តែលោកស្រីបាននិយាយជម្រាបជូនចៅក្រម ហ្វេនស៍ ថាលោកស្រីមិន<ប្រើ>ពាក្យច្បាប់ទេ។ <ដូច្នេះនេះជាពាក្យដែលលោកស្រីបានប្រើយ៉ាងច្រើនដង។ ហើយលោកស្រីបាននិយាយទៅកាន់ចៅក្រម ហ្វេនស៍ ថាលោកស្រីមិនបានផ្តល់និយមន័យឱ្យវានោះទេ> ព្រោះថាពាក្យនេះមិនមែនជាកម្មវត្ថុនៃការសិក្សារបស់លោកស្រីទេ។ <តើលោកស្រីមិនឃើញពីការផ្ទុយគ្នាទេឬនៅត្រង់ចំណុចនេះ ឬក៏ជាបញ្ហាមួយ ដែលនាំឱ្យ>លោកស្រីនិយាយថា ការរៀបការនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យមិនមែនជាការរៀបការដោយបង្ខំនោះទេ តែលោកស្រីឆ្លើយថា លោកស្រីមិនស្គាល់ មិនយល់អំពីនិយមច្បាប់នៃពាក្យ "រៀបការដោយបង្ខំ" នេះទេ? អ៊ីចឹងលោកស្រីអាចពន្យល់បានដែរឬទេ? ហើយ<ជាថ្មីម្តងទៀត ខ្ញុំមិននិយាយពីនិយមន័យច្បាប់ទេ។ ខ្ញុំនិយាយអំពីនិយមន័យដែលអាចឱ្យលោកស្រីអាចចាត់ទុកថា ការរៀបការនោះមិនមែនជាការបង្ខំនោះទេ។ ខ្ញុំមានការភ្ញាក់ផ្អើល កាលពីម្សិលមិញ គំនិតនៃការបង្ខិតបង្ខំ បានបើកនូវទ្វារថ្មីមួយ ហើយលោកស្រីបាននិយាយពីម្សិលមិញថាលោកស្រីចាត់ទុកគំនិតនេះជាជាការបង្ខិតបង្ខំ។ ប៉ុន្តែខ្ញុំចង់ចំណាយពេលពីរបីនាទីដើម្បីនិយាយអំពីភាពផ្ទុយគ្នានេះ ដែលហាក់ដូចជាចម្លែកសម្រាប់ខ្ញុំ។> តើលោកស្រីអាច<>ទាញការសន្និដ្ឋានថា <>ការរៀបការនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ វាមិនមែនជាការរៀបការដោយបង្ខំយ៉ាងម៉េចទៅ បើលោកស្រីខ្លួនឯងផ្ទាល់មិនស្គាល់និយមន័យច្បាប់នៃពាក្យដូចថា "រៀបការដោយបង្ខំ" នេះផងនោះ? <តើលោកស្រីយល់សំណួរខ្ញុំទេ? តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ នូវអ្វីដែលខ្ញុំចាត់ទុកថាជាការផ្ទុយគ្នា និងកម្សោយនៅក្នុងអំណះអំណាងរបស់លោកស្រីនោះ?>

[១០:០១:៣៦]

**ឆៈ** និយាយដោយត្រង់ទៅ ខ្ញុំបានបង្ហាញអំពីយថាភាពនៃការរៀបការ ផ្អែកទៅតាមការយល់ឃើញរបស់ប្រជាជន។ ខ្ញុំបានពិនិត្យទៅលើភាពស្របច្បាប់នៃអាពាហ៍ពិពាហ៍នោះ។ ហើយខ្ញុំមិនចង់ឱ្យកត្តាអ្វីជំរុញខ្ញុំទៅលើការយល់ឃើញរបស់ខ្ញុំនោះទេ។ <ខ្ញុំអាចនិយាយថា សំណួររបស់ខ្ញុំ គឺត្រូវបានឆ្លើយរួចទៅហើយ។> ពាក់ព័ន្ធទៅនឹងការបង្ខំដែលលោកស្រីបានលើកឡើង <ខ្ញុំគិតថា>វាជាសម្ពាធមួយដែលបន្តកើតឡើង <ពីព្រោះកាលពីម្សិលមិញ គឺមានចំណាប់អារម្មណ៍មែនទែន ដោយសារមានការលើកឡើងអំពី>និយមន័យនៅ<>សៀវ៉ាឡេអូន<។ កាលពីយប់មិញ> ខ្ញុំបានពិចារណានៃការ<ប្រើប្រាស់>ពាក្យហ្នឹងនៅក្នុងបរិបទដែល<បានលើកឡើងហ្នឹង គឺវាជាបរិបទដែល>ខ្ញុំ<បាន>ធ្វើការសិក្សាស្រាវជ្រាវ។ <ម្តងទៀត គឺថាការយល់ឃើញរបស់ខ្ញុំ គឺច្បាស់ណាស់វាគឺជាការ>ដាក់សម្ពាធជា

បន្តបន្ទាប់។ <>ការបង្ខំ <ខ្ញុំមានន័យថា ការបង្ខំ បើកាលណាយើងមានការបង្ខិតបង្ខំ ហើយយើងបាន បង្ខំ ហើយយើងមានអ្វីផ្សេងលើសពីហ្នឹង។ សូម្បីតែ>នៅក្នុងបរិបទនៃការបង្ខំនោះ <គឺវាមាន>ការដាក់សម្ពាធ<>បន្តបន្ទាប់<។> ការដាក់សម្ពាធដោយក្រុមអ្នកដែលក្នុងវ័យជាមួយគ្នា <គឺដូចជាការបង្ខំ។> ឧទាហរណ៍ថា តើ<ក្រុមមិត្តភ័ក្តរបស់អ្នកបានបង្ខំឱ្យអ្នកផឹកគ្រឿងស្រវឹង ដែរឬទេ? ថាតើអ្នកទទួលឥទ្ធិពលពីពួកគេ ដោយសារតែអ្នកបារម្ភថាអ្នកនឹងត្រូវបានគេបោះបង់ចោល បើសិនជាអ្នកមិនព្រមនោះ? ទាំងអស់នេះ គឺជាចំណោទសួរដ៏ធំ> ។

[១០:០៣:១៣]

នៅក្នុងបរិបទនៃការសិក្សាស្រាវជ្រាវរបស់ខ្ញុំជាមួយនឹងមនុស្សទាំងឡាយដែលខ្ញុំបានជជែកវែកញែកជាមួយ អ្នកទាំងអស់នោះ គឺខ្ញុំមិនបាន<រៀបចំដោយ>ជ្រើសរើស<ជាគំរូមួយ ដោយផ្អែកទៅលើ>អ្នកដែលអះអាងថាគាត់ទទួលរងនូវអំពើហិង្សាដោយផ្លូវភេទនោះទេ <ឬក៏ក្នុងន័យមួយទៀតនោះ គឺខ្ញុំមិនបានរៀបចំកំណត់លក្ខណៈនៃក្រុមមនុស្សគោលដៅរបស់ខ្ញុំនោះទេ>។ ខ្ញុំអត់មានឃើញភាពខុសគ្នានៅពេលដែលយើងសួរ<ថា តើ>អាពាហ៍ពិពាហ៍<ស្របច្បាប់ដែរឬទេ?> តើអាពាហ៍ពិពាហ៍នោះ<ត្រូវបាន>ទទួលស្គាល់<>ដែរឬទេ? <តើវាជាការរៀបការ>ពិត<ដែរឬទេ? ហើយគេបានឆ្លើយថា បាទ។ ខ្ញុំមិនបានឃើញភាពសមហេតុផលនោះទេ ពីព្រោះខ្ញុំត្រូវតែបែរត្រឡប់ទៅវិញ ហើយនិយាយថា តើពួកគេទាំងអស់ហ្នឹងនឹងត្រូវបង្ហាញដែរឬទេ? ម្តងទៀត> ដូចដែលខ្ញុំបានលើកឡើង<កាលពី>ម្សិលមិញអ៊ីចឹង <ការបង្ហាញហ្នឹង គឺបានធ្វើឱ្យមានការឈឺចាប់។ ក៏ប៉ុន្តែថា>តើមាននៅពេលណាមួយដែល<ពួកគេត្រូវបាន>សួរអំពី<ភាពស្របច្បាប់>នៃការរៀបការនោះដែរឬទេ។ ពួកគេ<អាច>ត្រូវបានគេសួរ។ អ៊ីចឹងថាតើ<ការជ្រើសរើសគំរូមួយ ចាប់ផ្តើមនៅត្រង់ចំណុចណា? តើអ្វីជាលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសគំរូមួយណាមុនគេ>នោះ? តាមពិតទៅខ្ញុំមិនមានប្រើប្រាស់លក្ខណៈវិនិច្ឆ័យសាកសួរថា តើមានភាពបង្ខំ ឬក៏អត់នោះទេ។ ខ្ញុំ<>បានសិក្សា<ស្រាជ្រាវអំពីពាក់ព័ន្ធរបស់ពិន្ទុសាស្ត្រ ទៅនឹងរឿងរ៉ាវនេះ។ សំណួរនេះ គឺមិនសមស្របទៅនឹងវិធីសាស្ត្រដែលខ្ញុំបានប្រើប្រាស់នោះទេ។>។

[១០:០៤:៥៩]

**សៈ** បើខ្ញុំយល់មិនច្រឡំទេ អ្វីដែលៗធ្វើឱ្យលោកស្រីទាញការសន្និដ្ឋានថាការរៀបការនៅសម័យនោះមិនមែនជាការរៀបការដោយបង្ខំ ដែលនៅក្នុងបរិបទក្រៅច្បាប់នោះ គឺលោកស្រីចង់និយាយថាការរៀបការនោះ គឺការរៀបការតាមធម្មជាតិហើយត្រូវបានអនុញ្ញាត។ អ៊ីចឹងតើកត្តានេះហើយឬ ដែលនាំ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឲ្យលោកស្រីទាញការសន្និដ្ឋានថាជាការរៀបការដោយមិនបង្ខំនោះ?

**ឆ៖** នេះមិនមែនជាកត្តាតែមួយគត់ដែលវាឈានទៅដល់ការសន្និដ្ឋានរបស់ខ្ញុំនោះទេ។ មានកត្តាជាច្រើនទៀតដែលជាមូលដ្ឋាននៃការសន្និដ្ឋានរបស់ខ្ញុំ។

**ស៖** ខ្ញុំចង់សូមឲ្យលោកស្រីរៀបរាប់អំពីកត្តាផ្សេងទៀតផងដែរ។ អ៊ីចឹងលោកប្រធាន ខ្ញុំសូមពីរនាទីទៀតលោកប្រធានដើម្បីបន្ថែមពេល។ ខ្ញុំភ្លេចទៅហើយលោកប្រធាន មិនដឹងថាខ្ញុំមានពេលវេលាប៉ុន្មានទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<>យើងបានផ្តល់ពេលវេលាបន្ថែមទៅដល់ភាគីទាំងសងខាងរួចមកហើយ ហើយបានន័យថាម្នាក់ៗគឺបានប្រហែលជាកន្លះម៉ោងបន្ថែមទៀត ដូចជាយើងបានបញ្ជាក់រួចហើយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

អ៊ីចឹងសូមអរគុណ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដើម្បីបញ្ជាក់ឲ្យបានច្បាស់ ពេលវេលានេះ គឺសម្រាប់ភាគីទាំងសងខាងទៅដល់អាហារថ្ងៃត្រង់ ហើយខ្ញុំមិន<ចាំ>ថាខាងមេធាវី នួន ជា <នៅសល់ពេលវេលាប៉ុន្មានឲ្យជាក់ច្បាស់>នោះទេ។ <ខ្ញុំគិតថា មានតែពីរបីនាទី។>

**លោក វ៉ិចទ័រ កូប៉េ៖**

ជាការពិតខាង ខៀវ សំផន នេះគាត់កំណាញ់បន្តិច។ <ប៉ុន្តែខ្ញុំជឿថា>យើង<អាចសួរចប់ក្នុងរយៈពេល>កន្លះម៉ោង <ហើយពេលវេលានៅសល់ប៉ុន្មាន គឺសម្រាប់ខាងក្រុមមេធាវីលោក> ខៀវ សំផន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ក៏ប៉ុន្តែលោកមិនមានពេលវេលាច្រើននោះទេ ពីព្រោះម៉ោង>បន្ថែមនោះ <គឺមានតែមួយវគ្គទេ។ ហេតុដូច្នេះហើយបានជាខ្ញុំសួរលោក។> គឺយើងបានផ្តល់កន្លះម៉ោងបន្ថែមទៅដល់ក្រុម<មួយៗ> ហើយបើសិនជាគិត<ចាប់តាំងពីវគ្គចាស់> គឺថាលោកមានតែពីរបីនាទីតែប៉ុណ្ណោះ។ <នេះគឺជាការគណនាពេលវេលា។>

**លោក វ៉ិចទ័រ កូប៉េ៖**

<គាត់ចប់នៅម៉ោងដប់ ដូច្នេះ>ចំពោះខ្ញុំ គឺថា ខ្ញុំគិតថា <ខ្ញុំមានរយៈពេល១០នាទី ពីវគ្គមុន ហើយបន្ទាប់មក គឺមានរយៈពេល> ២០<>នាទី<ផ្សេងទៀត ខ្ញុំសង្ឃឹមអ៊ីចឹង>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើច្បាស់ដែរហើយឬនៅភាគីទាំងអស់?

[១០:០៧:៣១]

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកស្រីចៅក្រមឥឡូវខ្ញុំបន្តសួរសំណួរទៀត ឬក៏សម្រាកសិនលោកប្រធាន ពេលចូលចេញ ចូលពីសម្រាកវិញបានត្រូវសួរបន្ត?

**ស៖** ឥឡូវដោយខ្លីដើម្បីឲ្យច្បាស់ទាំងអស់គ្នាលោកស្រីអ្នកជំនាញ លោកស្រីនិយាយថាដោយ-សារមានយថាភាព មានលក្ខណៈធម្មជាតិនៃពិធីការនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង លោកស្រីនិយាយថានេះជាដោយសារកត្តាទាំងអស់នេះហើយ ដែលលោកស្រីទាញការសន្និដ្ឋានថាជាការរៀបការដោយមិនមានការបង្ខំ។ អ៊ីចឹងមានកត្តាអីផ្សេងទៀតដែរឬទេ? កត្តាអីខ្លះទៅ?

**កញ្ញា ផេហ្គី ឡឺវ៉ាញ៖**

**ឆ៖** កត្តា<សំខាន់មួយ> គឺកត្តាទំនាក់ទំនងជាសំខាន់។ បានន័យថាប្រជាជនបានទទួលការទទួលស្គាល់ពីសមាជិកគ្រួសារ ឬក៏ពីអ្នកដែលគាត់មានទំនាក់ទំនង ថាពួកគាត់នឹងទៅចូលរួមអាពាហ៍ពិពាហ៍ដែលអនុញ្ញាតឲ្យពួកគាត់ប្រកាស និងប្ដេជ្ញាពេលនោះ ថាពួកគាត់នឹងក្លាយជាគូស្រករហ្នឹងគ្នា។ ចម្លើយភាគច្រើនលើសលប់គឺបានបង្ហាញអំពីភាពធូរស្បើយរបស់ពួកគាត់ ដែលនេះវាស្ថិតនៅក្នុងបរិបទមួយផ្សេង។ ខ្ញុំដឹងថានៅសៀវ៉ាឡេអូនជាបរិបទមួយដោយឡែក តែខ្ញុំលើកឡើងតែពីបរិបទនៅទីនេះតែប៉ុណ្ណោះ គឺសេចក្ដីធូរស្បើយ។ កត្តាដែលធ្វើឲ្យគាត់ធូរស្បើយនេះ គឺជាកត្តាមួយធំធេង។ ខ្ញុំបានពិនិត្យមើលទៅលើនិយមន័យនៃអាពាហ៍ពិពាហ៍ ឬការរៀបការ។ អត្ថន័យនៃការរៀបការចំពោះក្រុមដែលខ្ញុំធ្វើការសិក្សាស្រាវជ្រាវពួកគាត់លើកឡើងថាពួកគាត់មានភាពធូរស្បើយ។ គាត់មិនមានការគំរាមកំហែង ហើយការភ័យខ្លាចរបស់គាត់មានភាពថយចុះ។ ដូច្នេះហើយវាគាត់លើកឡើងថាវាពាក់ព័ន្ធទៅនឹងជីដូនជីតារបស់គាត់។ អ៊ីចឹងកត្តានេះគឺជាកត្តាមួយធំធេង ខ្ញុំជឿជាក់ថា ដូច្នេះហើយទើបម្សិលមិញនោះ ខ្ញុំបានប្រតិកម្មទៅលើពាក្យថា "ស្ត្រីកំដរអារម្មណ៍"។ នេះវាបង្ហាញនូវស្ត្រី អារម្មណ៍របស់ស្ត្រី ក៏ប៉ុន្តែវាមិន

មែនជាការបញ្ជាក់មួយជាក់ស្ដែងនោះទេ។ ដូច្នេះហើយកត្តាទាំងនេះហើយ ដែលជំរុញឲ្យខ្ញុំទាញសេចក្ដីសន្និដ្ឋានមួយជាក់លាក់។

[១០:១០:២៨]

ហើយលើសពីនេះទៀត គ្មាននរណាម្នាក់បានប្រាប់ខ្ញុំមានប្រជាជនលើកឡើងថា ពួកគាត់ភ័យខ្លាចថាពួកគាត់នឹងទទួលរងការធ្វើបាបនោះទេ ប្រសិនបើពួកគាត់មិនរៀបការជាមួយនឹងបុគ្គលជាគូស្រកររបស់ពួកគាត់ ហើយក៏មិនមានគេប្រាប់ថាពួកគេប្រាកដជាត្រូវបានគេបញ្ជូនទៅធ្វើការដោយបង្ខំប្រសិនបើមិនរៀបការ<។ នេះគឺជាករណីជាក់ស្ដែង។ វាមិនមែនជាសេចក្ដីស្លាប់ពិតប្រាកដនោះទេ គឺមានគេនិយាយច្រើនណាស់ថា៖>"ខ្ញុំឮគេ<ថា ឬនរណាម្នាក់បាន>ប្រាប់ខ្ញុំ <ឬ>ម្ដាយរបស់ខ្ញុំ<និយាយថា>" ក៏ប៉ុន្តែប្រសិនបើយើងពិនិត្យមើលវិញ ការគំរាមកំហែងដោយផ្ទាល់ចំពោះក្រុមដែលខ្ញុំធ្វើការសិក្សាស្រាវជ្រាវនោះ គឺអត់ទេ អត់មានទេ។ <ខ្ញុំជឿថា អ្នកផ្សេងទៀត>ប្រហែលជាមាន<។ ខ្ញុំចង់មានន័យថា នៅពេលដែលអ្នកមើលទៅលើក្រុមប្រជាជនជាទូទៅនោះ វាមិនអាចថាមិនមាននោះទេ>។ នៅក្នុងក្រុមដែលខ្ញុំសិក្សាស្រាវជ្រាវ គាត់មិនទទួលបាននូវ គាត់មិនទទួលនូវការគំរាមកំហែងដោយផ្ទាល់នោះឡើយ។ ហើយចំពោះកត្តាស្ដីពីការភ័យខ្លាច ខ្ញុំត្រូវតែលើកឡើងអំពីការភ័យខ្លាចទៅលើអង្គការដែលវាកើតឡើងនៅពេលនោះ។ គឺការភ័យខ្លាចនេះកើតឡើងចេញពីអង្គការដែលគិតថា អង្គការនោះមានវត្តមាននៅគ្រប់ទីកន្លែងទាំងអស់។ ក៏ប៉ុន្តែចំណុចនេះដូចជាហាក់លាក់ ជាលក្ខណៈមួយបោកបញ្ឆោតនិងបន្លំតែប៉ុណ្ណោះ។

[១០:១១:៥៤]

**ស៖** បាទ នេះជាមានប្រយោជន៍ណាស់អ្វីដែលលោកស្រីបានពន្យល់ ហើយដែលពន្យល់អំពីខ្លឹមសារនៃការរៀបការដោយបង្ខំនេះ។ ខ្ញុំសូមចូលទៅការផលប៉ះពាល់រយៈពេលវែង។ អ្វីដែលលោកស្រីសរសេរនៅទំព័រទី៣២ និង៣៣ នៃសៀវភៅរបស់លោកស្រីនោះ លោកស្រីបាននិយាយអំពី ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។ លោកស្រីនិយាយដូចតទៅនេះ ពីផលប៉ះពាល់រយៈពេលវែង ដែលលោកស្រីបានសង្កេតឃើញនៅក្នុងទំព័រ៣២ និង៣៣ ដូចតទៅនេះ ខ្ញុំសូមអភ័យទោសដែលខ្ញុំលោតពីភាសាបារាំងទៅអង់គ្លេស អង់គ្លេសទៅបារាំងនេះជាញឹកញាប់។ "គាត់ជាប្រជាជនកម្ពុជា ដែលខ្ញុំសម្ភាសបានរស់រានមានជីវិត។ ក៏ប៉ុន្តែម្នាក់ៗបានបង្ហាញនូវការមិនមានការវិវឌ្ឍខ្លួន វាខុសពីប្រភេទនៃជំងឺបាក់ស្បាត។ ឧទាហរណ៍ វិធីដែលស្ត្រីនិងបុរសលើកឡើងអំពីការភ័យខ្លាចរបស់ពួកគេ ហើយថាតើពួកគាត់

ហ្នឹងពាក់ព័ន្ធទៅនឹងព្រលឹងនៅជុំវិញខ្លួនរបស់ពួកគាត់យ៉ាងដូចម្ដេចនោះ គឺជាទូទៅវាមានគុណភាព ឬក៏មានទិដ្ឋភាពនូវភាពដែលគាត់មានភាពច្របូកច្របល់នៅក្នុងជីវិតរបស់គាត់។”

អ្វីដែលលោកស្រីបានសង្កេតឃើញនេះ លោកស្រីអាចអត្ថាធិប្បាយជូនចៅក្រមបានដែរឬទេ? តើលោកសង្កេតឃើញ លោកស្រីសង្កេតឃើញចំណុចទាំងអស់នេះជាញឹកញាប់ដែរឬទេ នៅចំពោះអ្នកដែលបានឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យនេះ?

**ឆ៖** ជាការពិត មិនថាពួកគាត់រៀបការ ឬក៏មិនរៀបការនោះទេ <វាគឺជារឿងស៊ីជម្រៅ>។

[១០:១៥:២២]

**ស៖** នៅក្នុងសៀវភៅរបស់លោកស្រីនេះ លោកស្រីនិយាយអំពីការរីកលូតលាស់យឺត ការទុកចិត្តរបស់ខ្លួនឯង វាមានយឺតទៅ ដូចថាមានតិច កម្រមាន។ <ហើយ>លោកស្រី<បាន>ពន្យល់<ពីរបៀបដែលរបបកម្ពុជាប្រជាធិបតេយ្យមានការប៉ះទង្គិចទៅលើភាពស្និទ្ធស្នាល។ ដូច្នេះ តើលោកស្រីអាចផ្ដល់ព័ត៌មានថែមទៀត>ជូនតុលាការបានដែរឬទេ ដែលពីផលប៉ះពាល់ហ្នឹង វាធ្វើឱ្យខ្លួនឯងហ្នឹងទុកចិត្តនឹងខ្លួនឯងហ្នឹងកម្រនឹងទុកចិត្តនឹងខ្លួនឯង?

**ឆ៖** តាំងពីដើមដំបូងមក យើងឃើញមានគម្លាតធំ រវាងអ្នកដែលគាត់<អាច>រស់នៅក្នុងជីវភាពសាមញ្ញធម្មតា <នៅក្នុងបរិបទប្រទេសកម្ពុជា គឺការអភិវឌ្ឍជីវិត>។ អ្វីដែល<មានសរសេរច្រើននៅក្នុងឯកសារពាក់ព័ន្ធនឹង>ជំងឺ*ត្រូម៉ា* ឬបាក់ស្បាតនេះ <វាគឺជាបទពិសោធន៍>អារម្មណ៍របស់បុគ្គលខ្លួនឯង <សេចក្ដីត្រេកអររបស់បុគ្គលម្នាក់ និងការផ្លាស់ប្ដូរអារម្មណ៍រវាងមនុស្ស។ ដូច្នេះ>នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកទាំងអស់នោះ គឺនិយាយ<ប្រាប់ខ្ញុំច្បាស់ណាស់។ រឿងរ៉ាវទាំងនោះបានលេចជារូបរាងដល់ខ្ញុំ ប្រាកដណាស់ គឺពួកគាត់និយាយប្រាប់ខ្ញុំច្បាស់ណាស់ ហើយ>ពួកគាត់យំ និងរន្ធត់ក្នុងចិត្តញាប់ញ័រខ្លួន <ជាញឹកញាប់>។ ហើយ<>ក្រោយមក ខ្ញុំបាន<ទៅប្រឹក្សាជាមួយពេទ្យវិលកចរិត ដើម្បីឱ្យប្រាកដច្បាស់ថានឹងទៅជួបពួកគេនៅ>ថ្ងៃបន្ទាប់ ដោយសារ<តែខ្ញុំដឹងថា>ពួកគាត់<អាចនឹងយល់សប្ដិ>។ ដូច្នេះ<ធាតុផ្សំនៃរបស់នោះ គឺវាមាននៅជុំវិញភាពមិនប្រក្រតីនៃរូបរាងកាយរបស់មនុស្ស>។ ខ្ញុំមិនបាននិយាយអំពី<សេចក្ដីស្លាប់នោះទេ> ក៏ប៉ុន្តែខ្ញុំនិយាយអំពីជីវិតរស់នៅ។ <ដូច្នេះវាគឺជាសមត្ថភាពរបស់បុគ្គលម្នាក់ សិទ្ធិរបស់បុគ្គលម្នាក់ គឺអំពីសិទ្ធិមនុស្សក្នុងការទទួល> ពិសោធន៍<នូវអារម្មណ៍ត្រេកអររបស់បុគ្គលខ្លួនឯង គឺនិយាយអំពីការរួមភេទ។ វា>ពាក់ព័ន្ធទៅនឹង <បទពិសោធន៍នៃអារម្មណ៍សប្បាយរីករាយ> ការស្ទាបអង្អែល ក្លិន ហើយនិងសំឡេងជាដើម។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<របស់>ទាំងអស់ហ្នឹង គឺ<ត្រូវបានដកហូតពី>ប្រជាជន។

[១០:១៥:៤៩]

**ស៖** ខ្ញុំសូមសួរសំណួរបន្តទាក់ទងនឹងទំព័រ៣៥ នៃសៀវភៅរបស់លោកស្រី។ លោកស្រីបាននិយាយអំពីការស្ងៀមស្ងាត់។ នៅថ្ងៃទី១ ដែលលោកស្រីមកផ្តល់សក្ខីកម្មនេះ លោកស្រីនិយាយថា កាលណាយើងនៅស្ងៀមហ្នឹងជាយុទ្ធសាស្ត្រនៃការត្រដររស់នៅទំព័រទី៣៥។ អ៊ីចឹង ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសតែម្តង៖ "តើរយៈពេល៤ឆ្នាំ ដែលនៅស្ងៀមស្ងាត់នេះ វាប៉ះពាល់ដល់មនុស្សយ៉ាងម៉េចខ្លះ ហើយសញ្ញាណនៃពេលវេលា និងលំហ ឬក៏ទីកន្លែងនេះ គាត់យល់យ៉ាងម៉េច?"។ អ៊ីចឹងលោកស្រីអាចពន្យល់បានដែរឬទេថា ការដែលមនុស្សទាំងអស់នៅស្ងៀមស្ងាត់ហ្នឹង វាមានផលប៉ះពាល់យ៉ាងម៉េចខ្លះទៅលើប្រជាជនខ្មែរ ដែលរស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង?

**ឆ៖** ពាក្យថា "ភាពស្ងៀមស្ងាត់<" រក្សាភាពស្ងៀមស្ងាត់រវាងខ្ញុំ និងអ្នក និងរក្សាភាពស្ងៀមស្ងាត់នៅក្នុងខ្លួន និង>ធ្វើឲ្យអារម្មណ៍ខ្លួនឯង<ស្ងៀមស្ងាត់ គឺជាការស្ងៀមស្ងាត់បីខុសៗគ្នា។ ឥឡូវនេះ> ខ្ញុំ<ត្រូវតែ>លើកឡើងអំពីអាពាហ៍ពិពាហ៍ និងការរៀបការ <ពីព្រោះអ្វីដែលខ្ញុំត្រូវបានប្រាប់ដោយ>គូស្រករ <និងដោយ>អ្នកដែលរៀបការនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ថាតើពួកគេនៅជាមួយគ្នារហូតមក ឬ<ក៏អត់នោះ បើទោះបីជាចំនួនភាគច្រើននៃក្រុមមនុស្សដែលខ្ញុំបានសិក្សាស្រាវជ្រាវនោះ គឺបន្តរស់នៅជាមួយគ្នារហូត។ វាមិនមែនជា>លក្ខណៈវិនិច្ឆ័យមួយ <ដែលខ្ញុំស្វែងរកនោះទេ។> នៅពេលដែលមនុស្សវិវត្តន៍<សម្ព័ន្ធភាព> ជាមួយបុគ្គលមួយទៀត ដែលត្រូវបានរៀបចំឲ្យរៀបការជាមួយនឹងខ្លួន ដំបូងចំពោះមនុស្សមួយចំនួន ពួកគាត់យល់ថាគាត់មានសុវត្ថិភាពក្នុងការនិយាយរឿងរ៉ាវទាំងឡាយដែលពួកគេ <ជាធម្មតា មិន>និយាយ<អំពីរឿងហ្នឹងឡើយ។ ដូច្នេះ នេះគឺជារឿងមួយ>។

[១០:១៨:៥៧]

ចំណុចទី២ ភាពសំខាន់នៃការរៀបការដែលខ្ញុំបានរកឃើញ។ ខ្ញុំមិនបង្កើតអំពីតុល្យភាពរវាងភាពវិជ្ជមាននិងអវិជ្ជមាននោះទេ ក៏ប៉ុន្តែអ្វីដែលខ្ញុំស្វែងយល់នោះ ថាតើអ្នកទាំងអស់នោះគាត់មានសមត្ថភាពនៅក្នុងក្រុមដែលខ្ញុំសិក្សាស្រាវជ្រាវនោះ មានទំនាក់ទំនងរហូត មានអាចប៉ះពាល់គ្នា រហូតដល់ដំណាក់កាលចុងក្រោយដែរឬទេ? នេះជាចំណុចមួយសំខាន់សម្រាប់អ្នកទាំងអស់នោះ។

**ស៖** ខ្ញុំសូមអរគុណ។ អ៊ីចឹងសំណួរចុងក្រោយដើម្បីបញ្ចប់ នៅក្នុងសៀវភៅរបស់លោកស្រីៗ

បាននិយាយអំពីការភ័យខ្លាចរបស់បុគ្គលមួយចំនួនដែលលោកស្រីបានសម្ភាស។ ពួកគាត់ខ្លាចអង្គការត្រឡប់មកវិញនៅពេលណាមួយ។ អ៊ីចឹងលោកស្រីអាចពន្យល់ជូនតុលាការបានដែរឬទេ អំពីការភ័យខ្លាច ដែលពួកគាត់បានឆ្លងកាត់នោះ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែលគាត់ភ័យខ្លាចថា អង្គការត្រឡប់មកវិញនៅពេលណាមួយនោះ ពន្យល់ សូមលោកស្រីពន្យល់ជូនតុលាការបន្តិចមកមើល?

**ឆ៖** ខ្ញុំបានសម្ភាសនេះ បែបនេះនៅក្នុងខ្សែភាពយន្ត <ដែលវាគឺជាកិច្ចសម្ភាសដ៏ស៊ីជម្រៅមួយ។ គឺគូស្រករមួយគូ បាននិយាយថា> ពួកគាត់រស់នៅជាមួយគ្នាដោយសារតែគូព្រេង។ <វាគឺជាលើកទី១ ដែលខ្ញុំបានឮអំពីពាក្យថា> គូព្រេងនេះ គឺ<ព្រះពុទ្ធបានរៀបចំអាពាហ៍ពិពាហ៍របស់យើង> តាំងពីពេល<យើង>មិនទាន់កើត <ដែលវាផ្ទុយពី គូកម្ម គឺជាការជួបគ្នាមិនល្អ>។ ខ្ញុំត្រូវតែលើកឡើងអំពីបរិបទនៃការសម្ភាសដែលខ្ញុំបានធ្វើឡើងនៅពេលនោះ <ពីព្រោះខ្ញុំគិតថា វាមានសារៈសំខាន់ក្នុងការ>ឆ្លើយតប<ទៅនឹង>សំណួរ<ពីមុន>របស់លោកស្រី។ ការសម្ភាសមួយដែលខ្ញុំសម្ភាសគូ<ស្រករ>មួយគូ <មុនពេលដែលខ្ញុំសម្ភាស>ដោយឡែកពីគ្នា<។ ខ្ញុំបានសម្ភាសគូស្រករមួយគូ ហើយយើងបាន>បានជជែកគ្នាយូរ ជាពិសេសរវាងពាក្យថា “គូព្រេង” និង “គូកម្ម”។ ពេលនោះវាល្ងាចណាស់ទៅហើយ ហើយវាងងឹត ហើយនៅពេលដែលមេឃកាន់តែងងឹត យើងកាន់តែមានភាពភ័យខ្លាច យើងកាន់តែមានភាពភ័យខ្លាច វាជាកំហុសមួយខ្ញុំផងដែរដោយសារខ្ញុំសម្ភាសរហូតទៅដល់ពេលយប់ យូរមែនទែន។ <កិច្ចសម្ភាសនោះធ្វើឡើងយូរណាស់ ហើយពួកគាត់ចង់និយាយប្រាប់ខ្ញុំអំពីរឿងរ៉ាវជាច្រើនរហូតដល់មេឃងងឹត។> បុគ្គលហ្នឹងគាត់និយាយភាគច្រើនអំពីបទពិសោធន៍របស់គាត់ ឬក៏រូបកាយរបស់គាត់នៅពេលដែលគាត់ឃ្លាន។ ខ្ញុំមានរូបគំនូរព្រាងនៅក្នុងសៀវភៅរបស់ខ្ញុំ <អំពីបុគ្គលហ្នឹង។ ខ្ញុំបានគូសរូបតុកកែ ដោយសារតែ>គាត់បានលើកឡើងថា គាត់<មានអារម្មណ៍នៅពេលនោះ> ហាក់ដូចជា<បង្គួយមួយដែលកំពុងតែវានៅលើដីដោយសេចក្ដីឈឺចាប់>។ ដូច្នេះកិច្ចសម្ភាសន៍ហ្នឹង <គឺធ្វើឡើងពេញមួយថ្ងៃ ហើយទីកន្លែងចាប់ផ្ដើម>ងងឹត <>ខ្លួនរបស់គាត់ចាប់ផ្ដើមញ័រ។ ដូច្នេះ ខ្ញុំឈប់សម្ភាសជាលក្ខណៈផ្លូវការដើម្បីងាកមកជាការជជែកលក្ខណៈសាមញ្ញា បានន័យថាមានការហូបតែនិងទឹកមកវិញ <ដូចជាប្រជាជនសាមញ្ញធម្មតាធ្វើ។ ក៏ប៉ុន្តែនៅពេលបញ្ចប់កិច្ចសម្ភាសនោះ គឺ>មុនពេលដែលខ្ញុំអាចបន្តៗកិច្ចសម្ភាសន៍ជាផ្លូវការទៅមុខទៀត <គឺថាគាត់បាននិយាយឃ្លាមួយដែលខ្ញុំគិតថាវាមានសំខាន់ណាស់ គឺ>នៅពេលដែលគាត់យោងលើកឡើង<ថា “>អង្គការ<>អាចងើបពីដីមកនៅគ្រប់ពេលវេលា <ហើយសូម្បីតែសព្វថ្ងៃនេះ>យើងមិនមានសុវត្ថិភាពនោះទេ<”>។ ដូច្នេះ<ខ្ញុំគិតថា អ្វី

01365407



ដែលមានឥទ្ធិពលនៅត្រង់នេះ គឺជាញឹកញាប់មិនត្រូវបានលើកឡើងនៅក្នុងឯកសារ>ដែលនិយាយអំពី *ត្រូម៉ា* – ការបាក់ស្បាត <នោះទេ។ ជាពិសេសនោះ គឺ>ភាពពាក់ព័ន្ធគ្នារវាងនឹងអរូបិយ ភាពអរូបិយ និងភាពរូបិយ <នៅក្នុងជីវិតរស់នៅរបស់យើង>។

[១០:២៣:១៩]

កិច្ចសម្ភាសន៍ផ្សេងទៀតដែលខ្ញុំបានធ្វើឡើង គឺវាមានកត្តាមួយដែលវាខុសពីកត្តានៃភាពងាយរងគ្រោះ ពាក្យ<ថា> “ភាពងាយរងគ្រោះ” នេះ នៅក្នុងភាសាខ្មែរហាក់ដូចជាមិនមានពាក្យបកប្រែត្រឹមត្រូវសមរម្យ។ បទពិសោធន៍<នៃការខូចខាតធ្វើបាបខ្លាំងក្លាទៅលើមនុស្សជាច្រើន គឺខ្ញុំគិតថា វាមានទំហំ>ធំធេង<ណាស់។ ដូច្នេះនៅពេលដែលរឿង>កើតឡើងនៅក្នុងបរិយាកាស<នយោបាយ គឺ>វាមានផលប៉ះពាល់<មួយដោយឡែក>ទៅលើ<ប្រជាជន ដែលរឿងទាំងអស់នោះអាចកើតឡើងម្តងទៀត ហើយ>ពួកគាត់អាចគិតថាអង្គការនឹងត្រឡប់មកវិញគ្រប់ពេលវេលាទាំងអស់នោះដែរទេ<។ វាគឺជារឿងដែលស៊ីជម្រៅណាស់>។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមអរគុណលោកស្រីអ្នកជំនាញដែលបានឆ្លើយនឹងសំណួរខ្ញុំ។

សូមអរគុណលោកប្រធាន ដែលអនុញ្ញាតឲ្យខ្ញុំបញ្ចប់ការសួរចម្លើយទៅលោកអ្នកជំនាញនេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ុះុះ<នេះគ្រាន់តែជា>សំណួរ<ខ្លីពាក់ព័ន្ធនឹងការគ្រប់គ្រងរៀបចំប៉ុណ្ណោះ ពីព្រោះខ្ញុំចង់ឲ្យអង្គជំនុំជម្រះមានលទ្ធភាពក្នុងការគណនាចំនួននាទី នៅអំឡុងពេលសម្រាក។ ជាការពិត> យើងដឹងហើយថាពេលវេលាបន្ថែមបានប្រើប្រាស់ហើយ តើមានសំណួរបន្ថែមចង់សួរពីខាងសហព្រះរាជអាជ្ញាទៀតដែរឬទេ? ឬក៏មានសំណួរបន្ថែមពីខាងដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ បើសិនមិនដូច្នោះទេ គឺខ្ញុំនឹងផ្តល់ពេលវេលា<ដែលនៅសេសសល់ គឺវាមិនមានច្រើនប៉ុន្មានទេ បើសិនមិនរាប់បញ្ចូលពេលវេលាសម្រាកនោះ គឺ>យើងនឹងផ្តល់ពេលវេលា<ឲ្យ>ខាងមេធាវីការពារក្តីទាំងអស់តែម្តង<>។

**លោក នីកូឡាស គូមជែន៖**

តើខ្ញុំអាចឆ្លើយតបក្រោយពេលសម្រាកបានដែរឬទេ? ប្រហែលជាយើងខ្ញុំត្រូវការប្រហែលជា ១០នាទីទៀត លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

តាមពេលវេលាដែលបែងចែកឱ្យគឺអស់ហើយ ភាគីខាងសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខអស់ហើយ។ សហព្រះរាជអាជ្ញាពីរវគ្គសវនាការ បូកជាមួយនឹង១៥នាទី អំមិញនេះគឺមួយវគ្គបូកជាមួយ១៥នាទី។ ដូច្នេះពេលវេលាសម្រាប់ភាគីនេះអស់ហើយ ដូច្នេះអង្គជំនុំជម្រះមិនអនុញ្ញាតទេណ៎ះ!

បាទឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់អ្នកជំនាញរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឱ្យអញ្ជើញគាត់មកកាន់ផ្តល់ កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ ខ្វះដប់ប្រាំនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:២៥ នាទី ដល់ម៉ោង ១០:៤៥ នាទី)*

[១០:៤៥:00]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី ដើម្បីសួរសំណួរដេញដោលចំពោះអ្នកជំនាញ។

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្តីលោកស្រីអ្នកជំនាញ! ពេលវេលារបស់ខ្ញុំ គឺថាមានកម្រិត។ អ៊ីចឹងខ្ញុំព្យាយាមសួរគ្របដណ្តប់ទៅលើប្រធានបទឱ្យបានច្រើនតាមពេលវេលារបស់ខ្ញុំ។ ខ្ញុំសូមចាប់ផ្តើមសួរពាក់ព័ន្ធទៅនឹងសញ្ញាប័ត្របណ្ឌិតរបស់លោកស្រី នៅទំព័រទី១នៃសញ្ញាប័ត្របណ្ឌិតរបស់លោកស្រី គឺជាការទទួលបាន បំពេញលក្ខខណ្ឌពេញលេញក្នុងការទទួលបានសញ្ញាប័ត្របណ្ឌិតនេះ។ លោកស្រីក៏បាននិយាយអំពី

ឈ្មោះ ដេវីដ ឆេនដ៍ល័រ ថាជាទីប្រឹក្សាចម្បងរបស់លោកស្រី<។ ហើយ>លោកស្រី<ក៏បាននិយាយអំពីគាត់ផងដែរ កាលពីពីរ>ថ្ងៃមុននេះ។ តើ ដេវីដ ឆេនដ៍ល័រ គាត់ចូលរួមពាក់ព័ន្ធទទួលស្គាល់ថា លោកស្រីបានបំពេញគ្រប់លក្ខខណ្ឌទាំងអស់ដែរឬទេ មុននឹងទទួលបានសញ្ញាប័ត្របណ្ឌិតនេះ?

**កញ្ញា ផេហ្គី ឡឺវ៉ាញ៖**

**ឆ៖** <ដើម្បីបញ្ជាក់ឲ្យច្បាស់រឿងនេះ>ខ្ញុំ<បានចាប់ផ្ដើមរៀនថ្នាក់>បណ្ឌិតខ្ញុំនៅញូហ្សឺឡែន។ ខ្ញុំបានបំពេញពាក់កណ្ដាល ហើយបាន<ផ្លាស់>មកសកលវិទ្យាល័យម៉ូណាស្ហ<។ ខ្ញុំមានអ្នកត្រួតពិនិត្យការសិក្សាស្រាវជ្រាវចំនួនពីរនាក់> ដែលខ្ញុំមានសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ជា<អ្នកត្រួតពិនិត្យ>ចម្បង ហើយ<ម្នាក់ទៀត គឺ ម៉ារីកា វីកហ្សីអានី ដែលជានាយកនៃវិទ្យាស្ថាន>ម៉ូណាស្ហ <អាស៊ី>ផងដែរ ដែលអ្នកទាំងពីរហ្នឹងគាត់ជាអ្នកកំណត់<ថាអ្វីគ្រប់យ៉ាងគឺបានរៀបរយ>មុននឹងបញ្ជូននិក្ខេបបទរបស់ខ្ញុំជូនទៅគណៈកម្មាធិការ <ដើម្បីទទួលស្គាល់ គឺថាវាត្រូវតែរៀបរយ មុនពេលដែលគេបញ្ជូនទៅបរទេស គឺទៅអ្នកត្រួតពិនិត្យអន្តរជាតិ>។

[១០:៤៧:៤៦]

**ស៖** ខ្ញុំយល់ហើយ។ ខ្ញុំមិនដឹងថា តើទំនៀមទម្លាប់ស្ថាប័នសិក្សាអូស្ត្រាលីយ៉ាងណានោះទេ។ តើមានពេលណាមួយនោះវាមានភាពចាំបាច់ឲ្យលោកស្រីឡើងការពារទៅដល់វិធីសាស្ត្ររបស់លោកស្រីនៅចំពោះមុខអ្នកដែលផ្ដល់មូលនិធិសម្រាប់លោកស្រី <អ្នកឧបត្ថម្ភ ឬក៏>ចំពោះមុខអ្នកដទៃណាទៀតដែរឬទេ?

**ឆ៖** វាមានលក្ខណៈខុសពី<ប្រព័ន្ធសិក្សារបស់>អាមេរិក <ដែលខ្ញុំបានឆ្លងកាត់ គឺថាដំបូងអ្នកត្រូវការពារនិក្ខេបបទរបស់អ្នកនៅចំពោះមុខគណៈកម្មាធិការចំនួនប្រាំរូប>។ ប្រព័ន្ធសិក្សារបស់អូស្ត្រាលី គឺយើងត្រូវតែការពារនៅក្នុងបន្ទប់មួយជាមួយនឹង<អ្នកត្រួតពិនិត្យរបស់អ្នក និងអ្នកផ្សេងទៀតដែលមិនពាក់ព័ន្ធនឹងការធ្វើនិក្ខេបបទរបស់អ្នក ដើម្បីធ្វើការកែសម្រួលពិនិត្យឡើងវិញ> ហើយបន្ទាប់មកយើងធ្វើការលើបទបង្ហាញ<ជាសាធារណៈ> និងអ្នកដទៃទៀត<ដែលសិក្សាជំនាញផ្សេងៗ>នៅក្នុងសកលវិទ្យាល័យក៏មកស្ដាប់អំពីបទបង្ហាញនេះដែរ។ ហើយចុងក្រោយ គឺថា រួចរាល់ជាស្រេចដើម្បីបញ្ជូនទៅ<>ពិនិត្យជាចុងក្រោយ។ នៅក្នុង<ដំណាក់កាលនេះ>គឺថា វិធីសាស្ត្រ<ស្រាវជ្រាវ ចាំបាច់ត្រូវតែច្បាស់លាស់>។

**ស៖** តើនៅចុងបញ្ចប់ វិធីសាស្ត្ររបស់លោកស្រីហ្នឹង ត្រូវបានទទួលស្គាល់នូវគ្រប់ផ្នែក<>

ទាំងអស់ដែរឬទេ?

**ឆ៖** គឺទទួលស្គាល់គ្រប់ផ្នែកទាំងអស់។

**ស៖** ខ្ញុំគិតថា ហ្នឹងគឺវាដូចគ្នា<ទៅនឹងសេចក្ដីសន្និដ្ឋាន>ដែលលោកស្រី<ទាញ>នៅចុងបញ្ចប់នៃនិក្ខេបបទរបស់លោកស្រីុ<>?

**ឆ៖** ដោយសារថា អ្នកពិនិត្យអន្តរជាតិនេះ គឺជាអ្នកអះអាងថា គឺពិនិត្យមើលទៅលើវិធីសាស្ត្រទាំងអស់ហ្នឹង ក៏ដូចជាការវិភាគនៅទូទាំងនិក្ខេបបទ ហើយថា អ៊ូ ! ពេញគ្រប់គ្រាន់អាចទទួលសញ្ញាប័ត្របានហើយ។

[១០:៥០:០២]

**ស៖** <បាទ ខ្ញុំយល់អំពីរឿងនេះ ប៉ុន្តែខ្ញុំគ្រាន់តែចង់បានវាឱ្យមានជាកំណត់ត្រាប៉ុណ្ណោះ។> តើមានភាព<មិនស្របគ្នា>ណាមួយដែរទេរវាងអ្វីដែលលោកស្រីបាននិយាយ និងការពារវិធីសាស្ត្រ <និងសេចក្ដីសន្និដ្ឋានដែរឬទេ?>។ ម្យ៉ាងទៀត <ពាក់ព័ន្ធទៅនឹងនិក្ខេបបទរបស់លោកស្រី និង>អ្វីដែលលោកស្រីបានឆ្លើយនៅចំពោះមុខតុលាការពីរថ្ងៃកន្លះមកនេះ តើវាមានភាពចម្រូងចម្រាស ឬក៏ភាពខុសគ្នាអ្វីដែរឬទេ តាមការយល់ឃើញរបស់លោកស្រី?

**ឆ៖** មិនមានភាពខុសគ្នា។

**ស៖** សូមអរគុណលោកស្រី។ ឥឡូវខ្ញុំចូលទៅប្រធានបទថ្មីមួយទៀត។ នៅថ្ងៃដំបូងនេះហ្នឹង គឺលោកស្រីបាននិយាយអំពីបញ្ហារៀបការ។ លោកស្រីហៅការរៀបការនេះថា ជាប្រធានបទមួយដែល <ក្ដៅគគុក ហើយលោកស្រីបាននិយាយអំពី>ភាពតឹងតែងទៅលើប្រធានបទនេះ លោកស្រីបានលើកឡើង <គឺមានរបៀបវារៈកម្មវិធីមួយ ហើយលោកស្រីបានស្នាក់នៅរយៈពេលសមល្មមគួរសមដែរ> ដោយសារតែពេលវេលាវាខ្លី ក៏ប៉ុន្តែតើលោកស្រីអាចពន្យល់ឱ្យបានលម្អិតបន្តិចបានទេ លោកស្រីចង់មានន័យដូចម្ដេចចំពោះបញ្ហានេះ?

[១០:៥១:៥០]

**ឆ៖** នៅដើមដំបូងនៃការសិក្សារបស់ខ្ញុំ គឺថាមានអ្នកគេចាប់អារម្មណ៍ទៅលើប្រធានបទនេះ ហើយក៏មានអ្នក<ធ្លាប់នៅក្នុង>បន្ទប់សវនាការនេះ<ពីមុន> ក៏បាន<សន្ទនា>ជាមួយខ្ញុំ។ <និយាយឱ្យចំទៅ គឺលោកស្រី> ស្វូតហ្ស៊ីនស្គី ហ្នឹងក៏បាននិយាយជាមួយខ្ញុំ ហើយមេធាវី ស្វូតហ្ស៊ីនស្គី សួរខ្ញុំអំពីការសិក្សាស្រាវជ្រាវរបស់ខ្ញុំ។ ហើយក្នុងពេលនោះ <ខ្ញុំបានផ្ដល់នូវនិទ្ទាការរបស់ខ្ញុំ ជាជាងការផ្ដល់នូវ

សេចក្ដីសន្និដ្ឋាន គឺ>នៅពេលដែលខ្ញុំនិយាយគ្នានេះ មិនទាន់ឈានទៅដល់ការធ្វើសេចក្ដីសន្និដ្ឋាននៅឡើយទេ។ យើងបាន<ជួបគ្នា និង>ផ្ញើអ៊ីម៉ែលឆ្លើយឆ្លងគ្នា ហើយនៅក្នុងអ៊ីម៉ែលដែលឆ្លើយឆ្លងគ្នាអ្វីដែលខ្ញុំកត់សម្គាល់នោះគឺថា វាមាននិន្នាការមួយដែលចង់ជំរុញខ្ញុំឱ្យពិនិត្យមើលអំពីបញ្ហាអាពាហ៍ពិពាហ៍នេះ។ ហើយនៅក្នុងការផ្លោះប្តូរគំនិតយោបល់គ្នានេះ ខ្ញុំមានអ៊ីម៉ែលនៅទីនេះដែរ។ ខ្ញុំសូមអានតែអ៊ីម៉ែលរបស់ខ្ញុំតែមួយបន្ទាត់ទេ <ហើយខ្ញុំនឹងអានអ៊ីម៉ែលរបស់ខ្ញុំដែលផ្ញើទៅកាន់គាត់ ដោយសារតែខ្ញុំមិនមានការអនុញ្ញាតពីបុគ្គលផ្សេងទៀតនេះ ដើម្បី>អានអ៊ីម៉ែល<ឆ្លងឆ្លើយ>របស់គាត់ទេ។ អ៊ីចឹងខ្ញុំអានតែអ៊ីម៉ែលរបស់ខ្ញុំទេ។ ចុះថ្ងៃទី០៨ សីហា ២០០៨<។ អ្នកនរវិទូ គឺរក្សាទុកឯកសារគ្រប់យ៉ាង> ៖ "ខ្ញុំបានទទួល<>សេចក្ដីប្រកាសព័ត៌មាន<របស់អ្នក ហើយខ្ញុំនឹងឆ្លើយតបនៅក្នុងរយៈមួយ ឬពីរថ្ងៃបន្ទាប់>។ ខ្ញុំនិយាយតែចំពោះការសិក្សាស្រាវជ្រាវរបស់ខ្ញុំ ដែលខ្ញុំបានធ្វើ៨ឆ្នាំមកហើយ ប៉ុន្តែ<ខ្ញុំគិតថាការជំទាស់តវ៉ារបស់លោកស្រី ១០០ភាគរយនោះ គឺវា>មិនស៊ីសង្វាក់គ្នាទៅនឹងការ<រកឃើញ>របស់ខ្ញុំនោះទេ<។>ខ្ញុំអាច<មានទទ្បីករណ៍>ជំទាស់តតាំងនូវអ្វីដែលលោកស្រីលើកឡើងនៅក្នុងកថាខណ្ឌ៤<ប្រសិនបើលោកស្រីចង់បាន> ខ្ញុំអាចសរសេរឆ្លើយឆ្លងបាន<។ ការព្រួយបារម្ភរបស់ខ្ញុំនោះ គឺ>ទទ្បីករណ៍របស់លោកស្រី<ប្រហែលជានៅតែរក្សាជំហរខ្លាំងដដែល">។ វាមាននិន្នាការមួយ<ដែលខ្ញុំបានសរសេរឯកសារក្នុងតំបន់> ហើយខ្ញុំ<បានសរសេរច្រើនអំពីនិន្នាការទាំងអស់នោះ ហើយខ្ញុំបាន>និយាយឱ្យច្រើនអំពីការសិក្សាស្រាវជ្រាវរបស់ខ្ញុំ។ <វាគឺ>ជា<ឧទាហរណ៍មួយនៃ>ការផ្លោះប្តូរគំនិតយោបល់គ្នាដែលនាំឱ្យខ្ញុំ<ធ្វើការងារដាច់តែឯង។ ហើយវាងាយស្រួលក្នុងការយល់ឃើញ> នៅពេលដែលខ្ញុំផ្តល់ការសម្ភាស<នៅក្នុងប្រព័ន្ធ>សារព័ត៌មាន <នៅគ្រប់ពេល គឺប្រសិនបើមានទំព័រមតិយោបល់ គឺវានឹងមានប្រតិកម្មតបមួយឆ្លើយនៅក្នុងទំព័រមតិយោបល់នោះ>។ ដូច្នេះខ្ញុំគិតថា វា<គឺ>ជាប្រធានបទមួយ<ដែលរំជួលអារម្មណ៍។ ក៏ប៉ុន្តែ>បើសិនណា<ការរំជួលអារម្មណ៍នោះ> មិន<មែនជាការពិតជាក់ស្តែងនោះទេ វាមិនអាចបង្ហាញឱ្យឃើញអំពី>អ្វីដែលកើតឡើង <ដូចអ្វីដែលវាបានកើតឡើង>នោះទេ។

**សៈ** បាទ សំណួរខ្លីពាក់ព័ន្ធទៅនឹងបញ្ហានេះ លោកស្រីមានបានអានសារព័ត៌មាន មានអានកាសែតទេ ព្រឹកមិញនេះ?

**ឆៈ** ខ្ញុំអត់បានអានទេ។

[១០:៥៥:០៤]

**សៈ** ឥឡូវខ្ញុំសូមចូលទៅប្រធានបទមកទៀត គឺប្រធានបទស្តីអំពីគោលនយោបាយជាតិ។ យើង

បាននិយាយគ្នាតិចតួចអំពីគោលការណ៍<បដិវត្តន៍>ទាំង១២ <> ឬក៏សារៈសំខាន់នៃគោលការណ៍ទាំងនេះវាមានសារៈសំខាន់សម្រាប់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។

ម្យ៉ាងវិញ លោកស្រីត្រូវបានសហព្រះរាជអាជ្ញាសួរថា តើអៀង សារី បាននិយាយអ្វីខ្លះនៅក្នុងឆ្នាំ១៩៨០។ ហើយ<ក៏មានភស្តុតាងបង្ហាញថា> ប៉ុល ពត នោះក៏បាននិយាយអំពី<> គោលនយោបាយរៀបការនេះផងដែរ។ តើលោកស្រីមានបានដឹង <ប្រហាក់ប្រហែលអំពីអ្វីដែល> ប៉ុល ពត បាននិយាយនៅខែសីហា កញ្ញា ឆ្នាំ១៩៧៥ ទៅកាន់ប្រតិភូ ប៊ែលហ្ស៊ិក ដែរឬទេ?

**ឆ៖** សូមបញ្ជាក់ឡើងវិញ។

**ស៖** ឥឡូវ ខ្ញុំសូមបញ្ជាក់អំពីដែល ប៉ុល ពត បាននិយាយ។ លោកប្រធាន ខ្ញុំយោងទៅលើហ្វេប៊ីស របាយការណ៍ហ្វេសប៊ីស <E3/76>។ គាត់និយាយនៅថ្ងៃទី០៥ សីហា ឆ្នាំ១៩៧៨។ ERN ជាភាសាអង់គ្លេស 00170426, ខ្មែរ 01327012 មិនមានការបកប្រែជាភាសាបារាំងនៅឡើយទេ។ នេះគឺជាអ្វីដែល ប៉ុល ពត បាននិយាយ៖ "ក្នុងការកសាងគ្រួសារ យុវជន យុវនារីយើង គឺថាកសាងគ្រួសារដោយស្ម័គ្រចិត្ត។ ក្រោយការរៀបការ <ប្រសិនបើមានបញ្ហាកើតឡើងនៅក្នុងគ្រួសារ> គឺមហាជន នឹងផ្ដល់<ដំបូន្មាន>ទៅដល់គូភាគី ដើម្បីឲ្យដោះស្រាយ<បញ្ហា>របស់ពួកគេ។ បើសិនណា<ភាគីពាក់ព័ន្ធ>យល់ឃើញថា <មិនអាច>រួមរស់<នៅ>ជាមួយគ្នា<បានតទៅទៀត> ពួកគេអាចលះលែងគ្នាបាន។ <ភាគីដែលពាក់ព័ន្ធនោះ មិនចាំបាច់ឡើងទៅ>តុលាការ<ទេ>"។ តើលោកស្រីធ្លាប់ដែលឮ <សេចក្ដីដកស្រង់នេះនៃ>កិច្ចសម្ភាសន៍របស់ ប៉ុល ពត នេះ ជាមួយប្រតិភូប៊ែលហ្ស៊ិក ដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ឮ។

[១០:៥៨:២០]

**ស៖** ឥឡូវ យើងយកសម្ដីរបស់គាត់យកមកពិចារណាទាំងអស់គ្នា ពាក់ព័ន្ធទៅនឹងគោលការណ៍<>បដិវត្តន៍ <និងសារៈសំខាន់របស់វា> ហើយការអនុវត្តនេះ គឺការអនុវត្តតាំងពីទសវត្សរ៍៦០មកម្ល៉េះ។ សំណួររបស់ខ្ញុំ គឺសួរអំពីមូលហេតុ <ឬ> ភាពសមហេតុផលណាមួយ ពាក់ព័ន្ធទៅនឹង<ការចោទប្រកាន់>គោលនយោបាយនេះ។ បើសិនណា វាជាការពិត ដែលថា<>ទិសដៅរបស់បក្សកុម្មុយនីស្តកម្ពុជា គឺដើម្បីបង្កើនចំនួនប្រជាពលរដ្ឋ។ <ដូច្នេះ>តើវា<មិន>សមហេតុផល <និងផ្ទុយអំពីហេតុផល>ក្នុងការបង្ខំប្រជាជនឲ្យរៀបការ ពីព្រោះដោយសារ បើកាលណា គេបង្ខំប្រជាជនឲ្យរៀបការ <បង្កើតកូនចៅ បើតាមនិយមន័យធម្មជាតិ>នោះវាមិនមែនជាលក្ខណៈងាយស្រួលទេ <ឬក៏>វាពិបាក

ណាស់ <មិនអ៊ីចឹងឬ?> អ៊ីចឹងសំណួររបស់ខ្ញុំ <គឺមិនមែនពាក់ព័ន្ធ>គោលនយោបាយដែលលើកឡើង ដោយ ប៉ុល ពត នៅ<សីហា> ឆ្នាំ១៩៧៨ <នោះទេ។ ថាតើការថែងនៅក្នុងគោលការណ៍>បដិវត្តន៍ នោះ គឺជាគោលនយោបាយសមហេតុសមផល<មួយ ដែលមិនតម្រូវ>ការបង្ខំឲ្យមានការរៀបការណា មួយនោះដែរឬទេ?

**ផះ** ទី១ ខ្ញុំមិនដឹងថានេះគឺជាគោលនយោបាយ ឬក៏អត់ទេ <ប៉ុន្តែ>វាជាសេចក្តីថ្លែងការណ៍ សាធារណៈតែប៉ុណ្ណោះ។ <ខ្ញុំមានន័យថា វាគួរឲ្យចាប់អារម្មណ៍។> ខ្ញុំ<បានគិតអំពី>ក្រម<>បដិវត្តន៍ ហើយខ្ញុំក៏បានពិចារណាអំពី<ក្រមសីលធម៌>យេនឌ័រ ព្រោះខ្ញុំដឹងថាតួនាទី<នៃក្រមសីលធម៌របស់> ស្ត្រីហ្នឹងគឺថា ត្រូវបានលើកឡើងនិងត្រូវបង្ហាញ<នៅក្នុងតុលាការ គឺមាននិស្សិតថ្នាក់បណ្ឌិតម្នាក់> ដែល<បានបញ្ចប់ថ្នាក់>បណ្ឌិត<របស់គាត់នៅក្នុងខែកុម្ភៈ> ឆ្នាំ២០១៤ <គឺលោក សុក សុត នៅ សាកលវិទ្យាល័យរីកតូរៀរ ក្នុងទីក្រុងម៉ែលប៊ន។ គាត់បានសរសេរនិក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់ អំពី>ប្រធានបទ<--ដែលរួមបញ្ចូល>និយាយអំពីក្រមសីលធម៌សម្រាប់បុរសៗនោះផងដែរ។ ខ្ញុំក៏ពិនិត្យ មើលទៅលើក្រមសីលធម៌សម្រាប់បុរស <និងនៅពេលដែលខ្ញុំពិនិត្យមើលក្រមសីលធម៌>ស្ត្រី <គឺថា ចំណុចទាំងអស់នោះ ដើរស្របតាមគោលការណ៍បដិវត្តន៍មួយចំនួន> ជាពិសេសគឺការហាមឃាត់មិន ឲ្យមានអំពើផិតក្បត់។ <អ្វីដែលខ្ញុំអាចនិយាយនៅពេលនេះ គឺជាអ្វីដែល> ប៉ុល ពត បាននិយាយអំពី បញ្ហានេះ ដែលវាស្របគ្នាទៅនឹងគោលនយោបាយសំខាន់ៗ ដើម្បីឲ្យប្រជាជនមានទំនាក់ទំនងគ្នាបានល្អ ជាចម្បងសិន មុននឹងចូលទៅដល់ការរួមដំណេករវាងភាគីទាំងពីរនេះ។

**សះ** ខ្ញុំយល់ហើយអំពីបញ្ហានេះលោកស្រី។ ឥឡូវខ្ញុំសូមចូលទៅប្រធានមួយទៀត ដែលយើង បានពិភាក្សាគ្នាច្រើន ដែលភាគីដទៃបានសួរច្រើនមកហើយ <ប៉ុន្មានថ្ងៃកន្លងមកនេះ គឺ>និយាយអំពី បរិយាកាសនៃភាពភ័យខ្លាច ឬក៏និយាយអំពីបរិយាកាស<ជាទូទៅ>នៃការបង្ខិតបង្ខំ។ តើលោកស្រី យល់ស្របជាមួយខ្ញុំដែរឬទេដែលថា បើវាមានអត្ថិភាពនៃភាពភ័យខ្លាចក្នុងការរស់នៅជាប្រចាំថ្ងៃរបស់ បុរសស្ត្រី ដែលលោកស្រីបានសម្ភាសនោះ គឺវាអាស្រ័យទៅលើវិធីសាស្ត្ររបស់អាជ្ញាធរមូលដ្ឋាន ដូច ជាមេភូមិជាដើម។ គឺមានន័យថា អាជ្ញាធរមូលដ្ឋាននេះហើយជាអ្នកទទួលខុសត្រូវចម្បងសម្រាប់ ដែល ជាអ្នកបង្កើតឲ្យមានបរិយាកាសនៃភាពភ័យខ្លាចបែបនេះ។ តើលោកស្រីយល់ស្របជាមួយខ្ញុំទេ?

[១១:០២:៥៤]

**លោក នីកូឡាស គូមជែន៖**

សូមជំទាស់ទៅនឹងនេះ គឺថាវាលើសពីជំនាញរបស់អ្នកជំនាញរូបនេះហើយ។ លោកស្រី<មិនអះអាងថា គាត់ដឹងអំពីមន្ទីរសន្តិសុខ> អំពីបញ្ហាការចាប់ខ្លួន ឬក៏<រចនាសម្ព័ន្ធថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ។

**ចៅក្រម ក្លូឌា ហ្វេនស័៖**

ប្រហែលជាគួរសួរសំណួរបើកវិញ វាជាសមស្របជាង។ តើលោកស្រីមានអារម្មណ៍<ជឿជាក់ក្នុងការនិយាយប្រាប់>អង្គជំនុំជម្រះ <អ្វីដែលលោកស្រីគិតថាវាគឺជាមូលហេតុ ឬក៏អ្នកណាដែលទទួលខុសត្រូវចម្បង> មិននិយាយពីរឿងផ្លូវច្បាប់ទេ និយាយជា<បរិយាកាសភ័យខ្លាច ឬតើវានៅក្រៅវិសាលភាពនៃការសិក្សារបស់លោកស្រីដែរឬទេ? លោកស្រីបានប្រាប់អង្គជំនុំជម្រះថាមានបរិយាកាសភ័យខ្លាច។ នេះគឺជាអ្វីដែលខ្ញុំយល់អំពីលោកស្រី។ តើលោកស្រីមានអារម្មណ៍ស្រួល>ក្នុងនាម ក្នុងឋានៈជាអ្នកជំនាញ បើលោកស្រីថាមិនដឹង ក៏ឆ្លើយថាមិនដឹង។ តើលោកស្រីអាចជម្រាបជូនតុលាការបានទេថា បរិយាកាសនេះជាបរិយាកាសមួយ<នៃការភ័យខ្លាច >បង្ខិតបង្ខំ<ត្រូវបានធ្វើឡើងដែរឬទេ>? នេះគឺអ្វីដែលមេធាវីការពារក្តីចង់ដឹងហើយ <វាមិនមែនជាគំនិតយោបល់បែបទស្សនវិជ្ជានោះទេ ប៉ុន្តែថា> តើមានអ្នកណាទទួលខុសត្រូវចំពោះ<រឿងនេះ? តើលោកស្រីមានអារម្មណ៍ស្រួលក្នុងការផ្តល់ចម្លើយដោយផ្អែកទៅលើមូលដ្ឋាននៃកិច្ចការស្រាវជ្រាវរបស់លោកស្រីដែរឬទេ?>

[១១:០៤:២៣]

**កញ្ញា ផេហ្គី ឡឺវ៉ាញ៖**

**ឆ៖** ចាស មាន។ ដូច្នេះចម្លើយរបស់ខ្ញុំទាក់ទងទៅនឹងអាជ្ញាធរមូលដ្ឋាន ហើយនិងការភ័យខ្លាចនេះគឺថា អាជ្ញាធរមូលដ្ឋានហ្នឹង<បាននិយាយ>បំផ្លើស<អំពី>ការភ័យខ្លាច។ <សម្រាប់ខ្ញុំ នៅក្នុងកិច្ចស្រាវជ្រាវរបស់ខ្ញុំ រឿងដំបូងនោះ គឺសូមចាប់ផ្តើមអំពីបន្ទាត់>មូលដ្ឋាននៃការភ័យខ្លាចនេះ ពិតណាស់គឺថា វា<ស្ថិតនៅ>កម្រិតខ្ពស់ណាស់។ ឧបមាថា វាមានបន្ទាត់<មូលដ្ឋាននៃការភ័យខ្លាច>មួយកំណត់អ៊ីចឹង <គឺការនិយាយបំផ្លើសនោះនៅលើកម្រិតបន្ទាត់មូលដ្ឋាននៃការភ័យខ្លាចនោះ ឬប្រហែលជាវានៅក្រោមបន្តិចនៃបន្ទាត់មូលដ្ឋាននោះ ដែលវាអាស្រ័យទៅលើការប្រព្រឹត្តទៅលើ>ប្រជាជន<ពីសំណាក់> អ្នកដែលទទួលខុសត្រូវគ្រប់គ្រងទៅលើគាត់ហ្នឹង គឺអាជ្ញាធរមូលដ្ឋាននេះហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** សូមអរគុណ។ ខ្ញុំសូមសួរលោកស្រីបន្ថែមទៅលើពាក្យអង្គការ។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីជាមួយប្រជាជនដែលមកឆ្លើយនឹងសំណួររបស់លោកស្រីនោះ តើវាមាន<ប្រែប្រួលចំពោះ>ការយល់ឃើញ<អំពី>អង្គការនេះដែរឬទេ? ហើយនៅជាពិសេស <តើពេលណាមួយ>នៅក្នុងឆ្នាំ១៩៧៧ <គេយល់ឃើញយ៉ាងម៉េចដែរ?> តើមានការយល់ឃើញខុសគ្នាដែរឬទេពីអំឡុងពេលមួយៗ<ដែរឬទេ?> ដោយសារលោកស្រីឆ្លើយថា អ្វីៗទាំងអស់វាអាស្រ័យទៅលើពេលវេលា <និងទីកន្លែងជាដើម ថាតើវាក៏អនុវត្តដូចគ្នាផងដែរ>ពាក់ព័ន្ធទៅនឹងអង្គការនេះ<>?

**ឆៈ** គឺថាមានការយល់ឃើញខុសៗគ្នា។

**សៈ** តើការផ្លាស់ប្តូរនេះគឺផ្លាស់ប្តូរនៅពេលណាដែរ?

**ឆៈ** គឺនៅអំឡុងមុំឆ្នាំ១៩៧៧។

[១១:០៦:៤៨]

**សៈ** តើលោកស្រីមានបានដឹងអំពីសេចក្តីណែនាំរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាអំពីការប្រើប្រាស់ពាក្យ "អង្គការ" និង "បក្ស" ដែរឬទេ? លោកប្រធានខ្ញុំយោងលើឯកសារ E3/740, អង់គ្លេស 00305412, ខ្មែរ 00082731, បារាំង 00983932។ សេចក្តីណែនាំនេះនិយាយថា ក្នុងចំណោមបញ្ហាជាច្រើននោះគឺមានដូចតទៅនេះ គឺនេះគឺ សុន សេន <គឺជាអ្នក>ណែនាំបង្គាប់ទៅ<កងពល និង>កងវរសេនាធំ <និងមន្ទីរ>ឲ្យអនុវត្តន៍ចំពោះសេចក្តីណែនាំនេះ។ "ដូចដែលបានកត់សម្គាល់កន្លងមកហើយ សមមិត្តខ្លះនៅក្នុងអង្គភាពមួយចំនួនកំពុងតែ<>ច្របូកច្របល់ <ក្នុងការប្រើប្រាស់>ពាក្យ "អង្គការ" និងពាក្យ "បក្ស"។ ហើយនៅកន្លែងខ្លះគឺសមាសធាតុមិនល្អដែលលាក់ ខ្លាំងដែលលាក់ខ្លួន គឺបានប្រើប្រាស់ពាក្យអង្គការនេះខុសដើម្បីបន្លំ ហើយនិងបំផ្លិចបំផ្លាញបក្ស <និងបដិវត្តន៍>"។ ហើយមកខាងក្រោមនេះបន្តិច "<អាស្រ័យហេតុនេះ គណៈ>មជ្ឈិមបក្ស សូមបង្គាប់ទៅអាជ្ញាធរមូលដ្ឋាន ក្រសួងមន្ទីរ <និងអង្គភាព>ផ្សេងៗ ពាក្យអង្គការ ឬក៏បក្សនេះ ប្រើតែចំពោះ<អង្គភាពចាត់តាំង>តែប៉ុណ្ណោះទេ<មិនត្រូវ>ប្រើ<សម្រាប់បុគ្គលឡើយ">។ តើ<នេះគឺជាអ្វីដែល>ស៊ីសង្វាក់ទៅនឹង<ការ>ប្រែប្រួល <ដែលលោកស្រីបានធ្វើការអង្កេតនោះដែរ ឬទេ>?

[១១:០៨:៤៩]

**ឆៈ** អត់ទេ។

**សៈ** អ៊ិចឹងតើលោកស្រីអាចពន្យល់បានទេ លោកស្រីថា លោកស្រីកត់សម្គាល់ទៅឃើញមាន

ការប្រែប្រួលនោះ?

**ឆ៖** អ្នកដែលខ្ញុំសម្ភាស ២២ភាគរយ គឺថាអង្គការជាថ្នាក់ដឹកនាំ។ ៤៨ភាគរយ គឺថាជា <ជំនឿ និង>កម្លាំងដែល<ផ្លាស់ប្ដូរ ហើយ៣០ភាគរយ គឺ>អត់ដឹងថាអង្គការជាស្អីទេ<។ ហេតុដូច្នេះ ព័ត៌មានហ្នឹងមិនដល់៣០ភាគរយនោះទេ>។ ក៏ប៉ុន្តែនេះជាវប្បធម៌មួយខ្ញុំបានអះអាងនៅក្នុងនិក្ខេបបទរបស់ខ្ញុំ <ថាវាគឺជាការងារវប្បធម៌មួយដែល>ខ្មែរក្រហមមិន<ធ្វើ ឬមិនអាចធ្វើ។ ខ្ញុំគិតថា ពួកគេមានទំនួលខុសត្រូវចំពោះរឿងនេះ។ ប៉ុន្តែមានកត្តាមួយចំនួន ដែលខ្ញុំបានគូសបង្ហាញដំបូង>នៅក្នុងសៀវភៅរបស់ខ្ញុំដែរ នៅទំព័រ១៥៩ ដែលខ្ញុំបាន<គូសបង្ហាញលម្អិត>ពីដំណើរការ<ការងារផ្អែកលើវប្បធម៌> ដែលអនុវត្តន៍នៅក្នុងរបបនោះ។ គឺថា វាបានធ្វើឲ្យមានភាពតានតឹង <ការងារ>វប្បធម៌ <ដែលបានកើតឡើង ដោយសារវប្បធម៌កម្លាំងពលកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ>រីករាលដាលដុះឡើង។

**សៈ** ខ្ញុំ<ចង់>សួរបន្តពីចំណុចនេះ <ប៉ុន្តែ>ខ្ញុំមានពេលវេលាខ្លី <ដូច្នេះខ្ញុំសូមចូលទៅ>សំណួរចុងក្រោយ ទៅលើប្រធានបទនេះគឺដូចតទៅ លោកស្រីបាននិយាយអំពីភស្តុតាងដែលលោកស្រីបានឃើញ ក៏ដូចជាសក្ខីកម្មដែលបានផ្ដល់ដោយដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងតុលាការនេះតែម្ដង។ លោកស្រីថា លោកស្រីអត់មានការមន្ទិលសង្ស័យ<ចំពោះភាពពិតនៃ>ភស្តុតាងទាំងអស់នេះទេ។ ការដែលខ្ញុំលើកឡើងយ៉ាងដូច្នេះ ខ្ញុំក៏នឹកឃើញដែលនៅពេលមួយលោកស្រីបានប្រើពាក្យ <">ភស្តុតាងតាមការរៀបរាប់រឿងរ៉ាវនេះ" <គឺវាមិនពាក់ព័ន្ធក្នុងរឿងនេះទេ ប៉ុន្តែវាជារឿងរ៉ាវផ្សេងទៅវិញ>។ តើយើងអាចរកឲ្យឃើញ ឬក៏<មានវិធីអ្វីដែលយើងគួរតែធ្វើ>ដើម្បីឈានទៅដល់ការ<កំណត់ថាតើ>ភស្តុតាងដែលបានផ្ដល់មក<>នៅចំពោះមុខតុលាការ <គឺ>ភស្តុតាង<ដែលរៀបរាប់អំពីរឿងរ៉ាវ ដោយមិនបានឆ្លុះបញ្ចាំងអំពីព្រឹត្តិការណ៍នោះ> យ៉ាងម៉េចដែរ? ខ្ញុំយល់ថាសំណួរនេះជាសំណួរមួយដែលពិបាកណាស់។ ហើយខ្ញុំរំពឹងថា លោកស្រីអាចឆ្លើយសំណួរខ្ញុំបាន។

[១១:១២:០៣]

**ឆ៖** ខ្ញុំសង្ឃឹមថា មានអ្នកសរសេរនិក្ខេបបទបណ្ឌិតទៅលើប្រធានបទថា តើដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានជ្រើសរើសដោយរបៀបណា ហើយថាតើកិច្ចសម្ភាសន៍ជាមួយពួកគាត់ត្រូវធ្វើឡើងដោយរបៀបណា និងថាតើឯកសារដែលទទួលបានពីពួកគាត់ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ដោយរបៀបណា។ ខ្ញុំសុំផ្ដល់ឧទាហរណ៍នៅប្រតិចារឹកមួយដែលចំណុចសំខាន់ក៏បានបាត់ចេញពីប្រតិចារឹកនេះ។ ខ្ញុំមិនសួរអំពីសុចរិតភាព ឬក៏ភាពជឿជាក់បានទៅលើដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។ ខ្ញុំបានស្ដាប់សក្ខីកម្មរបស់

ពួកគាត់។ ខ្ញុំមិនសួរចំណុចនេះទេ។ អ្វីដែលខ្ញុំចង់សួរនោះគឺការវិនិច្ឆ័យសេចក្តី ការវាយតម្លៃដែលពាក់ព័ន្ធទៅនឹងអង្គការណាមួយដែលចូលរួមពាក់ព័ន្ធទៅនឹងបញ្ហានេះ<នៅក្នុងបន្ទប់សវនាការនេះ>។

**ស៖** សូមអរគុណច្រើន។

[១១:១៣:២៧]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រី ឡឺវ៉ាញ ខ្ញុំនៅសល់ពេលពីរបីនាទីទេ ដើម្បីសុំការបំភ្លឺមួយចំនួនពីលោកស្រី។ លោកសហព្រះរាជអាជ្ញាបានប្រើសញ្ញាណជាភាសាអង់គ្លេសគឺថា *ហ្វ្រីវិល* ខ្ញុំមិនដឹងថាបកប្រែជាបារាំងថាម៉េចទេ។ គឺថា ឆន្ទៈ ឬក៏ថា ដោយចិត្តឯង។ គាត់<ប្រើពាក្យនេះ នៅពេលគាត់និយាយអំពីការរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយចំណុចនេះ ធ្វើឲ្យខ្ញុំគិតអំពីអ្វីដែលលោកស្រីបាន>និយាយអំពីការជ្រើសរើសវិធីសាស្ត្រនៃការស្រាវជ្រាវ ដែលលោកស្រីថា<មិនមែនជាការវិនិច្ឆ័យទៅលើអ្វីដែលជាការរៀបការនោះទេ> ទោះបីនិយាយពីការរៀបការមុន<ឬក្នុង>របបកម្ពុជាប្រជាធិបតេយ្យក៏ដោយ <ហើយក៏មិនមែនជាការប្រៀបធៀបការរៀបការតាមទស្សនៈជនជាតិអឺរ៉ុបនោះដែរ>។ <ប្រហែលនេះជាគំនូសព្រាង ប៉ុន្តែវាជាគំនិតមួយ។> នេះខ្ញុំសូមសង្ខេបបរិបទកាលពីម្សិលមិញហ្នឹង។ អ៊ីចឹងកាលពីម្សិលមិញពេលដែលនិយាយអំពីករណី មុន្នី លោកស្រីនិយាយថា ហ្នឹងហើយគាត់និយាយថា គាត់អត់ចង់រៀបការទេ ក៏ប៉ុន្តែទោះបីយ៉ាងណាក៏ក្តី គាត់ក៏ត្រូវរៀបការតាមឪពុកម្តាយដែរ <>។ នេះសំណួរហ្នឹងវែងតិចដែរ។ អ៊ីចឹងខ្ញុំយោងទៅឯកសារមួយទៀត ការកត់សម្គាល់មួយទៀតរបស់អ្នកជំនាញ ណាកាហ្គាវ៉ា នៅថ្ងៃទី១៣ កញ្ញា នៅម៉ោង១០:៤២:២៩សឹកុង អ្នកជំនាញ ណាកាហ្គាវ៉ា គាត់និយាយពីស្ត្រីនៅពេលហ្នឹង គាត់និយាយអំពីការរៀបការតាមប្រពៃណីខ្មែរធម្មតា។ គាត់និយាយដូចតទៅនេះ៖ "ពាក់ព័ន្ធទៅនឹង<អំណាចនៃការធ្វើការសម្រេចចិត្តរបស់ស្ត្រី> វាស្មើរតែសូន្យ ដូច្នេះ<ឪពុកម្តាយបញ្ជា ឬក៏>ណែនាំ<ទៅកូនស្រី>រៀបការ<ជាមួយនរណាម្នាក់។ ហើយ>ភាគច្រើន កូន<ស្រី>តម្រូវឲ្យឪពុកនេះ ម្តាយជាអ្នកសម្រេចជំនួស។ ផ្ទុយមក -- ម្យ៉ាងទៀត ចំពោះបុរស គាត់មានសេរីភាពជាងគាត់អាចផ្តួចផ្តើមការរៀបការដោយស្នើទៅឪពុកម្តាយ <សាច់ញាតិ> ឬក៏អាណាព្យាបាលដែល<អាចទាក់ទងឪពុកម្តាយខាងស្រី>ដែលគាត់ចង់រៀបការ។ ទោះបីជាយ៉ាងណាក៏ដោយ ការរៀបការទាំង

ឡាយ គឺរៀបចំដោយឪពុកម្តាយ និងសម្រេចដោយឪពុកម្តាយ។ ទោះបីជាបុរសចង់រៀបការជាមួយនឹងស្ត្រីណាក៏ដោយ ប្រសិនបើឪពុកម្តាយមិនយល់ព្រម វាពិបាកសម្រាប់បុរសនោះ ក្នុងការស្នើសុំការយល់ព្រម ដើម្បីឲ្យមានការរៀបការ"។ បញ្ចប់ការដកស្រង់។ ខ្ញុំចោទសំណួរនេះទៅលោកស្រី ទាក់ទងទៅនឹង<អ្វីដែលលោកស្រីបាននិយាយអំពី>វិធីសាស្ត្រនៃការស្រាវជ្រាវរបស់លោកស្រី ហើយនិង<>អំពី<របៀបដែលប្រជាជនបាន>និយាយប្រាប់លោកស្រី<អំពីការរៀបការ>នុ៎ង <រួមទាំងការរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ> គឺខ្ញុំចង់ដឹងថា តើរបៀបនៃការរៀបចំពិធីការ<ហ្នឹង> ហើយនិងឆន្ទៈរបស់<អនាគត>គូស្វាមីភរិយានុ៎ង មិនមែនមានសារៈសំខាន់អ្វីទេ<ក្នុងការរៀបការនោះ តើចំណុចនេះមានផលប៉ះពាល់លើអង្គហេតុដែលលោកស្រីមិនបានសួរ គឺថា "តើអ្នកចង់រៀបការដែរឬទេ?" ឬក៏លោកស្រីជ្រើសរើសប្រើពាក្យថា "តើនេះជាការរៀបការពិតប្រាកដទេ?" ដូច្នេះតើនេះគឺជា>ពាក្យ *ហ្វ្រីវីល* <ដែលសហព្រះរាជអាជ្ញាបាននិយាយនោះឬ គឺការរៀបការមិនមែនចេញពីចិត្តរបស់បុគ្គលពីរនាក់ទេ? តើពាក្យថា> *ហ្វ្រីវីល* <ឬក៏>ថាឆន្ទៈរបស់<បុគ្គលម្នាក់ៗហ្នឹង មិនមែនជាការរៀបការដោយពេញចិត្តទេឬ? តើនេះជាអ្វីដែលនាំឲ្យលោកស្រីសួរសំណួរជាក់លាក់ថា *ហ្វ្រីវីល ឬ*> ឆន្ទៈសេរីនោះ<មិនមែនជាការជ្រើសរើសដោយចេញពីចិត្តទេឬ?> គឺខ្ញុំដឹងថាសំណួរខ្ញុំវាវែងអន្លាយ ប៉ុន្តែឥឡូវខ្ញុំ<ចង់លើកពី>បរិបទហ្នឹង<មកនិយាយឡើងវិញ ដើម្បីឲ្យខ្ញុំ>យល់<ឲ្យបានច្បាស់។>

[១១:១៨:២៣]

**កញ្ញា ផេហ្គី ឡឺវ៉ាញ៖**

**ឆ៖** ខ្ញុំ<មិន>គិតថា វាមិន<សមហេតុផលនោះទេ> នៅពេលដែលសួរអំពីការរៀបអាពាហ៍ពិពាហ៍ដោយមានការទទួលស្គាល់ <ប៉ុន្តែមិន>បង្ខំ។ <ខ្ញុំចង់បញ្ជាក់ថា វាមិនមែនមិនសមហេតុផលនោះទេ។> ចំណុចទី២ ទោះបីជា ខ្ញុំមិនឯកភាពជាមួយនឹងលោកស្រី ណាកាហ្គាវ៉ា ដែលគាត់ចង្អុលយោងនោះក៏ដោយ <ខ្ញុំបានដឹងថា>នៅក្នុងការសិក្សាស្រាវជ្រាវ ដែលគាត់សិក្សា គឺអ្នកដែលទទួលរងគ្រោះអំពើហិង្សាដោយអំពើផ្លូវភេទនោះ ត្រូវបានកំណត់<>រួចស្រេចទៅហើយ <មុនការចាប់ផ្តើមសិក្សាស្រាវជ្រាវរបស់គាត់។ ក៏ប៉ុន្តែសូមទុកវាមួយអន្លើសិន> នៅក្នុងក្រមរបស់បុរស <របស់និស្សិតបណ្ឌិត> ដែលខ្ញុំយោង<នៅមុននេះ គឺថា>កាតព្វកិច្ចជាកត្តាសំខាន់ <គឺកាតព្វកិច្ចចំពោះឪពុកម្តាយ។ ឪពុកម្តាយ មាន "គុណ">។ ឪពុកម្តាយ គឺមានបន្ទុកធ្ងន់ធ្ងរ ហើយជាកាតព្វកិច្ចរបស់ឪពុកម្តាយក្នុងការស្វែងរកបុគ្គលណាម្នាក់សម្រាប់កូនប្រុសរបស់ពួកគេ <ដែលមានចែងនៅក្នុង>ក្រមបុរស ដែលខ្ញុំ

បានយោង <ហើយសម្រាប់កូនស្រីក៏ដូចគ្នាដែរ។ ដូច្នេះវាគឺជារឿងទី១ ហើយការនាំឲ្យមាន>កិត្តិយស <គ្រួសារ គឺជារឿងសំខាន់ ដែលមានចែងនៅក្នុងក្រមបុរស។ មានការលើកឡើងថា គឺមានកត្តាមូលដ្ឋាន>វប្បធម៌<មួយ នៅត្រង់ចំណុចនេះគឺ> នៅពេលដែលការរៀបការត្រូវបានរៀបចំ<ផ្គូផ្គង>ឡើងតាមប្រវត្តិសាស្ត្រ។ ជាពិសេសនៅពេលដែលការរៀបការត្រូវបានរៀបចំ<ផ្គូផ្គង>នោះ។ ប្រសិនបើខ្ញុំ <លើកឡើងនៅក្នុង>ឆ្នាំ១៩៧០ <-- គឺលើកឡើងនៅក្នុង>របប លន់ នល់ និងរបបខ្មែរក្រហម <គឺ> កត្តា<មូលដ្ឋាន>វប្បធម៌ <ដែលប្រជាជនធ្វើនោះ គឺជា>កាតព្វកិច្ច<ដែលពួកគេត្រូវតែ>បំពេញ។ <>ឪពុកម្ដាយ <>រៀបចំ<ផ្គូផ្គងការរៀបការ។ ពួកគាត់បានរៀបចំ ដោយមាន>ពិភាក្សា<យ៉ាងច្រើនហើយ>កូនៗទោះបីមិនចង់ ឬក៏ចង់ក៏ដោយ គឺត្រូវមានកាតព្វកិច្ចគោរពតាម នេះជាកាតព្វកិច្ច។ ខ្ញុំអាចផ្ដល់ឧទាហរណ៍នា<សម័យឥឡូវៗនេះអំពី>និស្សិតម្នាក់មកពីសាកលវិទ្យាល័យភូមិន្ទ ឪពុកម្ដាយមានការអប់រំខ្ពស់ ហើយរៀបចំឲ្យកូនស្រីរបស់គាត់នេះរៀបការជាមួយបុរសម្នាក់ដែលគាត់គិតថាជាជម្រើសល្អសម្រាប់កូនស្រីរបស់<>ពួកគាត់។ ហើយ<នាងបាន>យល់ស្របតាមសេចក្ដីសម្រេចរបស់ឪពុកម្ដាយ ក៏ប៉ុន្តែនៅក្នុងសម័យកាល<នេះ អ្វីដែលខ្ញុំបាននិយាយ គឺវាមិនបានធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ នៅក្នុងសម័យកាលនេះ គឺឪពុកម្ដាយមានពេលវេលាដើម្បីសម្រេចចិត្ត> ថាតើបុគ្គល<នោះមានភាពសាកសម ឬក៏អត់នៅក្នុងអំឡុងពេលភ្ជាប់ពាក្យនោះ។ អ្វីដែលមិនមាននៅក្នុងរបបនោះ គឺការភ្ជាប់ពាក្យ។> ឪពុកម្ដាយ <បានសម្រេចចិត្ត>ថាបុរស<ក្មេង>ហ្នឹងមិន<សាកសមនឹងស្ត្រីក្មេងហ្នឹងទេ។ ស្ត្រីក្មេងនេះ>បានមក<ជួបខ្ញុំ ហើយ>និយាយជាមួយខ្ញុំ<ថា៖ "តើអ្នកអាច> និយាយជាមួយនឹងឪពុកម្ដាយរបស់ខ្ញុំ ហើយប្រាប់ឪពុកម្ដាយថា<នៅពេលដែលពួកគាត់>រៀបចំការឲ្យ <ខ្ញុំនៅលើកក្រោយទៀត សូមឲ្យពួកគាត់សួរខ្ញុំថា តើខ្ញុំយល់ព្រមរៀបការជាមួយបុគ្គលហ្នឹងដែរឬទេ?"> នេះជារឿង៥ឆ្នាំនៅពេលដែលខ្ញុំសិក្សាស្រាវជ្រាវ។

[១១:២១:៥២]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា ហាក់ដូចជាមិនបានឆ្លើយតបទៅនឹងសំណួរនោះទេ<។ ខ្ញុំមិនគិតថា វាគឺជាកំហុសរបស់អ្នកជំនាញនោះទេ។ វាមានសេចក្ដីផ្ដើមរហូតដល់១០>នាទី<។ ក៏ប៉ុន្តែសំណួរ ដែល>ខ្ញុំយល់ថាតាមការលើកឡើងរបស់មេធាវីការពារក្ដី សំណួរនោះគឺចង់សួរថា ហេតុអ្វីបានមិនសួរអ្នកឆ្លើយ ឬក៏<> សួរទៅគេទៅ ថាតើពួកគាត់ទាំងអស់នោះបានយល់<>ព្រមរៀបអាពាហ៍ពិពាហ៍ដែរឬទេ? នេះជា

សំណួរដែលមេធាវីការពារក្តីចង់ចោទសួរ។ ហើយ<លោកស្រីមេធាវីបាន>លើកឡើង<នូវចំណុចជាច្រើន> ហេតុអ្វីបានជាអ្នកជំនាញមិនបានសួរសំណួរបែបនេះនៅពេលដែលគាត់ធ្វើការសិក្សាស្រាវជ្រាវ។ ទោះបីជា <ខ្ញុំគិតថា>ពេលវេលា<អស់ហើយក៏ដោយ ខ្ញុំគិតថាគួរតែឲ្យអ្នកជំនាញឆ្លើយឲ្យចំទៅនឹងសំណួរដែលបានសួរ>។

**កញ្ញា អង់តា ហ្គិសសេ៖**

លោកសហព្រះរាជអាជ្ញាហ្នឹង អន្តរាគមន៍ពេលខ្ញុំចោទសំណួរទៀតហើយ។ ខ្ញុំយល់ថាសំណួរខ្ញុំៗអម្បាញ់មិញនោះវែងណាស់ ប្រហែលជាមានការបកប្រែបាត់ខ្លះហើយ ក៏ប៉ុន្តែសំណួរខ្ញុំហ្នឹងមិនៗសួរអ៊ីចឹងទេ ដោយសារខ្ញុំមានពេលវេលាបន្តិចតិចតួច អ៊ីចឹងខ្ញុំបន្តទៅទៀត។

[១១:២២:៥៨]

**សួរដោយកញ្ញា អង់តា ហ្គិសសេ៖**

**ស៖** លោកស្រីបានឆ្លើយកាលពីម្សិលមិញផងដែរទៅសហព្រះរាជអាជ្ញា កាលនោះសហព្រះរាជអាជ្ញាបានលើកឧទាហរណ៍រឿងរ៉ាវមួយចំនួនថាលោកស្រីពិបាកបែងចែករឿងរ៉ាវរបស់ -- អ្នកដែលលោកស្រីសម្ភាសដើម្បីឆ្លើយទៅសំណួរសហព្រះរាជអាជ្ញា។ ហើយខាងព្រះរាជអាជ្ញាបានផ្តល់<ស្ថិតិជាក់លាក់មួយចំនួន ឬក៏>ឧទាហរណ៍មួយចំនួនទៀត ហើយខ្ញុំសូមយកឧបសម្ព័ន្ធរបស់លោកស្រីដែលមានរឿងរ៉ាវរបស់ដែលលោកស្រីសម្ភាសហ្នឹង មានសេចក្តីសង្ខេបនៅក្នុងឧបសម្ព័ន្ធហ្នឹងគឺនៅចាប់ពីទំព័រ២១៦ គឺឯកសារ E3/1794 នៅក្នុងចំណោមមនុស្ស១៩២នាក់ ដែលលោកស្រីបានសម្ភាសហ្នឹងមាន២៩<>នាក់បានបញ្ជាក់ថាឪពុកម្តាយជាអ្នកជ្រើសរើសមុនគេ ជ្រើសរើសគូស្រករឲ្យគាត់ហ្នឹងមុនគេ ហើយ២៥នាក់ទៀត បានបញ្ជាក់ថាជួនកាលហ្នឹង ភាគីទាំងពីរហ្នឹងខាងស្រី និងខាងប្រុសហ្នឹងបាន<ព្រមព្រៀងគ្នាមុននឹង>ទៅសុំការអនុញ្ញាតពីអង្គការ<>។ <ជាសរុប>២៨ភាគរយនៃការរៀបការទាំងអស់ហ្នឹង គឺជាការចេញពីការជ្រើសរើសរបស់ឪពុកម្តាយ ឬក៏ចេញពីភាគីណាមួយជាសាមីខ្លួន។ អ៊ីចឹងនៅពេលដែលលោកស្រីបាននិយាយនៅក្នុងសេចក្តីសន្និដ្ឋានរបស់លោកស្រីប្រើ ដោយលោកស្រីប្រើពាក្យថាការរៀបការជាដាច់កាតព្វកិច្ចហ្នឹង <តើ>លោកស្រី<ក៏>និយាយ<ពី>២៨ភាគរយហ្នឹង<ដែរ ឬក៏>លោកស្រីចង់និយាយពីករណីទូទៅតែម្តង ឬក៏យ៉ាងម៉េច?

[១១:២៥:១៥]

**ឆ៖** <នៅក្នុងផ្នែកដែលខ្ញុំកំពុងតែនិយាយអំពី>និន្នាការ<ទូទៅ ក៏ប៉ុន្តែនៅក្នុង>ផ្នែក<នេះ> ខ្ញុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជ្រើសរើសពាក្យ<នេះ គឺ> ខ្ញុំសូមថយក្រោយបន្តិច -- ការរៀបការទាំងនោះដែលនៅតែ ឪពុកម្ដាយជាអ្នកយកឈ្មោះដាក់ឲ្យទៅមេដឹកនាំសុំការឯកភាពដើម្បីឲ្យកូនប្រុស កូនស្រីរបស់ពួកគាត់រៀបការនៅតែឪពុកម្ដាយសុំការយល់ព្រមដដែល។ អ៊ីចឹងគឺយើងអាចមើលឃើញថា វាជាការរៀបចំ។ នៅក្នុងការរៀបចំ សហគមន៍មានភាពខុសគ្នា។ <សូមនិយាយរឿងនេះ នៅក្រៅអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកណាម្នាក់>មិនទៅ<>ជួបប្រធានភូមិ<> ហើយនិយាយថា<៖ "ខ្ញុំចង់>សុំការអនុញ្ញាត<ពីអ្នក ដើម្បីឲ្យ>កូនប្រុសកូនស្រី<របស់ខ្ញុំអាច>រៀបការ<បាន">។ ដូច្នេះ <មិនមានគេនិយាយថាប្រធានភូមិនោះ មិនបានផ្ដល់តម្លៃដល់កូនទាំងពីររបស់គាត់នោះទេ> ក៏ប៉ុន្តែវាមានភាពខុសគ្នានៅត្រង់ចំណុចខ្លះ។ ខ្ញុំឆ្លើយថា ពិតជាដូច្នោះមែន ចំពោះសំណួររបស់លោកស្រី វាជាទិដ្ឋភាពទូទៅ ហើយខ្ញុំអាចទាញជាសេចក្ដីសន្និដ្ឋានរួម។ <ហើយខ្ញុំចង់និយាយផងដែរថា> ការរៀបការ<ទាំងអស់នោះ គឺ>ឪពុកម្ដាយបានចូលរួមក្នុងការរៀបចំ<ផ្ទូផ្ទង>។ វាកើតឡើងនៅក្នុងពេលវេលា<ជាក់លាក់។ មានអំឡុងរយៈពេលមួយដែលរឿងនេះវាមិនបានកើតមានឡើងមួយរយៈពេល ពីព្រោះ>ឪពុកម្ដាយ<>មានសំឡេងតិចតួចតែប៉ុណ្ណោះ។ <ហើយវាគឺជាពេលវេលាដែលខ្ញុំបានជ្រើសរើស ជាពេលវេលាមួយនៃការផ្លាស់ប្ដូរដ៏ច្បាស់លាស់មួយ គឺដូចអ្វីដែលខ្ញុំបាននិយាយមុននេះ គឺថាសម្រេចចិត្តធ្វើតាមអ្វីដែលកំពុងតែធ្វើ។ យើងគួរតែបន្ថែមល្បឿនដើម្បីសម្រេចនូវរឿងនោះ។> ហើយ<រឿងទាំងអស់នោះគឺបានកើតឡើងប្រហែលជាក្នុង>ឆ្នាំ៧៨។ <ហេតុដូច្នេះហើយ បានជា>ក្រុមដែលខ្ញុំធ្វើការស្រាវជ្រាវក្រោយឆ្នាំ<៧៩>នោះ <មានការចាប់អារម្មណ៍ណាស់សម្រាប់ខ្ញុំ ដើម្បីឆ្លុះបញ្ចាំងអំពីរឿងទាំងនោះ។ ខ្ញុំអាចមើលឃើញថាមានការប្រែប្រួលមួយចំនួន រួមទាំងទិដ្ឋភាពនៃការប្រាស្រ័យទាក់ទងគ្នាផងដែរ។ តើការរៀបការនៅក្នុងឆ្នាំ១៩៧៩ ធ្វើឡើងដោយរបៀបណា?> ថាតើទីតាំងកើតឡើងនៅទីកន្លែងណាខ្លះ ហើយអំណាចរបស់មេដឹកនាំនៅកន្លែងនីមួយៗនោះមានលក្ខណៈយ៉ាងម៉េច?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នៅក្នុងឆ្នាំ១៩៧៩ របបនោះបញ្ចប់ហើយលោកស្រី។

**កញ្ញា ផេហ្គី ឡឺវ៉ាញ៖**

ខ្ញុំយល់ ក៏ប៉ុន្តែចំពោះខ្ញុំ<ដែលជាអ្នកស្រាវជ្រាវម្នាក់ គឺ>ខ្ញុំត្រូវតែពង្រីក ពន្លាតការសិក្សារបស់ខ្ញុំរហូតទៅដល់ឆ្នាំ៧៩ ដោយសារ<វាគឺជារឿងដែលគួរឲ្យចាប់អារម្មណខ្លាំងណាស់>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<ខ្ញុំយល់ច្បាស់អំពីរឿងនេះ> ក៏ប៉ុន្តែចំពោះចំនួនតួលេខ ដែល<បាន>ផ្តល់ឲ្យ <គឺ>លោកស្រីបានលើកឡើងគឺលើកឡើងនៅក្នុងឆ្នាំ ១៩៧៩។ <ឥឡូវនេះ ខ្ញុំមិនចង់បង្អាក់ ហើយសួរថាតើមានចម្លើយចំនួនប៉ុន្មាន ដែលបានលើកឡើងថា>ឪពុកម្តាយគាត់ពាក់ព័ន្ធ<ការរៀបការ>នៅក្នុងឆ្នាំ១៩៧៩ <នោះទេ>។ ខ្ញុំយល់អំពីគោលបំណងរបស់លោកស្រី ក៏ប៉ុន្តែចំណុចនេះគួរតែបញ្ជាក់បំភ្លឺឲ្យបានច្បាស់លាស់។

[១១:២៨:០៩]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងខ្ញុំមានសំណួរមួយចេញពីចម្លើយហ្នឹង។ ទាក់ទងនឹង ២៨ភាគរយនេះ ដែលមានសំណើពីសំណាក់ឪពុកម្តាយ ឬក៏សំណើពីសាមីជន តើលោកស្រីអាចបញ្ជាក់បានដែរឬទេ ថាបញ្ជាក់ពីរយៈកាលមើល តើវាមានប្រែប្រួលដែរឬទេ? ខ្ញុំមានឧទាហរណ៍ ដូចលេខ២នេះ ជាបុគ្គលម្នាក់ដែលបានសុំ លេខរៀងទី២នេះ គាត់បានសុំការអនុញ្ញាតនៅឆ្នាំ<៧៨> ហើយនៅលេខ១ក្នុងតារាងហ្នឹង គឺថា គឺមនុស្សម្នាក់ហ្នឹងបានសុំដែរនៅក្នុងឆ្នាំ<៧៨> ហ្នឹងមានមួយដែរ។ នៅ<ខែ១១> ឆ្នាំ១៩៧៨ មួយទៀត <លេខ៧។> បន្ទាប់មកទៀត លេខ<១០> សីហា ឆ្នាំ១៩៧៨។ <ហើយឆ្នាំ៧៧ លេខ១២> តើមានសីមាអីមួយ ប្រព័ន្ធណាមួយ<ពាក់ព័ន្ធទៅនឹងការរៀបការប្រភេទនេះ>ដែលថា<>មានសំណើចេញពីគ្រួសារ <ឬក៏សំណើដោយភាគីណាមួយនៃប្តីប្រពន្ធនោះ ទាក់ទងទៅនឹងឆ្នាំ ឬក៏បាតុភូតនេះរីករាលដាលគ្រប់ពេល គ្រប់តំបន់? ជាការពិតហើយ ខ្ញុំយល់ថា មានការញែកដាច់ពីគ្នារវាងពេលវេលា និងទីកន្លែង> ក៏ប៉ុន្តែការរៀបការនេះ ដែលមានការស្នើចេញពីសាមីជន ឬក៏ពីឪពុកម្តាយហ្នឹងវាមានទ្រង់ទ្រាយជារចនាសម្ព័ន្ធមួយ ជាសីមាមួយដែលយើងអាចយល់បាន ឬក៏យ៉ាងម៉េច?

[១១:២៩:៥៩]

**កញ្ញា ផេហ្គី ឡឺវ៉ាញ៖**

**ឆ៖** ខ្ញុំឃើញមានការងាកប្រែប្រួលនៅក្នុង<ដំណើរ>ការជ្រើសរើស <គឺវាអាស្រ័យទៅលើថា>តើនរណាជាមេដឹកនាំនៅក្នុងតំបន់<មួយ> នៅក្នុងពេលវេលាមួយ<នោះ>។ ខ្ញុំបានឃើញមានការប្រែប្រួលដូច្នោះមែន ជាពិសេស ខ្ញុំបានឃើញនៅដើមឆ្នាំ១៩៧៦ ដែលការរៀបការ គឺថាមានធាតុវាធាតុប្រពៃណីជាច្រើន<។ ខ្ញុំដឹងថា រឿងនេះវានៅក្រៅដែនវិសាលភាពពេលវេលាយុត្តាធិការរបស់តុលាការនេះ> ក៏ប៉ុន្តែនៅចុងឆ្នាំ១៩៧៩ នៅពេលដែលខ្មែរក្រហមផ្តល់ការយល់ព្រមទៅដល់ការរៀបការ យើងឃើញថា មានការរៀបចំច្រើន ហើយលក្ខណៈទិដ្ឋភាពប្រពៃណី យើងឃើញមានការងាកមក

វិញ<នៅក្នុងអំឡុងពេលនោះ>។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ពេលវេលាខ្ញុំអស់ទៅហើយ អ៊ីចឹងខ្ញុំសូមបញ្ចប់ការសំណួរខ្ញុំនៅពេលនេះតែម្តង។ ហើយលោកប្រធាន សូមអរគុណ ដែលបានផ្តល់ពេលវេលាបន្ថែមឲ្យខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញ ផេហ្គ ឡឺវ៉ាញ បានដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះ សូមអរគុណកញ្ញា អ្នកជំនាញ បណ្ឌិត ផេហ្គ ឡឺវ៉ាញ ដែលចំណាយពេលវេលាដ៏មានតម្លៃធ្វើដំណើរមកពីនាយសមុទ្រ ហើយនិងត្រូវបានចំណាយពេលវេលាអស់រយៈពេលមួយសប្តាហ៍រង់ចាំនៅទីក្រុងភ្នំពេញដោយមូលហេតុទឹកជំនន់លិចទីធ្លាបរិវេណនៅ អ.វ.ត.កនេះ។ ហើយក្នុងការមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាអ្នកជំនាញ ក្នុងរយៈពេល៣ថ្ងៃកន្លងមកនេះប្រកបដោយភាពអត់ធ្មត់ គុណធម៌ និងសីលធម៌វិជ្ជាជីវៈខ្ពស់ ហើយសក្ខីកម្មរបស់កញ្ញាបណ្ឌិតនឹងអាចរួមវិភាគទានសំខាន់ ក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់កញ្ញាបណ្ឌិតនៅ អ.វ.ត.កនេះ លែងមានភាពចាំបាច់ទៀតហើយ ហើយកញ្ញាបណ្ឌិតអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលកញ្ញាមានបំណងចង់ទៅហើយ ហើយសូមកញ្ញាមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន និងទទួលបានជោគជ័យថ្មីៗថែមទៀត និងធ្វើដំណើរការប្រកបដោយសុវត្ថិភាព។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនអ្នកជំនាញវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ។ សូមកញ្ញាបណ្ឌិតអញ្ជើញចាកចេញពីបន្ទប់សវនាការបានហើយនៅពេលនេះ។

[១១:៣២:៣២]

បាទ តទៅនេះ អង្គជំនុំជម្រះមានបញ្ហាបន្តិចបន្តួច ហើយសូមទី១ គឺផ្សព្វផ្សាយនូវសេចក្តីសម្រេចមួយ ពាក់ព័ន្ធទៅនឹងសំណើរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-298 ដែលនឹងធ្វើមកផ្តល់សក្ខីកម្មនៅរសៀលនេះ។ អង្គជំនុំជម្រះបានទទួលសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E446 សុំឲ្យទទួលយកឯកសារភស្តុតាងនូវឯកសារ E319/51.3.3 ដែលទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01365424



ប្បវេណី 2-TCCP-298 ដែលត្រូវបានកំណត់ឲ្យមកផ្តល់សក្ខីកម្មបន្ទាប់ពីអ្នកជំនាញ 2-TCE-81។

អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារដែលបានស្នើឡើងនេះ មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-298 និងទម្រង់បែបបទព័ត៌មានបន្ថែមចំនួនពីរ។ មួយ ក្នុងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១០ និងមួយទៀតចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៣។ អង្គជំនុំជម្រះបញ្ជាក់ថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងទម្រង់បែបបទព័ត៌មានបន្ថែម ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១០ ត្រូវបានទទួលយកធ្វើជាឯកសារភស្តុតាង ក្នុងសំណុំរឿង០០២/០២រួចហើយ ដោយកំណត់លេខឯកសារដាច់ពីគ្នា គឺលេខ E3/4779។ សម្រាប់ពាក្យសុំ និង គឺលេខ E3/6034a សម្រាប់ទម្រង់បែបបទព័ត៌មានបន្ថែម។ ដូច្នេះសំណើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងឯកសារទាំងនេះចាត់ទុកអសារបង់។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារជាភាសាខ្មែរនៃឯកសារ E319/51.3.3 ហាក់ដូចជាដូចគ្នាទៅនឹងឯកសារ E3/4779។ រីឯឯកសារ E3/6034a ដែលជាឯកសារភាសាអង់គ្លេស មានភាពខុសគ្នាខ្លះ។ ដូច្នេះ អង្គជំនុំជម្រះបានស្នើឲ្យអង្គភាពបកប្រែភាសាពិនិត្យឯកសារជាភាសាអង់គ្លេស ទាំងលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងទម្រង់បែបបទ មានព័ត៌មានបន្ថែម ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១០នេះ ដើម្បីធានាថាការបកប្រែភាសានេះបានត្រឹមត្រូវ។ ចំពោះបែបបទព័ត៌មានបន្ថែម ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ E319/51.3.3 ដែលមានលេខ ERN 01049457 ដល់ 01049458 អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារទាំងពីរទំព័រនៃឯកសារ E319/51.3.3 នេះ មិនទាន់ត្រូវបានទទួលយកធ្វើឯកសារភស្តុតាងពីមុនមកនោះទេ។ ពាក់ព័ន្ធនឹងចំណុចនេះ អង្គជំនុំជម្រះរំឭកពីការអនុវត្តរបស់អង្គជំនុំជម្រះក្នុងការទទួលយកចម្លើយពីមុនៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ដែលបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះធ្វើជាឯកសារភស្តុតាង អនុលោមវិធាន៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ហើយទទួលយកឯកសារនេះ ធ្វើជាឯកសារភស្តុតាង។ អង្គជំនុំជម្រះកំណត់លេខឯកសារនេះ គឺ E3/6034b សម្រាប់ឯកសារនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីលើកឡើងនូវបញ្ហាមួយចំនួន លើសំណើសុំរបស់ភាគី ពាក់ព័ន្ធនឹងសវនាការស្តាប់សក្ខីកម្មដែលមានរហស្សនាម 2-TCW-960 ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីរូបនេះ នៅរសៀលថ្ងៃស្អែក។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:៣៧:១០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ បាទ ខ្ញុំមានការបំភ្លឺមួយចំនួនពាក់ព័ន្ធនឹងការស្តាប់សក្ខីកម្មនៅថ្ងៃស្អែក នូវសាក្សី 2-TCW-960។ អង្គជំនុំជម្រះបានទទួលដំណឹងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានឯកភាពក្នុងការដាក់បង្ហាញនូវខ្សែអាត់ស្តាប់ចម្លើយសាក្សី 2-TCW-960 ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតមកនៅក្នុងសំណុំរឿង០០២។ ហើយកាលពីព្រឹកមិញនេះ ភាគីក៏បានទទួលអ៊ីម៉ែលអង្គជំនុំជម្រះដែលបានជូនដំណឹងថា ខ្សែអាត់សំឡេងនេះមានហើយ គឺមានលេខ E319/52.2.17r។ ប្រហែលជាត្រូវការពេលវេលាបន្តិច ដើម្បីឲ្យភាគីចូលមើលបាន។ ក៏ប៉ុន្តែដំណើរការកំពុងតែរៀបចំហើយ។

អង្គជំនុំជម្រះបានទទួលសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដើម្បីសុំឲ្យអង្គជំនុំជម្រះទទួលយកខ្សែអាត់របស់បុគ្គលដែលបានស្តាប់ចម្លើយនៅក្នុងសំណុំរឿង០០៣ និង ០០៤ ដែលកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរត្រូវបានទទួលយករួចមកហើយនៅក្នុងសំណុំរឿង០០២។

<យើងនឹងមិនចេញសេចក្តីសម្រេចលើសារណានេះទេ។> អ៊ីចឹង ខ្ញុំសូមបញ្ជាក់ថា មិនមានការជំទាស់អ្វីពីភាគី ក្នុងការទទួលយកខ្សែអាត់សំឡេងទាំងអស់នេះ របស់សាក្សី 2-TCW-960 ទេ។ ខ្ញុំមិនមើលឃើញថា ភាគីណាមួយជំទាស់នោះទេ។ ដូច្នេះ ខ្ញុំសូមឲ្យមានការកត់ត្រាក្នុងប្រតិចារឹកត្រង់ចំណុចនេះ។

[១១:៣៩:១២]

**លោក នីកូឡាស គូមជែន៖**

យើងខ្ញុំមិនមានការជំទាស់នៅពេលនេះទេ ក៏ប៉ុន្តែមានបញ្ហាមួយចំនួនដែលខ្ញុំត្រូវពិភាក្សា<ផ្ទៃក្នុងជាមួយនឹងក្រុមរបស់យើងអំពីបញ្ហានេះ។> ប៉ុន្តែចំពោះចំណុចមួយនេះ ខ្ញុំមិនជំទាស់ ប៉ុន្តែមិនមែនជាគោលនយោបាយរបស់ការិយាល័យរបស់យើងខ្ញុំនោះទេ <ខ្ញុំគិតថា គឺមានបញ្ហាមួយចំនួន>ពាក់ព័ន្ធទៅនឹង<ទំហំនៃសំណុំរឿង និង>ភាពសម្ងាត់ជាដើម។ល។ អ៊ីចឹងសម្រាប់សាក្សីរូបនេះតែម្តង ខាងសហព្រះរាជអាជ្ញាមិនមានការជំទាស់ទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំនិយាយនេះ សំដៅតែលើខ្សែអាត់ស្តាប់ចម្លើយសាក្សី 2-TCW-960 តែប៉ុណ្ណោះ ហើយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ភាគីមិនមានការជំទាស់អ្វីទេ។ អង្គជំនុំជម្រះនឹងសម្រេចទៅលើសំណើនេះនៅពេលសមស្រប។ ឥឡូវនេះ ខ្ញុំងាកមកមេធាវីការពារក្តី ខៀវ សំផន តែម្តង គាត់ចង់បង្ហាញការកត់សម្គាល់ទៅលើបញ្ហានៃខ្សែអាត់នេះ។ ដូច្នេះតើមេធាវីការពារក្តី ខៀវ សំផន នៅតែចង់ធ្វើដដែលឬក៏អត់?

**កញ្ញា អង់តា ហ្គីសសេ៖**

អត់ទេលោកចៅក្រម ឡាវែន៍ ខ្ញុំចង់និយាយហ្នឹង ចង់សួរបញ្ជាក់ពីស្ថានភាពនៃខ្សែអាត់ទាំងអស់ហ្នឹង ឥឡូវលោកប្រធានប្រាប់ទៅហើយ អ៊ីចឹងខ្ញុំលែងចង់សួរហើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បើអ៊ីចឹងអង្គជំនុំជម្រះប្រកាសទទួលយកខ្សែអាត់ ដែលខ្ញុំបានផ្តល់លេខយោងអម្បាញ់មិញនេះ គឺ E319/52.2.17r។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងឲ្យនាំគាត់ត្រឡប់ចូលរួមក្នុងសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៤១ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការតទៅនេះអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-298។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៣:៣៤:១០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស នាងខ្ញុំលោកប្រធានឈ្មោះ ប៉ែន សុចាន់។

**ស៖** អរគុណលោកស្រី។ ហើយតើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ចាសលោកប្រធាន ខ្ញុំកើតនៅថ្ងៃទី១០ ខែ១០ ឆ្នាំ៦២។

**ស៖** បាទអរគុណ។ ហើយលោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណាដែរ ស្រុកកំណើត? កុំអាលទាន់ឆ្លើយ។

**ឆ៖** ស្រុកកំណើតបច្ចុប្បន្ន ខ្ញុំពីមុនរស់នៅភូមិកំពង់ក្ដី ឃុំរំលេច ស្រុកអូរតាប៉ោង ខេត្តពោធិ៍សាត់ លោកប្រធាន។

**ស៖** កុំបាច់បះ អាហ្នឹងមិនចាច់បះពាល់វាទេ ចាំខាងនេះគេសម្របសម្រួលហើយណ៎ា។ បាទចាំមើលភ្លើងក្រហមទៅ សឹមឆ្លើយតបបានហើយណ៎ះ! បញ្ជាក់ម្ដងទៀត ទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ទីកន្លែងកំណើត ខ្ញុំកើតនៅភូមិកំពង់ក្ដី ឃុំរំលេច ស្រុកអូរតាប៉ោង ខេត្តពោធិ៍សាត់ លោកប្រធាន។

**ស៖** បាទ អរគុណ។ ចុះទីលំនៅបច្ចុប្បន្ននេះ តើលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** ចាស លោកប្រធាន បច្ចុប្បន្ន ខ្ញុំរស់នៅឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់លោកប្រធាន។

[១៣:៣៦:១៦]

**ស៖** លោកស្រីប្រកបមុខរបបអ្វីដែរ សព្វថ្ងៃនេះ?

**ឆ៖** សព្វថ្ងៃនេះខ្ញុំប្រកបមុខរបបធ្វើស្រែ ហើយខ្ញុំចិញ្ចឹមកូន។

**ស៖** ឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ឆ៖** ចាស លោកប្រធាន ឪពុកខ្ញុំឈ្មោះ ប៉ែន ម៉ុន តែឈ្មោះម្ដាយ អ៊ុក យាន់។ តែឪពុកខ្ញុំច្រើន

ប្រើឈ្មោះពីរ។ ឈ្មោះមួយក្នុងបញ្ជីជាតិគឺ ប៉ែន ផុន ឈ្មោះគេក្រៅគាត់ឈ្មោះគឺ ប៉ែន ម៉ុន លោកប្រធាន។

**ស៖** បាទ អរគុណ ហើយចុះលោកស្រី ប្តីរបស់លោកស្រីឈ្មោះ ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ចាស ប្តីខ្ញុំឈ្មោះ ឯក ផា កូនខ្ញុំស្រីមានប្រាំនាក់ ប្រុសពៅមួយ ប្រាំមួយនាក់លោកប្រធាន។

[១៣:៣៧:២៧]

**ស៖** បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមរំឭកបញ្ជាក់លោកស្រី ប៉ែន សុចាន់ ថាជាចុងក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីអាចមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម។ គឺផលអន្តរាយទាំងឡាយដែលកើតមានចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។ លោកស្រី ប៉ែន សុចាន់ តើលោកស្រីធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ អំឡុងពេលកន្លងមក?

**ឆ៖** ចាស ខ្ញុំបានផ្តល់ចម្លើយតាមលោកស្រីមេធាវីបានពីរដង លោកប្រធាន។

**ស៖** បាទ នុំងមិនមែនជាការផ្តល់សក្ខីកម្មនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតទេណា។ ហើយអនុវត្តតាមបទបញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលលើកដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសហមេធាវីនាំមុខ រួមតាំងតំណាងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គនៃសវនាការក្នុងការសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១៣:៣៨:៥៧]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីអង្គសវនាការទាំងមូល និងសូមជម្រាបសួរ ដល់លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់។ ខ្ញុំបាទឈ្មោះ ពេជ អង្គ ជាមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី។ ពួក

យើងតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ក្រុមរួមនៃដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនសម្រាប់លោកស្រី។ សូមលោកស្រីឆ្លើយទៅតាមសំណួរ ស្ដាប់ឲ្យបាន។ ប្រសិនបើស្ដាប់មិនបានទេ លោកស្រីអាចសួរបញ្ជាក់ ដើម្បីឲ្យខ្ញុំលើកជាសំណួរសាជាថ្មី។

**ស៖** ជាដំបូង ខ្ញុំចង់សុំសួរលោកស្រីថា នៅមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ មុនពេលនេះ តើលោកស្រីរស់នៅទីណា?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ខ្ញុំស្ដាប់អត់ទាន់លោក សួរថាកំណើតខ្ញុំកើត ឬសួរសំណួរអ្វីមួយ?

**ស៖** បាទ គឺចង់ដឹងពីទីកន្លែងដែលលោកស្រីរស់នៅមុន ១៧ មេសា ១៩៧៥?

**ឆ៖** ចាស កាលនុ៎ង ខ្ញុំរស់នៅខេត្តពោធិ៍សាត់យើងបាន គេជម្លៀសចេញមកនៅឃុំខ្នារទទឹង។

**ស៖** លោកស្រីអាចបញ្ជាក់បានទេ ភូមិឃុំណា មុនជម្លៀសហ្នឹង?

**ឆ៖** ឆ្លើយ គឺកាលនុ៎ង ខ្ញុំរស់នៅខេត្តពោធិ៍សាត់ តាមឪពុក និងអ្នកម្ដាយ រួចហើយបានគេជម្លៀសមកនៅឃុំខ្នារទទឹងយើង ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** ខេត្តពោធិ៍សាត់ដែលលោកស្រីមានប្រសាសន៍អម្បាញ់មិញ លោកស្រីចង់មានសំដៅទៅលើទីរួមខេត្តពោធិ៍សាត់មែនទេ?

**ឆ៖** ចង់សំដៅទៅលើខេត្តពោធិ៍សាត់ ចាស។

[១៣:៤១:៤៥]

**ស៖** បាទ អ៊ីចឹង ខ្ញុំសូមបន្តសំណួរទៅទៀត បន្ទាប់ពីជម្លៀសមក លោកស្រីអម្បាញ់មិញបានមានប្រសាសន៍ថា មកនៅឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់ដដែល ពីទីរួមខេត្តមកស្រុកបាកាន។ បន្ទាប់មកទៀត លោកស្រីបានទៅរស់នៅទីណាដែរ បន្តពីនោះទៀត?

**ឆ៖** ពេលដែលជម្លៀសមក ពេលគេចាប់ឪពុកខ្ញុំ ម្ដាយខ្ញុំបាននាំខ្ញុំរត់ទៅនៅឃុំរំលេចដដែល។

**ស៖** បាទ ចុះលោកស្រីមានធ្លាប់ទទួលរងនូវការតម្រូវឲ្យរៀបការទេ នៅក្នុងសម័យខ្មែរក្រហមនោះ?

**ឆ៖** ចាស លោកប្រធាន អង្កាល់នុ៎ង ខ្ញុំនៅវ័យក្មេង គេបានតម្រូវឲ្យខ្ញុំរៀបការកាលសម័យខ្មែរក្រហម តាំងពីខ្ញុំអត់ទាន់គ្រប់អាយុលោកប្រធាន។

**ស៖** លោកស្រីមានប្រសាសន៍អម្បាញ់មិញ អត់ទាន់គ្រប់អាយុ។ លោកស្រីអាចបញ្ជាក់បានទេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិនទាន់គ្រប់អាយុហ្នឹង លោកស្រីមានអាយុប៉ុន្មាន? ខ្ញុំចង់សំដៅទៅលើពេលដែលគេតម្រូវឲ្យលោកស្រីរៀបការហ្នឹង ថាតើអាយុប៉ុន្មានលោកស្រីពេលនោះ?

**ផ៖** ចាស កាលនោះ ខ្ញុំមិនសូវចាំ និងមានឆ្នាំខែរាប់ដូចសម័យនេះទេ កាលនោះ ខ្ញុំចាំបានប្រហាក់ប្រហែលអាយុខ្ញុំ ប្រហែលជា១៥ ទៅ១៦ឆ្នាំប៉ុណ្ណោះ លោកប្រធាន។

[១៣:៤៣:៤៩]

**ស៖** បាទ អរគុណ ហើយពេលនោះ លោកស្រីមានបានចងចាំទេ គូទាំងលោកស្រី ហើយនិងអ្នកផ្សេងទៀត សរុបទៅមានប៉ុន្មានគូដែលរៀបការក្នុងពេលជាមួយគ្នា?

**ផ៖** សរុបទាំងអស់ ទាំងមានរូបខ្ញុំ ទាំងបងប្អូនយើងទៀត ទាំងអស់១២គូ លោកប្រធាន។

**ស៖** ក្នុងចំណោម១១គូ -- បាទ អរគុណក្នុងចំណោម១១គូ ទាំងរូបលោកស្រីទៀត ១២គូ។ ក្នុងចំណោម១១គូហ្នឹង លោកស្រីមានបានចាំគូណាខ្លះទេ ឈ្មោះគេ ឈ្មោះអ្នកដែលត្រូវគេឲ្យ -- ដែលរៀបការក្នុងពេលជាមួយគ្នា?

**ផ៖** កាលនោះ ខ្ញុំនៅវ័យក្មេង មានការភ័យខ្លាច ខ្ញុំអត់ទាន់ស្គាល់ពួកបងៗនោះទេ។ តែគ្រាន់ខ្ញុំចាំ១២គូ លោកប្រធាន។

**ស៖** បាទ អរគុណ។ លោកស្រីមានបានចាំទេ ទីកន្លែងរៀបការនៅកន្លែងណា?

**ផ៖** ចាស លោកប្រធាន នៅឃុំខ្នារទទឹងដដែល តែភូមិដើមរកា។

**ស៖** បុរសដែលគេឲ្យរៀបការជាមួយលោកស្រី ខ្ញុំសូមសួរសំណួរមុននឹងបន្តិចសិន។ តើការរៀបការរបស់លោកស្រីហ្នឹងជាការរៀបការដោយស្ម័គ្រចិត្តដែរឬទេ?

**ផ៖** ចាសលោកប្រធាន ថ្ងៃនោះ ឡើងមកពីធ្វើការមកម៉ោងប្រហែលជាប្រាំ ហើយគេបានកំណត់ប្រាប់ខ្ញុំថា ទៅការដ្ឋានមានបាយហូបឆ្អែត ហើយកាលនោះ ខ្ញុំហេវពេក ខ្ញុំក៏ដើរទៅ។ ដើរទៅ ក៏មានមេកងគេប្រាប់ថា មិត្តឯងមករៀបការ។ ហើយខ្ញុំក៏បានប្រកែកនៅក្នុងនោះ ពេលឃើញគេបើកសំពត់ខោអាវឲ្យខ្ញុំ ខ្ញុំប្រកែកថា ខ្ញុំអត់រៀបការទេ ខ្ញុំថាមកហូបបាយ ក៏គេថា អ៊ីចឹងគេថា មិត្តឯងគ្រប់ការហើយឬនៅ? ចំពោះរូបខ្ញុំផ្ទាល់ ខ្ញុំឆ្លើយទៅគេវិញថា គ្រប់ការហ្នឹងយ៉ាងម៉េច ខ្ញុំអត់ដឹងទេ។ ហើយក៏គេបង្ខំខ្ញុំ។ មិត្តឯង គ្រប់ការមិនគ្រប់ការ បក្សកំណត់មកហើយ ត្រូវតែរៀបការ ព្រោះគេទៅអស់ហើយ មិត្តឯងម្នាក់នៅរឹងទទឹងធ្វើអីទៀត។ អ៊ីចឹងក៏គេយកសំពត់ហ្នឹងខ្ញុំអត់ទាន់ចេះស្លៀកទេ គេក៏យកវល្លិ៍ចេកមកចងស្លៀកឲ្យនាងខ្ញុំ លោកប្រធាន។

**ស៖** ពេលដែលគេទៅហៅលោកស្រីហ្នឹង តើគេមានបញ្ជាក់ប្រាប់លោកស្រីថា គេហៅលោកស្រីទៅដើម្បីឲ្យរៀបការដែរឬទេ?

**ឆ៖** ចាស អត់លោកប្រធាន។ ពេលនោះ គេហៅខ្ញុំទៅថា ហូបបាយ។ ក៏ខ្ញុំដើរទៅ ក៏ឃើញគេអង្គុយតម្រង់ជួរ ប្រុសមួយជួរ ស្រីមួយជួរទៅហើយ។ ដល់ពេលហើយ ខ្ញុំនឹងប្រកែកយ៉ាងណាក៏គេមិនព្រម គេត្រូវតែចាប់រៀបការ។ ក្នុងពេលនោះ ក៏ខ្ញុំប្រកែកយ៉ាងម៉េច ក៏មេកងគេចាប់--

**ស៖** ខ្ញុំៗ សូមលោកស្រីឆ្លើយត្រឹមហ្នឹងបានហើយ ខ្ញុំនឹងសួរបន្តទៅទៀត។

បាទ សូមគោរពលោកប្រធាន ខ្ញុំចង់សុំអនុញ្ញាតលោកប្រធានឲ្យខាង អេ.វី ដើម្បីបញ្ចាំងឃ្លីបវីដេអូមួយដែលមានលេខ E3/7233R ដែលក្នុងចំណោមឃ្លីប ដែលខ្ញុំផ្តល់ជូនទៅខាង អេ.វី គឺជាឃ្លីបលេខ២។ ហើយឃ្លីបនោះ មានលេខនាទី សឺកុង ដែលខ្ញុំនឹងផ្តល់ជូនទៅតាមលើកក្រោយ តាមក្រោយ។ សូមលោកប្រធានអនុញ្ញាតឲ្យ អេ.វី ចាក់ ហើយខ្ញុំនឹងផ្តល់ជូននៅពេលក្រោយ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ផ្នែកខាងអេ.វី ចាក់ផ្សាយនូវឃ្លីបវីដេអូតាមសំណើសុំរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[១៣:៤៩:១៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព – E3/7233R)*

*[អ៊ីចឹង ក្នុងឱកាស គេប្រើកំហឹងមកលើខ្ញុំហ្នឹង គេឲ្យបងឯងហៅខ្ញុំម៉េច? ហៅឲ្យទៅហៅ សមមិត្តចាន់ មករៀបការ។ ថាឥឡូវនេះ សមមិត្ត ចាន់ នេះនៅក្នុងកងមិត្តឯង ឥឡូវទៅហៅសមមិត្តហ្នឹងមកត្រូវរៀបការហើយ ស្អែកហ្នឹង ត្រូវរៀបការហើយ។ ពេលសមមិត្ត ចាន់ នេះប្រកែកថា ខ្ញុំមិនទាន់រៀបការទេ ព្រោះខ្ញុំមិនទាន់ចង់បាន ហើយក៏ខ្ញុំអត់ស្រឡាញ់។ មិត្តឯងអត់ស្រឡាញ់ ក៏គេត្រូវឲ្យមិត្តឯងរៀបការដែរ។]*

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមអរគុណ។ ខ្ញុំបាននាទីនៃវីដេអូនោះហើយ គឺនាទីទី៣៨ និង០៥សឺកុង ដល់៤០ និង២១សឺកុង។ ខ្ញុំចង់សូមសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី វីដេអូនេះ មានរូបលោកស្រីនៅក្នុងហ្នឹង ដែលមានចំណងជើងថា "អាពាហ៍ពិពាហ៍ក្រហម"។ លោកស្រីអាចបញ្ជាក់បានទេ មនុស្សស្រីដែល

បានឆ្លើយឆ្លងជាមួយលោកស្រីអម្បាញ់មិញ គាត់មានឈ្មោះអ្វី? ហើយគាត់មានតួនាទីអ្វី នៅពេលសម័យខ្មែរក្រហម?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស លោកប្រធាន គាត់ជាមេកងនៅជាមួយពួកខ្ញុំរាល់ថ្ងៃ។ ហើយដែលខ្ញុំអង្គុយជាមួយគាត់ហ្នឹង ខ្ញុំថតជាខ្សែអាត់វីដេអូនេះ ខ្ញុំអត់ដឹងថា គេហ្នឹងរៀបការយ៉ាងម៉េចៗទេ។ ខាងអ្នកថតហ្នឹងគាត់ចង់ដឹង។ ខ្ញុំថា មិនដឹងគេថ្នាក់ណាមកទេ បើលោកស្រីចង់ដឹង អាចទៅសួរមេកងនៅភូមិក្រូចសើចបាន។ ខ្ញុំក៏នាំគេទៅ ឲ្យសួរទៅ ចាស។

**ស៖** ហើយអ្នកដែលជជែកជាមួយលោកស្រី ពេលដែលលោកស្រីត្រូវរៀបការនុំង អំពីអាយុរបស់លោកស្រី លោកស្រីពេញរូបរាងសម្រាប់រៀបការហើយឬនៅ? ថាតើជានរណា ជាលោកស្រីម្នាក់នេះ ឬក៏ជាអ្នកណា?

[១៣:៥១:៥០]

**ឆ៖** ចាស គឺលោកស្រីមួយមេកងខ្ញុំហ្នឹងឯង ដែលខ្ញុំប្រកែកដោយមិនបានរៀបការ។

**ស៖** គាត់សួរលោកស្រីយ៉ាងដូចម្តេច អំពីថាលោកស្រីពេញរូបរាង ឬក៏ពេញការហើយ? លោកស្រីអាចនិយាយអំពីបញ្ហានេះបានទេ? លោកស្រីប្រកែកទៅគាត់យ៉ាងដូចម្តេចដែរ លោកស្រី សូមអញ្ជើញ?

**ឆ៖** ពេលនាងខ្ញុំបានឆ្លើយទៅកាន់គាត់ថា៖ “សមមិត្តបង ខ្ញុំអត់ទាន់រៀបការទេ ខ្ញុំអត់ស្រឡាញ់ទេ ព្រោះខ្ញុំអត់ទាន់ដឹងអី។” គេថា៖ “អ៊ីចឹងសមមិត្តឯង គ្រប់ការហើយឬនៅ?” ខ្ញុំបានឆ្លើយទៅកាន់គាត់វិញថា៖ “គ្រប់ការហ្នឹងយ៉ាងម៉េច? ខ្ញុំអត់ដឹងទេ។” “ទោះមិត្តឯង មិនដឹង មិនត្រូវចិត្ត ក៏ក្នុងរៀបការដែរក្នុងយប់នេះ ព្រោះ មិត្តអឿន បានចាត់តាំងមកដាក់ឈ្មោះមិត្តឯងហើយ។” អ៊ីចឹងលោកប្រធាន។

**ស៖** ប្រយោគចុងក្រោយដែលលោកស្រីនិយាយអម្បាញ់មិញថា៖ “ទោះមិត្តឯងមិនចង់រៀបការ ក៏ត្រូវតែរៀបការដែរ ព្រោះលោក អឿន ដាក់កំណត់មកយ៉ាងដូច្នេះ។” ខ្ញុំប្រហែលជាលើកឃ្លារបស់លោកស្រីមិនប្រាកដ -- មិនត្រឹមត្រូវច្បាស់លាស់ទេ។ តែចង់សួរថា តើអ្នកណាជាអ្នកនិយាយឃ្លានេះ? លោកស្រី ឬក៏មិត្ត អ៊ុំ អម្បាញ់មិញ?

[១៣:៥៣:២៦]

**ឆ៖** នេះ ដែលសំឡេងខ្ញុំឆ្លើយអម្បាញ់មិញ ជារឿងរបស់គាត់។ គាត់ថា មិត្តឯង មិនរៀបការ

ក៏ត្រូវរៀបការដែរ ព្រោះ មិត្តអឿន ដាក់កំណត់មកឲ្យមិត្តឯងហើយ។ កង់ប្រវត្តិសាស្រ្ត គេវិលទៅមុខ គេមិនវិលថយក្រោយទេ។ អ្នកឯងមិនរៀបការ ប្រយ័ត្នគេចាប់ទៅកសាង។ ដល់ពេលខ្ញុំឮសួរសំឡេងកសាង ក៏ខ្ញុំចូលខ្លួនទៅឲ្យគេស្លៀកសំពត់ចងសង្វាចេកទៅអង្គុយជួរនឹងគេ លោកប្រធាន។

**ស៖** តើពេលនោះ លោកស្រីមានបានព្យាយាមរត់ចេញពីកន្លែងរៀបការនោះដែរឬទេ?

**ឆ៖** ខ្ញុំព្យាយាមរត់ ខ្ញុំព្យាយាមសុំអង្វរលោកប្រធានមេកងហ្នឹង ហើយនិង បងអ៊ុំ ហ្នឹង គឺសុំគេអត់បាន គេថា កង់ប្រវិត្តសាស្រ្តវិលទៅមុខ គេបញ្ជាក់ម្តងហើយម្តងទៀត តែប៉ុណ្ណឹង លោកប្រធាន។

**ស៖** បាទ សូមអធ្យាស្រ័យ ដោយសារការភ័ន្តច្រឡំផ្នែកបច្ចេកទេស ឃ្លីបវីដេអូអម្បាញ់មិញ គឺពីនាទី៤០:២០វិនាទី ទៅដល់ ៤០:៥៥វិនាទី សូមអធ្យាស្រ័យ។ សូមបាទ ជាកំណត់ត្រា។ ខ្ញុំចង់សួមសួរបន្ថែមទៀត ថាតើគាត់មានបាននិយាយអីពាក់ព័ន្ធទៅនឹងអ្នកដទៃទៀតថា អ្នកដទៃទៀត គេព្រមហើយ ហើយលោកស្រីបដិសេធ តើគាត់មានបាននិយាយអំពីបញ្ហាហ្នឹងទេ?

[១៣:៥៥:២០]

**ឆ៖** ចាស បាន គាត់ថា១១គូគេទៅហើយ នៅមិត្តឯងមួយគូហ្នឹង នៅធ្វើទទឹងប្រវត្តិសាស្រ្តអីគេទៀត ព្រោះគេទៅចាប់ អង្គការចាត់តាំងមក ត្រូវតែអ្នកឯងរៀបការ ទោះក្មេង និងចាស់ គេអត់ដឹងទេ ពេលហ្នឹងគេៗធ្វើតាមសមមិត្តអឿន ដែរ។ បើចង់ដឹងច្បាស់នោះ ទាល់ទៅសួរមិត្ត អឿន ទៀត។

**ស៖** ចុះអ្នក១១គូផ្សេងទៀតនោះ លោកស្រីអាចដឹងទេថាគាត់ពេលដែលគាត់អង្គុយរៀបការហ្នឹង គាត់មានទឹកមុខរីករាយ ឬក៏ទឹកមុខគាត់យ៉ាងដូចម្តេចដែរ ហើយអាចលោកស្រីដឹងថា គាត់គេបង្ខំ ឬក៏ស្ថានភាពរបស់គាត់ដូចនឹងលោកស្រីដែរឬទេ?

**ឆ៖** ចាស អង្កាល់នោះ ឡើងមកពីធ្វើការទៅអង្គុយជួរ គ្មានអ្នកណាមួយមុខស្រស់ និងពេញចិត្តទេលោកគ្រូ -- លោកប្រធាន ព្រោះហេវផង ហត់ផង មកដល់គេចាប់ញាប់ៗ គ្នាគ្មានបាននិយាយគ្នាហើយក៏គ្មានឃើញមុខគ្នា ដែលស្គាល់ច្បាស់លាស់ថាបងណាជាមិត្តណា គឺខ្ញុំអត់បានមើល កាលហ្នឹងលោកប្រធាន។

**ស៖** បាទ អរគុណ។ គេ -- ពេលដែលលោកស្រីមកដល់កន្លែងរៀបការហ្នឹង គេមានចែកសម្ភារៈ ឬក៏ចែកអីជូនលោកស្រីទេ ឬក៏សម្លៀកបំពាក់?

[១៣:៥៧:០០]

**ឆ៖** ចាស នៅថ្ងៃនោះ គេចែកក្រមាមួយ អាវមួយ សំពត់ខ្មៅមួយ រួចខ្ញុំអត់ចេះស្លៀកទេ ដូចខ្ញុំ

មានប្រសាសន៍ជាន់ដើម គឺចេះតែចងវល្លិ៍ចេក គេចងឲ្យ គឺបានទទួលប៉ុណ្ណឹង។ រឿងបាយទឹកគឺអត់មាន។

**សៈ** ក្នុងការរៀបការហ្នឹង មានពិធីៗប្រពៃណី មានចាស់ទុំមកចូលរួម សាច់ញាតិរបស់លោកស្រីមកចូលរួមដែរឬទេ?

**ឆៈ** ត្រង់នេះហើយបានជាតែខ្ញុំឈឺចាប់។ ការរៀបការនោះ គ្មានបង គ្មានប្អូន គ្មានសាច់ញាតិលោហិតណា ដែលដឹងថាយើងរៀបការយ៉ាងម៉េចទេ គ្មានទេ គ្រាន់តែឈោងចាប់ដៃគ្នាហើយ បាយក៏អត់បានហូបដែរ លោកប្រធាន។

[១៣:៥៨:០២]

**សៈ** ចុះសាច់ញាតិមានបានមកចូលរួមទេ?

**ឆៈ** សាច់ញាតិគឺអត់មានបានដឹង បងប្អូន មីងមាគ្មាន អត់ដឹងទាំងអស់លោកប្រធាន។ របបផ្ដាច់ការ គឺអត់មានបងប្អូនចូលរួមទេ។

**សៈ** ពួកគាត់ត្រូវបានគេជូនដំណឹងដែរទេ ម្ដាយរបស់លោកស្រី ហើយនិងសាច់ -- បងប្អូនបង្កើតរបស់លោកស្រីមានត្រូវបានគេជូនដំណឹងពេលទន្ទឹមគ្នានៃការរៀបការហ្នឹងដែរទេ?

**ឆៈ** គាត់ដឹង ឬមិនដឹង គឺគាត់អត់ដឹងទេ លោកប្រធាន។ ខ្ញុំអត់បានសួរគេ ថាម៉ែឪខ្ញុំដឹង ឬអត់ គឺខ្ញុំអត់ដឹង ព្រោះខ្ញុំតែប្រកែកពីគ្នាតែប៉ណ្ណឹង លោកប្រធាន គ្មានឃើញម៉ែឪមកជិតខ្ញុំទេ។

**សៈ** បាទ សូមអរគុណ។ ឥឡូវចង់សួរអំពីកម្មាភិបាល ឬក៏ជាមេកងវិញ តើពួកគាត់មានបានចូលរួមនៅក្នុងពេលរៀបអាពាហ៍ពិពាហ៍នោះដែរទេ?

**ឆៈ** ចាស នៅក្នុងថ្ងៃដែលអង្គុយជួរ១២គូនោះ គ្មានញាតិមិត្ត ឬមិត្តសម្លាញ់ណាបានដឹងឮទេ មានតែសមមិត្ត អឿន ហ្នឹង ហើយនិងសមមិត្ត អ៊ុំ ហើយនិងឈ្លបគេប្រាំនាក់ ចាសលោកប្រធាន។

[១៤:០០:០២]

**សៈ** តើពួកគាត់សមមិត្ត អឿន ឬក៏សមមិត្ត អ៊ុំ ពួកគាត់ទាំងពីរហ្នឹង គាត់មានបាននិយាយអ្វីទេក្នុងពេលរៀបការនោះ?

**ឆៈ** ទាំងពីររូបហ្នឹង គេបាន បានមើលក្រដាស ប្រហែលជាគេបានមកពីណាមក ក៏ខ្ញុំអត់ដឹងដែរ។ ក៏គេដាក់អានឲ្យយើងថា ឲ្យយើងទាំងពីរ ទាំង១២គូហ្នឹង ឡើងឈរចាប់ដៃឡើង។ ហ្នឹង គេមានផ្ដែមីក្រូមួយ។ គេឲ្យចាប់ដៃគូមុខ គឺគេចាប់គូមុខ លោកប្រធាន។ ហើយចាប់ហើយ ក៏ចេញ។ គេថ្លែង

ការណ៍នឹងជាមួយនឹងសមមិត្ត អ៊ុំហ្នឹង គឺមានពីរនាក់ និងឈ្លប ប្រាំនាក់ លោកប្រធាន។

**ស៖** លោកស្រីអាចនិយាយបញ្ជាក់ឲ្យបានជាក់ច្បាស់ទេ តើមិត្ត អឿន ឬក៏មិត្តអ៊ុំ លោកស្រី អ៊ុំហ្នឹង គាត់មានបាននិយាយអ្វីទេ លោកស្រីមានចងចាំសម្ដីរបស់គាត់ ដែលបាននិយាយនៅក្នុងពេលនោះទេ ពាក់ព័ន្ធនឹងការរៀបការ ឬក៏គោលដៅនៃការរៀបការ?

**ឆ៖** ចាស នៅពេលហ្នឹងគេមានយោបល់ថា ប្រាប់ថា អ្នកណាមិនពេញ ក៏ត្រូវពេញចិត្ត។ ត្រូវប្ដេជ្ញាចិត្តជូនអង្គការ។ ក៏ចប់បងអ៊ុំ ហ្នឹងទៅ ក៏ដល់លោក ពូអឿន ហ្នឹង ក៏គេថ្លែងឡើង គេថា សមមិត្តណាក៏ដូចគ្នា ត្រូវការប្រកែកយ៉ាងណា ក៏ប្រកែកមិនរួចដែរ ព្រោះអង្គការបានចាត់តាំងសមមិត្តឯងគ្រប់គ្នានេះ រៀបការដើម្បីបង្កើតកូនជូនអង្គការ ហើយក៏គេស្រែកឲ្យយើងឡើងឈរចាប់ដៃ លោកប្រធាន។

[១៤:០២:០៧]

**ស៖** ពេលនោះ តើមានគូណាមួយ ឬក៏គូរបស់លោកស្រីផ្ទាល់ មានបានឡើងបញ្ចេញមតិដែរឬទេ?

**ឆ៖** ទាំងអស់គ្នា ទាំង១២គូ គ្មានអ្នកណាហ៊ានឡើងមានយោបល់ ហើយក៏គ្រាន់តែឡើងប្ដេជ្ញាចិត្តថា ខាងប្រុសអ្នកស្រែកទទួលប្ដេជ្ញាចិត្ត ទទួលមិត្តនារីនេះអស់មួយជីវិត ក៏ដើរចេញទៅ លោកប្រធាន។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណ។ ខ្ញុំនឹង -- ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីបញ្ចាំងវីដេអូខ្លីមួយទៀត វីដេអូដដែល លេខដដែល ក៏ប៉ុន្តែផ្នែកផ្សេង ដែលមានលេខនាទី គឺ៤៤:៤៣វិនាទី ដល់ ៤៧:០២វិនាទី ដែលមានលេខ ដែលខ្ញុំបានផ្ដល់ទៅខាង អេ.វី គឺវីដេអូឃ្លីបលេខ៥។ សូមលោកប្រធានអនុញ្ញាត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវី ខ្ញុំសូមស្នើសុំថា> ដើម្បីជាប្រយោជន៍<សាធារណជន> ថាតើលោក<អាចប្រាប់យើងដោយខ្លីៗ តើវីដេអូនេះបង្ហាញអំពីអ្វី ហើយថាតើខ្សែភាពយន្តនេះត្រូវបានថត>នៅពេលណា? <គឺនិយាយអំពីវីដេអូទាំងមូលនេះ មិនមែនវីដេអូឃ្លីបហ្នឹងទេ>។

**លោក ពេជ អង្គ៖**

សូមគោរពលោកស្រីចៅក្រម ខ្ញុំបានផ្ដល់ជានាទី នៅក្នុងវីដេអូហ្នឹងហើយ ហើយនាទី៤៤:៤៣វិនាទី ដល់នាទី៤៧:០២សឹកុង (២វិនាទី) ហើយខ្ញុំមិនដឹងថា លោកស្រីចង់ឲ្យខ្ញុំ--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំយល់លោកមេធាវី។ ខ្ញុំព្យាយាមបញ្ជាក់ឡើងវិញ ដើម្បីជាប្រយោជន៍នៃសាធារណជន តើលោកអាចពន្យល់ពីរបីមាត់ ថាតើខ្សែភាពយន្តហ្នឹង និយាយអំពីអ្វី ចង់បង្ហាញអំពីអ្វី<?> ហើយ <សំណួរ>ទី២ <តើវាត្រូវបាន>ថតនៅពេលណា<?> ហើយលោកពន្យល់ដោយសង្ខេបមក។ មិនបាច់ចាំវែងទេ។

[១៤:០៤:៥៦]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកស្រី ខ្ញុំយល់ប្រសើរជាងមុនអំពីអ្វីដែលលោកចៅក្រមបានមានប្រសាសន៍។ វីដេអូនេះ គឺនិយាយអំពីការសន្ទនាដែលលោកស្រីបានសន្ទនាជាមួយលោកស្រី អឿន ហើយនិងអ្នកផ្សេងម្នាក់ទៀតដែលនឹងខ្ញុំសួរសំណួរនិយាយអំពីបែបបទនៅក្នុងការរៀបការ ហើយនិងនិយាយអំពីសម្ដីរបស់មនុស្សម្នាក់ទៀតដែលនិយាយថា តើគាត់រៀបចំការរៀបការនេះគឺគាត់បានការណែនាំពីខាងណាមក? ដូច្នេះ នេះជាខ្លឹមសារគោលនៃឃ្លីបនេះ។ សូមអរគុណ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ខាងអាយ.វី ចាក់ផ្សាយវីដេអូឃ្លីបតាមសំណើសុំរបស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

[១៤:០៦:០៣]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*[សុចាន់៖ គឺជួនកាលសម័យ ប៉ុល ពត ហ្នឹងដែលគេហៅយើងហៅគ្នាចាប់ដៃហើយក៏វាម៉េច? អឿន៖ បាទ គេហៅគាត់-- សុចាន់៖ ដូចខ្ញុំនិយាយអត់? អឿន៖ គ្រាន់គេអង្គុយទឹមគ្នា គេហៅ គេឧទាហរណ៍ ថាបុរសនារីអង្គុយទឹមៗគ្នាអ៊ីចឹងទៅ គេហៅមក គេគ្រាន់តែប្រាប់ថា ឥឡូវអ្នកនេះគូនេះ អ្នកនេះគូអ្នកនេះ។ សុចាន់៖ ចាស ខ្ញុំឆ្ងល់ ឮខ្ញុំឆ្ងល់អ៊ីចេះ ឆ្ងល់ថា គេស្រឡាញ់យើងហ្នឹងគេបានស្នើប្រាប់ឮថា ស្រឡាញ់មិត្តនេះស្រឡាញ់មិត្តនោះដែរអត់? ហើយឬមួយក៏ថាបក្សកំណត់មកឲ្យការអ៊ីចឹងតែម្ដង? អឿន៖ អត់ទេ ខ្លះវា ខ្លះគេសួរដឹងថាអ្នកឯងស្រឡាញ់អ្នកនេះអ៊ីចឹង គេអាចរៀបឲ្យនេះ ដូចខ្ញុំស្រឡាញ់គាត់អ៊ីចឹង គេអាចរៀបឲ្យ។ ខ្លះបាទ ខ្លះគេកំណត់មកដល់កម្មាភិបាលអ៊ីចឹង ដូច្នេះគេកំណត់តែម្ដងអ្នកនេះយកអ្នកនេះៗ អ៊ីចឹងបណ្ដោយ។ មិនមែនថាយើងហ្នឹងមានសិទ្ធិអីណា (ឮមិនច្បាស់) អត់បានទេ តែខុសតិចគេយកវៃចោលឥឡូវហ្នឹង អត់បានទេ។ សុចាន់៖ អ៊ីចឹងមានបញ្ហា(ឮមិនច្បាស់) អឿន៖ បាទ*

*ទាល់គេបញ្ជា បើអត់មានបញ្ជាយើងទៅហ៊ាន ល្មមៗអត់ហ៊ានទេ ទាល់គេបញ្ជាថា ឥឡូវអ្នកឯង នេះ ឥឡូវគូនេះរៀបក្រុមនេះគេចង់បានគ្រួសារប៉ុន្មាននាក់ៗ ទាល់គេបញ្ជាមកបានយើងហ៊ាន បើថាអ៊ីចឹង អត់ទេ មាននរណាដែលហ៊ាន ការងារអីសូម្បីតែធ្វើអីបន្តិចក៏គ្មាននរណាហ៊ានដែរ បើអត់មានបញ្ជា នេះ ជំនាន់ហ្នឹង។ សុចាន់៖ អ៊ីចឹងមានមេធំលើពូកកំណត់ឲ្យការជាមួយខ្ញុំអ៊ីចឹង ដូចថាខ្ញុំ-- អឿន៖ បាទ សុទ្ធ មានមេគេពីលើមក មិនមែនធំអីតែយើង។ គេកំណត់ មិនមែនធំ ត្រឹមកំប៉ិកកំប៉ុកអី។ សុចាន់៖ ដូចៗគេ ប្រើពូអ៊ីចឹងឲ្យចាប់គូណា? អឿន៖ អត់ទេអាហ្នឹងគេតាមកងគេរាយការណ៍មកបាទ នៅតាមកងគេ។ គេរាយការណ៍អ៊ីចឹង ឥឡូវសម្រាប់គូនេះចង់បានអានេះៗ យើងមក អ្នកសហករណ៍គេៗមកតើ។ បាទ អ្នកសហករណ៍គេមកដល់ថាប៉ុន្មានគូប្រាំប្រាំមួយគូអ៊ីចឹង គេហៅមករៀបចំជាមួយគ្នាគេធ្វើពិធីការ។ អត់ស្គាល់អត្តសញ្ញាណ៖ អ៊ីចឹងខ្ញុំរៀបការមានគេចាត់ចែង ឬចំពោះបងឯងគឺថាអត់ទេ មានបងម៉ី មាន បងអឿន មានខុន។ អឿន៖ បងខុម បងថាន។ អត់ស្គាល់អត្តសញ្ញាណ៖ ហ្នឹងហើយបងខុំ បងថាន។ សុចាន់៖ អ៊ីចឹងទម្លាប់ៗហ្នឹងមក។ អឿន៖ បាទ។ សុចាន់៖ អ៊ីចឹងខ្ញុំដែលជនរងគ្រោះ ខ្ញុំឆ្ងល់ថាមានគេ បញ្ជាលើពូដែរអត់? អឿន៖ អត់ទេ។ អត់ស្គាល់អត្តសញ្ញាណ៖ ចុះហ្នឹងគេបញ្ជាហើយ យើងមិនមែន អាចចាត់ចែងខ្លួនយើងបានណា ដូចគាត់និយាយអ៊ីចឹង។ អឿន៖ អារឿងសហករណ៍អី វរសេនាធំគេ បញ្ជាហើយ។]*

*(ការបញ្ចប់ឯកសារជាសំឡេង-រូបភាព)*

[១៤:០៨:២៥]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណខាងអេ.វី ខ្ញុំសូមបញ្ជាក់បន្ថែមបន្តិច ដើម្បីបំពេញបន្ថែមទៅនឹងចម្លើយរបស់ខ្ញុំ ជូនលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍។ វីដេអូនេះជាវីដេអូដដែលដូចមុន ដែលខ្ញុំបានសូមឲ្យមានការ បញ្ចាំង ដែលមានចំណងជើងថា “អាពាហ៍ពិពាហ៍ក្រហម” – *វេតវេឌីង*។ ហើយវីដេអូនេះផលិតនៅឆ្នាំ ២០១២ ដែលមាននាយកគឺឈ្មោះ នាយកនៃការផលិតហ្នឹងឈ្មោះ លីដា ចាន់ និង ហ្គីយ៉ូម សួន។

[១៤:០៩:១៥]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ខ្ញុំសូមវិលត្រឡប់មកសួរទៅលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីវិញ។ លោកស្រីបានឃើញ អម្បាញ់មិញហើយបុរសម្នាក់ដែលលោកស្រីដេកជាមួយគាត់លោកស្រីអាចបញ្ជាក់បានទេ បុរសម្នាក់

នោះគាត់ឈ្មោះអ្វី? ហើយនៅសម័យដែលលោកស្រីរៀបការពេលនោះ បុរសនោះគាត់ធ្វើការអ្វី តួនាទីរបស់គាត់?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស លោកប្រធានអ្នកអង្គុយទាំងពីរហ្នឹងមួយឈ្មោះ អឿន គឺគេធ្វើអនុសេនាធំ គេធ្វើមេកងធំ ហើយស្រីទៀតគេជាអនុប្រធានកងធំនៅក្នុងកន្លែងពួកនាងខ្ញុំ លោកប្រធាន។

**ស៖** មនុស្សស្រីហ្នឹង គឺជាមនុស្សស្រីដដែល ដែលយើងបានឃើញពីមុនមែនទេ នៅក្នុងវីដេអូខ្លីពីមុនមែនទេ?

**ឆ៖** ចាស លោកស្រីហ្នឹងហើយដែលធ្វើបាបនាងខ្ញុំ ហើយចាប់ខ្ញុំឲ្យរៀបការគឺពីរនាក់ហ្នឹងឯង។

**ស៖** បាទ អម្បាញ់មិញ លោក អឿន មនុស្សប្រុសម្នាក់អំមិញ គាត់បាននិយាយថាគាត់ទទួលបញ្ជាពីលើ គាត់មិនហ៊ានធ្វើដោយខ្លួនឯងទេ។ នៅពេលដែលលោកស្រីបានជជែកជាមួយគាត់ហ្នឹង គាត់មានបានបញ្ជាក់ទៅលោកស្រីថា គាត់បានទទួលបញ្ជាពីណាឲ្យរៀបការលោកស្រីដែរឬទេ?

**ឆ៖** ចាសមាន។ គាត់ថា "បើៗអ្វែងចង់ដឹងណាស់ អ្វែងទៅសួរមេកងទៅសួរចៅហ្វាយស្រុកទៅ មានឡានមានអីចឹងជិះទៅសួរគេទៅ ព្រោះអញក៏គេចាត់ចែងមកដែរ។" គាត់ជឿ បងរឹម ហ្នឹងចៅហ្វាយនិងអ្នកចាត់ចែងមកដែរចាស ចៅហ្វាយស្រុកខ្មែរក្រហម។

**ស៖** អម្បាញ់មិញលោកស្រីបាននិយាយអំពី បងរឹម។ តើ បងរឹម ដែលជាចៅហ្វាយស្រុកហ្នឹងគាត់ប្រុសឬស្រី ហើយគាត់ចៅហ្វាយស្រុកហ្នឹងនៅពេលណា នៅពេលៗដែលលោកស្រីពីមុនឬក៏យ៉ាងម៉េចលោកស្រី?

[១៤:១១:៤៨]

**ឆ៖** ចាស កាលហ្នឹងគាត់ចៅហ្វាយស្រុក គាត់កាន់ក្តាប់ច្រើនៗសហករណ៍ចាស។ គាត់ក្តាប់១០សហករណ៍លើគាត់តែឯង គាត់ចៅហ្វាយស្រុកខ្មែរក្រហមលោកប្រធាន។

**ស៖** ចៅហ្វាយស្រុកនោះគឺស្រុកអី លោកស្រីបញ្ជាក់ឈ្មោះឲ្យផងនៅក្នុងខេត្តណា? ឈ្មោះស្រុក ហើយនិងឈ្មោះខេត្ត?

**ឆ៖** គាត់ចៅហ្វាយស្រុកទៅ ខ្ញុំអត់ដឹងថាគេឃុំណាគេអោបក្តាប់ ភូមិណាគេអោបក្តាប់ ខ្ញុំអត់យល់ទេ។ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាគេហ្នឹងចៅហ្វាយស្រុក គឺនីរសារគេមានប្អូន សេះប្អូនតែប៉ុណ្ណឹង។ ហើយគេបានមកកាន់ក្តាប់នៅក្នុងឃុំសហករណ៍នាងខ្ញុំនៅខ្នារទទឹងហ្នឹងចាស។

**ស៖** លោកស្រីអាចស្គាល់ឈ្មោះស្រុកហ្នឹងគេហៅស្រុកអីដែរទេ ដែលស្រុកដែលមានឃុំខ្នារទទឹងដែលនៅក្នុងនោះ ស្រុកនោះឈ្មោះអី?

[១៤:១២:៥១]

**ឆ៖** ស្រុកហ្នឹងគេហៅស្រុកពោធិ៍សាត់ ខេត្តពោធិ៍សាត់ ស្រុកបាកានដដែលលោកគ្រូ។

**ស៖** បាទអរគុណ។ អ៊ីចឹងលោកស្រីមានបានទៅជួបចៅហ្វាយស្រុកបាកាន ដែលជាចៅហ្វាយស្រុកពេលនោះឈ្មោះ រឹម ហ្នឹងដែរឬទេ? ពេលក្រោយពេលនៅក្នុងៗពេលដែលលោកស្រីថតវីដេអូហ្នឹងលោកស្រីមានបានទៅជួបគាត់ដែរឬទេ?

**ឆ៖** ចាស ខ្ញុំបានទៅថតខ្សែវីដេអូហ្នឹងគឺយូរដែរ គឺខ្ញុំបានឡើងទៅដល់ជួបគាត់។ គាត់ក៏មានខ្ញុំសំពះសួរគាត់ត្រឹមត្រូវ គាត់ឆ្លើយឡើងគាត់ថា "ពួកអ្វែងនៅណា មកថត មកសម្ភាសហ្នឹង" ក៏គាត់និយាយមកកាន់នាងខ្ញុំ។ ខ្ញុំសួរគាត់ថា "បងសម័យខ្មែរក្រហមគេចាប់បង្ខំរៀបការហ្នឹងធ្វើអ៊ីចឹងធ្វើអី?" គាត់ក៏ឆ្លើយឡើងគាត់ថា "មិនមែនធំតែអញទេ។ អញទៅមិនបាច់មកសម្ភាសអញទេ។ ហើយក៏មិនបាច់មកថតអញដែរ។ អញឡើងក្ដីដល់សាលាស្រុក សាលាក្ដីខ្មែរក្រហមនោះ។ អ្វែងចង់ដឹង អ្វែងដើរទៅសួរគេថ្នាក់លើទៀតទៅ បើមកសួរអញ អញមិនដឹងទេ។" ហើយខ្ញុំថា "ហ៊ឹបង! ការងារទាំងអស់គ្នាខ្ញុំគ្រាន់តែសួរ ខ្ញុំជនរងគ្រោះគ្រាន់ចង់ដឹងសម្ដីបង តើកាលបងចាត់ចែងហ្នឹងតើ បងបានដឹងថាអ្នកណាមកនិយាយជាមួយបងឯងដែរអត់?" "អញមិនបាននិយាយ ហាមថត ហាមសួរ។" ដល់គេផ្ដល់យោបល់អ៊ីចឹងលោកប្រធាន។

**ស៖** តើពេលនោះលោកស្រីដែលជាអតីតចៅហ្វាយស្រុកបាកានហ្នឹង គាត់មានបាននិយាយថាគាត់បានទទួលការណែនាំ ឬក៏បញ្ជាពីអ្នកណាពីខាងលើតទៅទៀតដែរឬទេ?

**ឆ៖** ចាសគាត់មាន គាត់ថាគាត់ទទួលពីតាអ៊ីចេះ តាម៉ុក។ ចង់ដឹងគាស់ខ្មោចទៅសួរ តាម៉ុក។ ងាប់ ឬរស់ គាត់អត់ដឹងទេ។ ចាស គាត់បានបញ្ជូនយោបល់មកអ៊ីចឹង ចាស។

**ស៖** ក្រៅពី តាម៉ុក គាត់មានបាននិយាយទៅអ្នកណាផ្សេងទៀតដែរឬទេ ដែលគាត់បានទទួលបញ្ជាពីគេនុ៎ង?

[១៤:១៥:៣៧]

**ឆ៖** ចាស គាត់អត់បាននិយាយអីទេ លោកប្រធាន ក៏គាត់ថាតែប៉ុណ្ណឹង។ ហើយពួកខ្ញុំក៏ឡើងឡានលាគាត់មកវិញ។ គាត់ថា ទៅណាទៅៗ។ កុំឲ្យអាចម៍ធ្លាក់ឡាន។ បើធ្លាក់ឡាន អត់ដឹងជាយោបល់

គាត់យ៉ាងម៉េច ខ្ញុំអត់ដឹង។ កាលនោះខ្ញុំទៅមានបារាំង មានអី។ មានជនជាតិច្រើន។

**ស៖** ខ្ញុំចង់សួរបញ្ជាក់បន្តិច អ្វីដែលលោកស្រីបញ្ជាក់ និយាយថាទទួលបញ្ជាក់ពីខាងលើអម្បាញ់មិញ បញ្ហាពាក់ព័ន្ធទៅនឹងបញ្ហាអ្វី ដែលទទួលបញ្ហាពី តាម៉ុក ហ្នឹង ពាក់ព័ន្ធនឹងបញ្ហាអ្វី?

**ឆ៖** ចាស គាត់ថា បើចង់ដឹងថា ចង់ដឹងច្បាស់លាស់ ចំពោះរៀបការនិងចាប់បង្ខំ រៀបការខ្មែរក្រហមហ្នឹង គាត់មិនបានចាត់ចែងទៅណាទេ ព្រោះមានគេចាត់ចែងមកឱ្យគាត់។ គាត់ចាត់ចែងទៅនុ៎ងវិញ។ ហើយក៏ខ្ញុំបានបញ្ជាក់គាត់ថា ខ្ញុំមកនេះ មកសួរបងដោយត្រឹមត្រូវ ព្រោះខ្ញុំជនរងគ្រោះណាបង។ ខ្ញុំគ្រាន់តែសួរឱ្យដឹងជាការពិត។ គាត់ថា បើចង់ដឹងច្បាស់ ទៅសួរខ្មោច តាម៉ុក រឿងនៅរស់ មិនរស់គាត់អត់ដឹងទេ។ អាចំពោះរៀបការនេះគឺគេធ្វើអ៊ីចឹង។ ឃើញតែគេធ្វើអ៊ីចឹងៗខាងហ្នឹង។ គាត់ឆ្លើយមកអ៊ីចឹង ក៏ពួកខ្ញុំចប់យោបល់ អត់ដឹងសួរថាម៉េច។

[១៤:១៧:១១]

**ស៖** តើគាត់មាននិយាយថា ការរៀបការហ្នឹងជាការរៀបការដោយគេតម្រូវឱ្យរៀបការអ៊ីចឹងតែម្តង តម្រូវឱ្យស្រីប្រុសរៀបការជាមួយគ្នាតែម្តង ឬក៏អាចនិយាយឱ្យច្បាស់ថា គាត់មានបាននិយាយថា គេបង្ខំឱ្យទៅរៀបការអ៊ីចឹងតែម្តង ឬក៏អត់ទេ ពេលដែលគាត់ឆ្លើយទៅលោកស្រីនេះ?

**ឆ៖** ព្រោះកាលដែលនាងខ្ញុំទៅដល់នោះ គាត់ឆ្លើយ។ គាត់ឆ្លើយមកកាន់នាងខ្ញុំថា គេឱ្យរៀបការមកពីថ្នាក់លើ ឱ្យទៅសួរ តាម៉ុក ហ្នឹង។ គាត់ថា គេឱ្យយើងរៀបការនេះ ដើម្បីយកកូនជូនអង្គការ។ ប៉ុន្តែវាអត់មានឃើញកូនជូនអង្គការ មានតែឃើញស្លាប់ អត់បានឃើញទេ លោកប្រធាន។

**ស៖** បាទ ខ្ញុំនឹងចូរទៅដល់បញ្ហាផ្សេង ប៉ុន្តែនៅក្នុងក្របខ័ណ្ឌនៃការរៀបការរបស់លោកស្រីដដែល។ អំពីការដែលលោកស្រីរួមរស់ជាមួយមនុស្សប្រុសដែលគេរៀបការឱ្យលោកស្រីហ្នឹង តើលោកស្រីមានដឹងថា កាលដែលថា គេផ្គូផ្គងលោកស្រី ហើយនិងមនុស្សប្រុសហ្នឹង គឺមនុស្សប្រុសហ្នឹង គាត់រើសលោកស្រី ឬក៏អង្គការជាអ្នកផ្គូឱ្យ អ្នកណាត្រូវនឹងអ្នកណាក្នុងពេលនោះ?

**ឆ៖** ចាស លោកប្រធាន ក្នុងពេលនោះ គេមិនបានថាឱ្យយើងស្រឡាញ់គ្នា ហើយក៏ខ្ញុំក៏អត់បានស្គាល់គ្នា។ ក្នុងខ្សែវីដេអូហ្នឹង ខ្ញុំបានទៅជួបបងគាត់ដែរថា សួរបញ្ជាក់ថា ខ្ញុំមិនបានស្រឡាញ់ទេ។ ហេតុអីបានប្អូនបងឯងមករៀបការជាមួយខ្ញុំ? គាត់ថា អត់ដឹងដែរ គឺមិត្តអ៊ុំ មិត្តអឿន ហ្នឹងគេរៀបការគាត់អត់ដឹង។ សូម្បីតែបងខាងប្រុសហ្នឹង ក៏គាត់អត់ដឹងខ្លួនដែរចាស។

[១៤:១៩:១២]

**ស៖** បាទ សូមអរគុណ។ សូមគោរពលោកប្រធាន។ ខ្ញុំចង់សុំអនុញ្ញាតលោកប្រធាន ដើម្បីបញ្ចាំងឃ្លីបវីដេអូទី១ដែលជាផ្នែកមួយនៃវីដេអូដែលស្ដីអំពី "អាពាហ៍ពិពាហ៍ក្រហម" ដែលក្នុងនោះគឺលោកស្រីនិយាយអំពីការរស់នៅជាមួយមនុស្សប្រុសនោះ ដែលជាប្ដី ដែលគេរៀបការជាមួយនឹងលោកស្រី។ ហើយវីដេអូនេះគឺជាវីដេអូដែល ហើយដែលមានលេខមួយដែលខ្ញុំប្រគល់ទៅឲ្យអេរី ឃ្លីបទី១ ហើយមានលេខនាទីពី៣២នាទី ៥៦វិនាទី ដល់ ៣៣នាទី ៤៤វិនាទី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

ខាងផ្នែក អេរី ចាក់ផ្សាយវីដេអូឃ្លីប តាមសំណើសុំរបស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*[វាអត់បានបានស្គាល់អាប្ដីខ្លួនឯង អារៀបការសម័យគ្រួសារ កាលសម័យខ្មែរក្រហមហ្នឹង អត់ដែលស្គាល់មុខ។ គាត់ ខ្ញុំចង់ចាំជាមួយគាត់នុំង វាគ្មានកន្លែងចងចាំថា ឲ្យពាក្យល្អ ដាក់ប្អូនបងឯងអត់ទេគ្មាន ដែលបាន ដឹងថា ល្អយ៉ាងម៉េច? អាក្រក់យ៉ាងម៉េច? ព្រោះដេកមិនដែលទល់មុខគ្នា ហើយក៏មិនដែលមើលមុខគ្នា ហើយក៏មិនដែលដេកថា ឲ្យមានសិទ្ធិសេរីភាពក្នុងខ្លួនទេបង។ ខ្ញុំជួប អត់មានចិត្តថាប្ដីខ្ញុំ បងខ្ញុំ ធ្វើអីនៅឯណា? អត់មានចាប់អារម្មណ៍សួរគ្នា ថាម៉ែឪនៅអីណា? អត់។ អត់ដែលបានទេ។ គឺតែជួបគ្នាដឹងតែពីទឹកភ្នែកតែម្ដង ឲ្យតែជួបគ្នា ដឹងតែ -- គាត់ហ្នឹងក៏គាត់ស្ដាប់ល្អប ហើយដឹងតែខោយប់ឡើង ដឹងតែពីរជាន់ហើយ យប់ថ្ងៃក៏នៅតែបារម្ភដែរ។ ថាជួបប្អូនឯងគ្មានកន្លែងសុខ ព្រោះយើងអត់ស្រលាញ់ណាបង។]*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:២១:១៩]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញ លោកស្រីបានពិភាក្សាអំពីការរស់នៅជាមួយប្ដី ជាមួយនឹងមនុស្សស្រីម្នាក់។ លោកស្រីអាចបញ្ជាក់បានទេ មនុស្សស្រីនេះ ជាអ្នកណា?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** នេះ ដែលខ្ញុំបាននិយាយជាមួយនេះ ខ្សែវីដេអូនេះ គឺហ្នឹងជាបងៗថ្លៃរបស់ខ្ញុំកាលសម័យ

ខ្មែរក្រហម ចាស។

**ស៖** បាទ សូមអរគុណ។ លោកស្រីបាននិយាយថា ប្តីរបស់លោកស្រីស្លាប់ឈ្លប។ អ៊ីចឹង លោកស្រីអាចបញ្ជាក់បានទេ ប្តីលោកស្រីហ្នឹងឈ្មោះអ្វី? ហើយដែលលោកស្រីនិយាយថា ប្តីលោកស្រី គាត់ស្លាប់ឈ្លបហ្នឹង លោកស្រីចង់និយាយថាយ៉ាងដូចម្តេច?

**ឆ៖** ពេលដែលឃើញចេញមកពីធ្វើការរៀងៗខ្លួន ឃើញមុខគ្នា គឺគាត់ស្លាប់ឈ្លប គេដឹងថា ថ្ងៃរៀបការ គាត់ស្លាប់ឈ្លបឲ្យធ្វើបាបចំពោះនាងខ្ញុំ ឃើញស្លៀកខោច្រើនជាន់អ៊ីចឹង គឺឈ្លបគេរាយ-ការណ៍មកថា ឲ្យធ្វើបាបទាល់តែបាន។ ចាប់រំលោភយ៉ាងម៉េចឲ្យទាល់តែបាន។ អាហ្នឹងគាត់ស្លាប់ឈ្លប មែន ចាស។

[១៤:២៣:០៥]

**ស៖** ចុះទីការដែល -- តើគាត់បានធ្វើអ្វីខ្លះទៅលើលោកស្រី? ប្តីរបស់លោកស្រីឈ្មោះអ្វី? អម្បាញ់មិញ ខ្ញុំស្តាប់អត់បាន។ បញ្ជាក់បន្ថែម ហើយគាត់បានធ្វើអ្វីខ្លះលើលោកស្រី ជាក់ស្តែងពេល នោះ?

**ឆ៖** កាលនោះ ប្តីខ្ញុំហ្នឹងឈ្មោះ តក់ សាត ហើយដល់ពេលគេស្តាប់ឈ្លបអ៊ីចឹង យប់ឡើងគេ ចាប់រឹតធ្វើបាបនាងខ្ញុំតាំងយប់ទី១ តែខ្ញុំបានសំពះអង្វរគេ។ ខ្ញុំបានស្លៀកខោពីរជាន់កុំឲ្យធ្វើបាបខ្ញុំ ហើយ ក៏គេចេះតែធ្វើបាបយើងតទៅ ក៏ថ្ងៃហ្នឹងក៏មិនបានធ្វើអ្វីខ្ញុំដែរ គេគ្រាន់តែបានចាប់ទះ ចាប់តប់រូបរាង កាយរបស់នាងខ្ញុំ។ ក្នុងពេលហ្នឹង ក៏ខ្ញុំសូមអង្វរគេ យំ អង្គុយយំអង្វរគេអ៊ីចឹងទៅ គេក៏ដេកលក់ទៅ។ គ្នា ក៏អស់កម្លាំងដែរ ធ្វើការក៏ពេលហ្នឹងទល់ម៉ោងពីរភ្លឺហ្នឹង គឺមានមេកងគេផ្តុកញ្ចែ នាងខ្ញុំចុះទៅទៀត ហើយចាស រួចបានមួយយប់ហ្នឹងទៀត។

**ស៖** លោកស្រីនិយាយអំពីកន្លែងដែលគេឲ្យដេកនៅជាមួយគ្នា លោកស្រីអាចបញ្ជាក់បានទេ កន្លែងដែលគេឲ្យដេកនៅជាមួយ នៅទីកន្លែងណាដែរ?

**ឆ៖** ចាស នៅភូមិដើមរកា ចាស គេធ្វើល្វែងអ៊ីចឹង គេចែក។ គេធ្វើដូចម៉ារីយ៉េ ទាហានអ៊ីចឹងក៏ គេខណ្ឌៗ មួយបន្ទប់ៗ គេចងស្បូវឲ្យពីរបីកណ្តាបៗអ៊ីចឹងទៅ ហើយរនាបគេនុំង គឺឫស្សីដកម៉ែយើង ឫស្សីព្រៃហ្នឹង កំពឹកកំពក ៗគេរែងដូចជាព្រួលអ៊ីចឹង គេយកមកឲ្យពួកខ្ញុំដេកក្នុងពេលនុំងឯង។ ហើយ គេបានធ្វើបាបយើង ចាប់បង្ខំយើង ក្នុងពេលហ្នឹងឯង ចាស។

**ស៖** គូដទៃទៀត ១១គូផ្សេងទៀត លោកស្រីមានដឹងថា ពួកគាត់ស្នាក់នៅកន្លែងណាដែរទេ

01365443



យប់ទី១?

[១៤:២៥:៣៤]

**ឆ៖** ចាស លោកប្រធាន យប់ទី១ គឺការហើយ គេរៀបបន្ទប់ហ្នឹង មួយជួរហ្នឹង គេមានផ្ទះគេវែងអ៊ីចឹងទៅ ដូចការដ្ឋានអ៊ីចឹង ក៏គេបាំងខាំង១ឲ្យគ្រប់១២បន្ទប់ គឺសម្រាន្តនៅទីហ្នឹងទាំងអស់។ ខ្លះ ក៏គេបានហៅកសាងទៅយប់ ខ្លះក៏ភ្លៀងមកអ៊ីចឹងទៅ គឺមានការលំបាក លោកប្រធាន។

**ស៖** បាទ សូមអរគុណ។ លោកស្រីមុនហ្នឹង លោកស្រីមានប្រសាសន៍ថា លោកស្រីមិនព្រមរួមដំណេកជាមួយគេទេ។ ហើយនៅក្នុងវីដេអូ លោកស្រីមានបានសួរទៅមេកង អ៊ុំ ហ្នឹងដែរទេថា បើលោកស្រីមិនព្រមរួមដំណេកហ្នឹង គេធ្វើអ្វីខ្លះលើលោកស្រី? លោកស្រីមានបានពិភាក្សាអំពីបញ្ហាហ្នឹងជាមួយមេកង អ៊ុំ ហ្នឹងដែរឬទេ ហើយគាត់បានឆ្លើយយ៉ាងម៉េចជាមួយលោកស្រី?

**ឆ៖** ចាស មានចម្លើយគាត់ មានលោកប្រធាន។ គាត់ថា៖ "បើសិនជារៀបការហើយ គេកសាងមិត្តឯង ទៅជាមួយដង យប់ទី១ យប់ទី២ គេកសាង តែយប់ទី៣ គឺគេសម្លាប់មិត្តឯងចោលហើយ" ហ្នឹងមានចាស។ ចង់១ឲ្យឃ្លីបវីដេអូហ្នឹង លោកចាក់ទៅចប់ គាត់និយាយហ្នឹង គាត់ថាត្រូវតែគេសម្លាប់ខ្ញុំចោលនឹងយប់ទី៣ ចាស។

**ស៖** បាទ អ៊ីចឹង ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីចាក់ឃ្លីបវីដេអូ ផ្នែកមួយនៃវីដេអូដដែលស្តីពី "អាពាហ៍ពិពាហ៍ក្រហម"នោះ ដែលជាឃ្លីបវីដេអូទី៣ ដែលមាននាទីពី៣៨នាទី០៥វិនាទី ដល់ ៤០នាទី ២១វិនាទី ដែលវីដេអូនេះនិយាយអំពីការពិភាក្សារបស់លោកស្រីជាមួយនឹងលោកស្រី -- ដើមបណ្តឹងរដ្ឋប្បវេណី ជាមួយនឹងលោកស្រី អ៊ុំ ដែលជាមេកងហៅលោកស្រីទៅរៀបការនោះថា បើសិនបើលោកស្រីមិនព្រម ថាតើនឹងមានអ្វីកើតឡើង។ ដូច្នេះសូមលោកប្រធាន អនុញ្ញាតឲ្យខាង អេ.វី ចាក់វីដេអូទី៣ ដែលខ្ញុំបានប្រគល់ជូនទៅខាង អេ.វី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ផ្នែកខាង អេ.វី ចាក់ផ្សាយឃ្លីបវីដេអូតាមសំណើសុំរបស់សហមេធាវីការពារក្តី -- សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[១៤:២៨:២៤]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*[សុចាន់៖ ការហើយ ម៉េចបានគេអត់ឲ្យយើងមិនព្រមអី ម៉េចក៏ធ្វើបាបយើង ខ្ញុំឆ្ងល់ណាស់*

កាលនុ៎ង?" អ៊ុំ៖ ចុះខ្ញុំអត់ដឹងដែរ។ សុចាន់៖ ព្រោះគេថា បើយើងមិនព្រមចុះសម្រុងគ្នា គេវាយខ្ញុំចោល។ អ៊ុំ៖ ហ្នឹងហើយ ខ្ញុំអត់ដឹងដែរ ត្រង់ហ្នឹង។ សុចាន់៖ ហើយគេឱ្យល្ពបតាមស្តាប់ខ្ញុំ។ តើហ្នឹង គេមានន័យថាម៉េច? អ៊ុំ ៖ អត់ដឹង ខ្ញុំអត់ដឹងៗថាគេមានន័យយ៉ាងម៉េច ខ្ញុំអត់ដឹង។ សុចាន់៖ ហ្នឹង គ្រាន់ថាបើយើង-- អ៊ុំ៖ ហ្នឹង ដូចថា គេឱ្យយើងព្រមព្រៀងគ្នាទៅ ព្រោះយើងបានជាគេរៀបការឱ្យហើយ។ ម៉េចដែរ? សុចាន់៖ "ចាស អ៊ីចឹងៗ បើបងឯងខ្វះខាត ខ្ញុំជួយបំពេញ។ គេឱ្យល្ពបទៅតាមស្តាប់ខ្ញុំអ៊ីចឹង ដល់ពេលថាយប់នេះ ខ្ញុំអត់ត្រូវគ្នា ត្រូវគេអូសយកវាយចោល ក៏មាន។ គេអូសយើងទៅរៀនច្បាប់ ឬមួយកសាងពីលើកទី១ ទី២ ដល់ទី៣។ តើអ៊ីចឹងពាក្យខ្ញុំនិយាយហ្នឹង ពិតឬអត់បង? អ៊ុំ៖ ពិត និយាយហ្នឹង ពិតហើយ។ សុចាន់៖ គេកសាងយើង សមមិត្តឯង មួយយប់ហ្នឹង មួយដង។ អ៊ុំ៖ ហ្នឹងហើយ មួយដង។ សុចាន់៖ យប់ទី២ គឺមួយដង។ អ៊ុំ៖ យប់ទី៣-- សុចាន់៖ យប់ទី៣ បើសិនអត់នេះ-- អ៊ុំ៖ បើអត់ទេ-- សុចាន់៖ គេវាយចោល។ អ៊ុំ៖ គេវាយយើងចោលហើយ។ សុចាន់៖ តើពាក្យហ្នឹង ពិតដែរអត់? អ៊ុំ ៖ ពិត ចាស ពាក្យហ្នឹងពិតហ្នង។ តែយើងរៀបការហើយ គេទៅតាមស្តាប់ហើយ ល្ពបអីអូន។ សុចាន់៖ គេលបស្តាប់យើង។ អ៊ុំ៖ គេទៅលបស្តាប់យើងហើយ ចាំមើល៍យើងវាអាចចុះសម្រុងគ្នាអត់ អូន អាចយើងថា ស្រឡាញ់គ្នាជាប្តីប្រពន្ធអត់។ បើយើងអត់ទេ គេកសាងយើងហើយ។ សុចាន់៖ កសាងគម្រប់បីដង--។ អ៊ុំ៖ គេៗអាចកសាងយើងទាំងយប់ហ្នឹង ឬចាំស្អែកក៏បាន។ ក្នុងយប់ទី១។ សុចាន់៖ គេអូសទាំងយប់ហ្នឹង យប់ទី១។ អ៊ុំ ៖ "ហ្នឹងហើយ យប់ទី១។ សុចាន់៖ យប់ទី២-- អ៊ុំ៖ យប់ទី២ គេតាមដានយើងទៀត។ យប់ទី៣ បើយើងអត់ព្រមព្រៀងគ្នាទេ គេចាប់យើងយកទៅធ្វើបាប ធ្វើ-- សុចាន់៖ ទៅវាលឬមួយគេវាយចោល។ អ៊ុំ៖ --ទុក្ខ ធ្វើទោសអី ទៅកន្លែងកសាងខ្លួនអ៊ីចឹងណ៎ាអូន ភូមិវាលអី វាលថ្នាងអ៊ីចឹងណ៎ា។ សុចាន់៖ សមមិត្តបងដូចថាធ្វើមេកងស្រាប់អ៊ីចឹងហើយ បើសិនជាយើងគេកសាង មិនមែនថាគេលើកលែងឱ្យទេ បើសិនជាគេកសាង ដូចថារៀបការនេះ ខ្ញុំតាមចិត្តខ្ញុំ ត្រូវតែគេយកវៃចោល។ បងឯងដែលឃើញផ្ទាល់ទេ ការហើយ ដែលសល់អត់ ខ្ញុំសួរបងឯង? អ៊ុំ៖ ចុះអាហ្នឹង ខ្ញុំដូចថាហ្នឹងហើយ យើងអត់ស្រឡាញ់ មកពីយើងអត់ស្រឡាញ់ របស់ដែលយើងមិនស្រឡាញ់។ សុចាន់៖ គេយកទៅវៃចោល? អ៊ុំ៖ អ៊ីចឹងទេអូន? សុចាន់៖ចាស។ អ៊ុំ៖ ដោយចាប់បង្ខំ។ ដោយរបស់ដែលយើងអត់ស្រឡាញ់ យើងសុខចិត្តស្លាប់អូន។ មែនអត់? សុចាន់៖ គេយកវៃមែនអត់? អ៊ុំ៖ មែនអត់? យើងអត់ស្រឡាញ់ គេវៃចោល វៃទៅ ឱ្យវាចប់រឿង មិនអ៊ីចឹង?"]

(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[១៤:៣០:៥១]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោកស្រីដើមបណ្ដឹង នៅឃ្លាចុងក្រោយរបស់លោកស្រី អុំ អម្បាញ់មិញ លោកស្រីប្រហែលជាបានឮហើយនិយាយថា "យើងអត់ស្រឡាញ់ បើយើងអត់ស្រឡាញ់ ដោយចាប់បង្ខំ ឱ្យរបស់ដែលយើងអត់ស្រឡាញ់ យើងសុខចិត្តស្លាប់អូន។ មែនអត់? យើងអត់ស្រឡាញ់ ឱ្យគេវាយចោលវាយទៅ ឱ្យវាចប់រឿង"។ លោកស្រីមានអ្វីអធិប្បាយអំពីឃ្លារបស់លោកស្រី អុំ នេះដែរឬទេ?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ឃ្លាសម័យនុ៎ង គឺដូចគាត់និយាយអ៊ីចឹង បើមិនស្រឡាញ់ គឺមិនដេក គេសម្លាប់ក្នុងពេលហ្នឹង គេធ្វើបាបទារុណកម្ម ដូចជារូបនាងខ្ញុំ។ យប់ទី១ គេកសាងខ្ញុំ យប់ទី២ ឱ្យខ្ញុំរត់ទៅបានពួជួយ តែយប់ទី៣ ខ្ញុំដឹងថា ខ្លួនខ្ញុំពេលនេះបែកម៉ែបែកឪហើយ ខ្ញុំថាខ្ញុំស្លាប់ហើយ។ បើអ៊ីចឹងទេ ខ្ញុំទ្រាំញាក់ ដេកនៅក្នុងបន្ទប់នោះ រួចហើយ ប្ដីខ្ញុំនោះ គ្រប់យប់ទី៣ គឺគេមកធ្វើបាបខ្ញុំ។ ចាប់នាងខ្ញុំចងដៃ ហែកខោខ្ញុំអស់--

[១៤:៣២:០២]

**ស៖** ខ្ញុំសូមកាត់លោកស្រីបន្តិច ដោយសារលោកស្រីមានអារម្មណ៍រំជួល ខ្ញុំចង់ត្រឡប់មកវិញ តើប្ដីរបស់លោកស្រីហ្នឹងមានគេណែនាំអំពីការរួមដំណេកជាមួយគ្នាទេ នៅមុនដែលជួបគ្នានៅក្នុងយប់ទី១ ហ្នឹង?

**ឆ៖** យប់ទី១ គេណែនាំប្ដីនាងខ្ញុំឱ្យធ្វើបាបខ្ញុំដូចពាក្យខ្ញុំនិយាយពីមុនអ៊ីចឹងលោកប្រធាន។

**ស៖** តើប្ដីនោះបានធ្វើបាប ខ្ញុំយកពាក្យរបស់លោកស្រីហ្នឹង ប្ដីរបស់លោកស្រីហ្នឹងបានធ្វើបាបលោកស្រីទេ នៅយប់ទី១ ហើយគាត់បានធ្វើអ្វីខ្លះ?

**ឆ៖** ចាស គេបានចាប់ដៃខ្ញុំ គក់ខ្ញុំ ហែកខោហែកអាវនាងខ្ញុំ ប៉ុន្តែថ្ងៃនុ៎ង ខ្ញុំបានស្លៀកខោពីរជាន់មានលោកប្រធាន ហើយអាវគេហែកអស់ហើយចាស។ ហ្នឹងយប់ទី១។

**ស៖** តើការរួមដំណេកបានសម្រេចដែរឬទេ?

**ឆ៖** យប់ទី១ គឺអត់ទេ លោកប្រធាន។

**ស៖** ហេតុអ្វី?

**ឆ៖** ខ្ញុំបាន -- ខ្ញុំ នាងខ្ញុំបានសំពះអង្វរគេ ក្រោកឡើងអង្គុយសំពះអង្វរគេអ៊ីចឹងទៅ ក៏គេដេក

លក់ទៅចាស ហើយក៏ម៉ោងពីរ គេផ្ដុំកញ្ចៃ នាងខ្ញុំក៏ចុះទៅតម្រង់ជួរមុនគេចាស។

[១៤:៣៤:០៨]

**ស៖** បន្ទាប់ពីយប់ទី១ នេះមក នៅថ្ងៃបន្ទាប់ស្អែកឡើង តើមានអ្វីកើតឡើងចំពោះលោកស្រីដែរឬទេ?

**ឆ៖** នោះដល់យប់ទី២ លោកប្រធាន មាន។ គេធ្វើបាបតទៀត តែបាន--

**ស៖** សូមទោសៗ ខ្ញុំអត់ចូលដល់យប់ទី២ទេ។ ពេលថ្ងៃ អំឡុងពេលថ្ងៃបន្ទាប់ពីយប់ទី១ ហ្នឹង តើមានអ្វីកើតឡើងចំពោះលោកស្រីដែរឬទេ?

**ឆ៖** ចាស មានលោកប្រធាន គឺសមមិត្ត អ៊ុំ ហ្នឹង កសាងខ្ញុំ។ ខ្ញុំចេះតែអង្វរគេទៅ ចាស។ នៅពេលថ្ងៃ គេប្រាប់ខ្ញុំថា មានឈ្លបលបចាំមើលនៅខាងមុខ ហើយអ្នកឯងអត់បានដេកជាមួយគ្នាទេ គេដឹងទៀត។ ខ្ញុំក៏ឆ្លើយតបថា ខ្ញុំ ឲ្យខ្ញុំសូមទោសអីចឹងទៅ ក៏គេអនុគ្រោះឲ្យខ្ញុំធ្វើការតទៀត លោកប្រធាន។

**ស៖** ក្រៅពីការអនុគ្រោះហ្នឹង សមមិត្តអ៊ុំ – នារីអ៊ុំ ហ្នឹង គាត់មានបានណែនាំអ្វីផ្សេងទៀត ដល់លោកស្រីទេ អំពីការរួមដំណេក?

**ឆ៖** ចាស មាន។ គាត់ថា បានយប់ទី១ និងយប់ទី២ យប់ទី៣ ប្រយ័ត្នស្លាប់ខ្លួន។ មាន ចាស។ ដូចគាត់និយាយនៅក្នុងឃ្លីបវីដេអូហ្នឹងអីចឹង ចាស។

[១៤:៣៦:០៣]

**ស៖** តើក្រៅពីសមមិត្ត នារីអ៊ុំ ហ្នឹង តើមានអ្នកផ្សេងទៀត មានណែនាំលោកស្រីដែរឬទេ នៅពេលថ្ងៃនោះ?

**ឆ៖** ចាស មាន។ គឺមានតែមិត្តអ៊ុំ ហ្នឹងឯង បើប្រុស គេណែនាំខាងប្រុស។ ស្រីគេណែនាំខាងស្រី លោកប្រធាន។

**ស៖** អីចឹង ខាងប្រុស ខាងប្ដីរបស់លោកស្រី តើមាន លោកស្រីមានដឹងថា ប្ដីលោកស្រីត្រូវបានគេហៅទៅណែនាំដែរឬទេ? ហើយបើហៅ គេណែនាំថាយ៉ាងដូចម្ដេចខ្លះ?

**ឆ៖** នោះ ខ្ញុំអត់បានដឹងទេ គឺខាងប្រុស គេអត់ឲ្យដើរជិតគ្នាទេ សម័យនោះ។ ខ្ញុំអត់ដឹងថា គេកសាងយ៉ាងម៉េច ខ្ញុំអត់ដឹងទេ។ អាហ្នឹង ជារឿងខាងប្រុស។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចូលដល់យប់ទី២ មានអ្វីកើតឡើង?

**ឆ៖** ចាស នៅយប់ទី២ មានទៀត មានកើតឡើងចំពោះរូបខ្ញុំ គេវៃតប ហែកខោហែកអាវទៀត ក៏ខ្ញុំសុំអង្វរគេ ក៏គេមិនស្ដាប់ដែរ។ ក៏យប់មួយ យប់ហ្នឹង ក៏មានពូខ្ញុំ គាត់រៀបការសម័យហ្នឹងដែរ គាត់ដេកទន្ទឹមខ្ញុំ ក៏គាត់មកសុំអង្វរប្ដីខ្ញុំហ្នឹងថា កុំឲ្យធ្វើបាបវា។ ចុះបើវានៅតូចយ៉ាងហ្នឹង បើអ្អែងវៃវាល់តែយប់ អីចឹងងាប់ហើយ។ ខ្មែរដូចគ្នា កុំធ្វើបាបវាអីអូន។ ហ្នឹងបានមួយយប់ទៀតទៅ ខ្ញុំទៅដេកជាមួយពូ។ ប្រហែលជាគាត់រាយការណ៍ទៅឲ្យឈ្លបហើយ បានយប់ទី៣ហ្នឹងគេធ្វើបាបខ្ញុំ ចាសលោកប្រធាន។

[១៤:៣៨:០៦]

**ស៖** លោកស្រីមានប្រសាសន៍ថា លោកពូហ្នឹងក៏រៀបការ ហើយដេកនៅជិតគ្នា។ លោកស្រីអាចបញ្ជាក់អំពីឈ្មោះរបស់ពូហ្នឹងបានទេ ហើយនិងគូដែលជាប្រពន្ធរបស់ពូហ្នឹង ឈ្មោះអ្វីដែរ?

**ឆ៖** ចាស គាត់ឈ្មោះ ពូខុម លោកប្រធាន។ គឺភរិយាគាត់ គឺឈ្មោះមីងអាន។ ចាស លោកប្រធាន។

**ស៖** ពួកគាត់នៅរស់ដល់សព្វថ្ងៃដែរទេ?

**ឆ៖** ចាស នៅ លោកប្រធាន។ ប្រពន្ធស្លាប់ហើយ ស្លាប់ខែមុន។ នៅប្ដី។

**ស៖** បាទ អរគុណ។ ខ្ញុំចង់សួរទៅដល់យប់ទី៣ តើមានអ្វីកើតឡើងចំពោះលោកស្រីជាមួយនឹងប្ដីរបស់លោកស្រីឈ្មោះ សាត ហ្នឹង?

**ស៖** ចូលដល់យប់ទី៣ សម្ដីសមមិត្តប្រធាន អុំ ក៏ខ្ញុំចងចាំថា យប់ទី៣ គឺយប់ដែលខ្ញុំត្រូវស្លាប់ដល់ពេលនោះ ខ្ញុំក៏ចូលរួមដំណេក ដេកនឹងគេ ក៏ខ្ញុំមិនព្រមដែរ លោកប្រធាន។ ខ្ញុំគ្រាន់តែចូលទៅ ខ្ញុំស្លៀកខោពីរជាន់។ ដល់ពេលហើយ ឈ្លបមកបីនាក់។ ឈ្លបមកបីនាក់ គេឈរឲ្យចងដៃខ្ញុំទៅជាប់នឹងសសរ សសររោងហ្នឹងទៅក្រោយទៅ ហើយក៏គេចាប់សម្រាតខោ សម្រាតអាវខ្ញុំអស់ នៅយប់ទី៣ ចាស។ គេរំលោភខ្ញុំបានសម្រេច រួចហើយក៏ខ្ញុំធ្លាក់ឈាមជាប់ជាងមួយខែជាង លោកប្រធាន។

[១៤:៤០:២៣]

**ស៖** ឈ្លបហ្នឹងមានគ្នាប៉ុន្មាននាក់? ហើយឈ្លបហ្នឹងជាអ្នកណាដែរជា -- តើជាមនុស្សដដែលក្នុងចំណោមប្រាំនាក់ដែលលោកស្រីនិយាយថាបានចូលរួមនៅក្នុងពេលពិធីរៀបការហ្នឹងដែរឬក៏អត់ទេ?

**ឆ៖** ចាស ឈ្លបទាំងប្រាំនាក់ហ្នឹងដដែល គេប្រចាំការនៅតាមកងអីចឹងគេចល័ត កងនេះ កងនោះ មួយថ្ងៃកងនេះ មួយថ្ងៃកងនោះ គេចល័តយប់ឡើងគេចល័តតាមដាន។ គឺៗជាល្បែងលេងសើចរបស់គេ ដើរលប ដើរស្ដាប់តែអ្នកដេកនៅជាមួយគ្នាអីចឹងឯងជាទូទៅ ជារឿងរបស់គាត់។

**ស៖** តើមាននរណាគេបាននិយាយប្រាប់លោកស្រីថា ពេលយប់ទី១ ទី២ មានឈ្លបមកលប ស្តាប់សកម្មភាពរបស់លោកស្រី និងប្តីរបស់លោកស្រីដែរឬទេ?

**ឆ៖** គ្មានអ្នកណាប្រាប់ទេលោកប្រធាន គឺជញ្ជាំងដែលពួកខ្ញុំដេកគ្មានជិត គឺមើលឃើញដេក គឺគេឈររថ្ងៃចាប់ខ្ញុំយប់ទី៣ គឺគេឈរមើលទាំងអស់គ្នានៅហ្នឹងឯង។ ឈរទាំងប្រាំនាក់ឈរមើលឲ្យធ្វើបាបអីចឹង បើសិនជាធ្វើបាបហើយយើងនៅអីចឹងទៀតប្រហែលជាថ្ងៃនេះជាថ្ងៃខ្ញុំស្លាប់។ នៅយប់ទី៤ ក៏ខ្ញុំរត់ទៅរកម្តាយលោកប្រធាន។

**ស៖** ក្រៅពីឈរមើល ឈ្លបទាំងនោះមានបាននិយាយអ្វីទេ?

**ឆ៖** គ្មានគេនិយាយក្រៅពីរឿងអាសភាសហ្នឹងលោកប្រធាន គេថាធ្វើអីចឹងបានល្អ ពួកឯងធើកូនជូនបក្ស តែប៉ុណ្ណឹងឯង ហើយគេសើច ហើយក៏គេដើរចេញ។

**ប្រធានអង្គជំនុំ៖**

បាទ បាន១។ បាទ អរគុណ។

ហើយឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខី-កម្មក្នុងបន្ទប់សវនាការនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹង។

**សួរដោយលោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីព្រមទាំងដើមបណ្តឹងរដ្ឋ

ប្បវេណីសាជាថ្មី។

**ស៖** ខ្ញុំសូមបន្តសំណួរទៅលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ មុនពេលសម្រាកលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីបានលើកពីឃ្លារបស់ឈ្លបម្នាក់ក្នុងចំណោមប្រាំនាក់ ដែលបាននិយាយមុនគេចេញពីកន្លែងដែលលោកស្រីដេកចេញទៅ។ ឃ្លានោះលោកស្រីបាននិយាយថា "គាត់ថាធ្វើអ៊ីចឹងបានល្អ ធើកូនជូនអង្គការ។" នៅពេលដែលគាត់និយាយថាធើកូនជូនអង្គការហ្នឹង លោកស្រីអាចយល់ទេថាគាត់ចង់និយាយថាយ៉ាងដូចម្ដេច?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ឃ្លាដែលសម័យនោះពួកឈ្លបនិយាយ កាលខ្ញុំរៀបការក៏គេថាឲ្យការយកកូនជូនអង្គការ។ ដល់ពេលគេតាមដានយើង យើងដេកនៅជាមួយគ្នាឈ្លបហ្នឹងក៏គេនិយាយថា ធ្វើអ៊ីចឹងល្អ យកកូនជូនអង្គការ។ ប៉ុន្តែចិត្តខ្ញុំថាដូចគ្មានឃើញកូនណាជូនអង្គការទេលោកប្រធាន គឺមួយគូបាត់ទៅ ពីរគូបាត់ទៅយូរៗអស់ពីកងក៏មានលោកប្រធាន អត់ឃើញបានអ្នករៀបការហ្នឹងបង្កើតកូនជូនអង្គការទេ ក៏គេយកទៅដាក់បង្កើតត្រង់ណា ក៏ខ្ញុំអត់ដឹងទេកាលនោះចាស។

[១៥:០៥:00]

**ស៖** តើពេលនោះលោកស្រីអាចបាននិយាយ -- អាចនិយាយបានទេប្ដីរបស់លោកស្រីបានធ្វើអ្វីខ្លះទៅលើលោកស្រីពេលយប់ទី៣ហ្នឹង លោកស្រីអាចនិយាយពីដំបូងបានទេ?

**ឆ៖** ចាស បានលោកប្រធាន។ យប់ទី៣ គេបានហែកខោហែកអាវខ្ញុំ ឈ្លបឈរមើលគឺខ្ញុំក៏មិនហ៊ានធ្វើអ្វីចំពោះគេដែរ ចាស ព្រោះដៃនាងខ្ញុំជាប់ចំណងហើយ អ៊ីចឹងគេសម្រាតយើងបាន រំលោភយើងបានតាមចិត្ត។ រួចក្រោយមក ក៏ខ្ញុំធ្លាក់ឈាមប្រហែលជាពីរខែ ទៅមួយខែជាងលោកប្រធាន។ ហើយពួកឈ្លបលួចមើលនោះគេថា អើ! ធ្វើអ៊ីចឹងបានល្អសម្រេចជូនអង្គការហ្នឹងឯង យកកូនជូនអង្គការ។ ខ្ញុំបានឮគេនិយាយតែប៉ុណ្ណឹង ហើយក៏គេសើចនាំគ្នាចេញទាំងប្រាំនាក់ទៅលោកប្រធាន។

**ស៖** តើលោកស្រីមានបានតដៃ ឬក៏ប្រតាយប្រតប់ជាមួយអ្នកណាទេពេលហ្នឹង?

**ឆ៖** ក្នុងពេលហ្នឹងមាន ដែលខ្ញុំអត់ឃើញឈ្លប ខ្ញុំបានតដៃនឹងគេ គេចាប់ខ្ញុំចងដៃខ្ញុំបានតដៃនឹងគេ ហើយក៏គេសង្កត់ដៃខ្ញុំមួយចំហៀងជាប់ ក៏គេទះកំផ្លៀងខ្ញុំមួយដៃទៅ ក៏ខ្ញុំងាកមុខមក ខ្ញុំឃើញឈ្លបខ្ញុំក៏សំងំទៅ ក៏គេចងដៃខ្ញុំជាប់ទៅសសរបាត់ហើយលោកប្រធាន។

**ស៖** លោកស្រីនិយាយថាឃើញឈ្លប ក៏លោកស្រីសំងំទៅ ពេលងាកមុខទៅឃើញឈ្លប។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហេតុអីក៏លោកស្រីសំងំ?

**ឆ៖** ព្រោះនោះ គេកសាងខ្ញុំយប់ទី២ -- យប់ទី១ មកដល់យប់ទី២ ដល់យប់ទី៣ខ្ញុំអាចនឹកឃើញថាថ្ងៃហ្នឹងហើយជាថ្ងៃខ្ញុំស្លាប់ បើអ៊ីចឹងទេ ខ្ញុំមានសិទ្ធិរើដែរ ប៉ុន្តែខ្ញុំអត់បានឃើញឈ្លប ដល់ខ្ញុំរើអ៊ីចឹង គេទះកំផ្លៀងខ្ញុំ ក៏គេជ្រែងខ្ញុំពីលើទ្រូង ក៏ដៃខ្ញុំគេចងទៅនឹងសសរទៅ នឹងជញ្ជាំងទៅ ហើយក៏គេសម្រាតខោ សម្រាតអាវខ្ញុំអស់នៅពេលហ្នឹង ពេលសម្រេចបានលោកប្រធាន។ ហើយក៏ឈ្លបឆ្លើយដូចខ្ញុំនិយាយពីមុនអ៊ីចឹង ចាស។

[១៥:០៧:២៩]

**ស៖** តើលោកស្រីមានការភ័យខ្លាចទេ ដែលគេមកមើល ហើយលោកស្រីឃើញឈ្លបអ៊ីចឹងមានការភ័យខ្លាចទេ ភ័យខ្លាចយ៉ាងម៉េចខ្លះ?

**ឆ៖** ក្នុងពេលហ្នឹង ខ្ញុំមានការភ័យខ្លាច ព្រោះខ្ញុំតូច ហើយខ្ញុំមិនដឹងថារត់ទៅរកអ្នកណាពឹង។ ដល់យប់ទី៣ យើងបានគេធ្វើបាបហើយ ដល់យប់ទី៤គេធ្វើបាបម៉េចទៀត ខ្ញុំគិតខ្លួនឯងញាក់ដូចកូនសត្វអ៊ីចឹងលោកប្រធាន។ ដល់ពេលយប់ទី៤ ខ្ញុំអត់បានដេកកន្លែងទេ ក៏ខ្ញុំអត់បានហូបបាយដែរ ខ្ញុំរត់ទៅរកម្ដាយ ទៅយប់ទី៤ ព្រោះពូបានយប់ទី២បានពូជួយ យប់ទី៣គ្មានអ្នកណាជួយខ្ញុំទេ ដល់គេកំណត់ហើយដល់យប់ទី៤ ខ្ញុំរត់ទៅរកម្ដាយខ្ញុំឲ្យម្ដាយជួយ ម្ដាយក៏បានតបមកវិញថា បើកូនរត់មករកម៉ែៗជួយម៉េចបាន បើគេការ ម៉ែក៏មិនដឹង ដល់ពេលកូនរត់មក កូនឃើញអត់? បងប្អូនដេករញ៉ង់ឃ្លានគ្មានអីស៊ី ហើយកូនបន្ថែមមកម្នាក់ទៀត បើសិនជាគេតាមមកសម្លាប់កូន គេសម្លាប់មួយពូជហើយ បើអ៊ីចឹងកូនត្រូវតែចេញទៅវិញ។ ខ្ញុំក៏ឆ្លើយទៅម៉ែថា ម៉ែអើយ ខ្ញុំឃ្លានណាស់ ខ្ញុំមកអត់មានហូបបាយទេ ខ្ញុំធ្វើការហើយៗខ្លួនខ្ញុំចេះតែធ្លាក់ឈាមតាំងពីយប់មកទល់ភ្លឺនេះ ធ្លាក់អត់បាត់ទេ។ គាត់ថាមានអីស៊ីកូន ម្ដាយខ្ញុំក៏ចុះទៅកាត់ទងល្ពៅយកមកស្រុសឲ្យខ្ញុំហូបជាមួយទឹកអំបិល។ ខ្ញុំក៏ហូបហើយឆ្ងាញ់ណាស់លោកប្រធាន ទឹកអំបិល និងទងល្ពៅផឹកទឹកទៅឆ្អែត ខ្ញុំចេញមករកមិត្តភក្តិខ្ញុំដែលចតឃ្លីបរឺឪអ្វហ្នឹងជាមួយចាស មាន។ អត់ហ៊ាននៅទេ ខ្លាចគេសម្លាប់ទាំងអស់ ទាំងបងទាំងប្អូន ខ្ញុំបានរត់ចេញមកវិញ ជីវិតខ្ញុំជូរចត់ណាស់។

[១៥:០៩:២៦]

**ស៖** លោកស្រីអាចបញ្ជាក់បានទេ មកទន្ទឹម រហូតទន្ទឹមដល់ថ្ងៃដែលលោកស្រីត្រូវបានគេធ្វើបាបយប់ទី៣ហ្នឹង មុនៗហ្នឹង ហើយលោកស្រីក៏បានបញ្ជាក់ថាលោកស្រីនៅក្មេងណាស់ អាយុមិនទាន់គ្រប់ការ លោកស្រីអាចបញ្ជាក់បានទេពាក្យ ខ្ញុំនិយាយដូចជាមិនសូវសមរម្យបន្តិច ក៏ប៉ុន្តែលោកស្រីធ្លាប់

មានមករដូវដែរទេរហូតដល់ពេលដែលថ្ងៃដែលលោកស្រីត្រូវបានគេឲ្យមករៀបការហ្នឹង?

**ឆៈ** ចាស លោកប្រធាន កាលនោះខ្ញុំនៅក្មេង អត់ដឹងថាមករដូវនោះយ៉ាងម៉េច គ្រប់រដូវនោះយ៉ាងម៉េច។ ខ្ញុំអត់ដឹង ខ្ញុំអត់យល់។ ដល់ពេលនោះ ខ្ញុំអត់មានរដូវអីនឹងមានដូចសម័យនេះ គឺខ្ញុំអត់មានទេ កាលនុ៎ង។ គេរំលោភខ្ញុំហើយ ខ្ញុំធ្លាក់ឈាមប្រហែលជាមួយខែជាង។ ខ្ញុំក៏បានផឹកថ្នាំខ្មែរ ម៉ែរកឲ្យក៏បាត់ទៅ។ ដល់តែពេលហ្នឹង ក៏ខ្ញុំចេញពីគាត់ទៀត។ តែប៉ុណ្ណឹងលោកប្រធាន។

**សៈ** លោកស្រី ពេលដែលលោកស្រីនៅជាមួយម្ដាយ បានរយៈពេលប៉ុន្មានដែរ បានលោកស្រីចេញបន្តទៅទៀត?

**ឆៈ** ខ្ញុំរត់ទៅរកម្ដាយ នៅមិនបានប្រហែលជាពីរម៉ោងផង ព្រោះគាត់តែស្រុសទងល្ពៅហើយខ្ញុំហូបហើយក៏ខ្ញុំចុះចេញ។ ខ្ញុំខ្លាចឈ្លបទៅតាមពួកខ្ញុំ។ ឃើញខ្ញុំ ខ្លាចគេចាប់ទាំងម៉ែទាំងឪសម្លាប់។ ដល់អ៊ីចឹង ខ្ញុំនៅជាមួយគាត់ប្រហែលជាពីរម៉ោង ឬបីម៉ោងតែប៉ុណ្ណឹងលោកប្រធាន។ ខ្ញុំរត់ចេញមកទៀត។

**សៈ** តើលោកស្រីមានដឹងដែរឬទេ មានឈ្លបទៅតាមលោកស្រីដែរឬទេ នៅពេលមុន ឬក៏ក្រោយពេលដែលលោកស្រីជួបម្ដាយ?

**ឆៈ** ដល់ពេលខ្ញុំចេញផុតមក ខ្ញុំអត់ដឹងថាឈ្លបទៅ ឬមិនទៅ។ កាលហ្នឹង យើងមិនមានខ្សែរយៈទាក់ទងទេ លោកប្រធាន ព្រោះគេមិនឲ្យយើងស្គាល់ម្ដាយ ម្ដាយក៏មិនឲ្យពេលយើងនៅជាមួយគាត់។ គាត់ភ័យខ្លាចស្លាប់ ចាស។

**សៈ** ក្រោយមកទៀត លោកស្រីមានធ្លាប់ម្ដាយលោកស្រីនិយាយប្រាប់ទេ នៅពេលបែកហើយបែកខ្មែរក្រហមហើយ តើមានធ្លាប់ម្ដាយលោកស្រីនិយាយប្រាប់ទេថា មានឈ្លបមកតាមរកលោកស្រី?

**ឆៈ** ក្នុងពេលនុ៎ង ខ្ញុំអត់បានជួបគាត់រហូតទាល់តែបែក ដល់សន្តិភាពបានខ្ញុំរកគាត់ឃើញលោកប្រធាន។

[១៥:១២:២៥]

**សៈ** ពេលសន្តិភាពហ្នឹង ក្នុងអំឡុងពេលសន្តិភាពហើយនេះ ដែលលោកស្រីជួបម្ដាយរបស់លោកស្រីនេះ ម្ដាយលោកស្រីមានធ្លាប់និយាយថា មានឈ្លបមកតាមរកលោកស្រីដល់ផ្ទះដែរឬទេ?

**ឆៈ** នៅក្នុងនោះគឺមាន។ តែកាលនុ៎ង ខ្ញុំអត់ចង់និយាយពីជីវប្រវត្តិរូបខ្ញុំទេ។ គាត់គ្រាន់តែថាកាលខ្មែរក្រហម កូនរៀបការ ឃើញឈ្លបគេទៅតាម។ តែចៃដន្យអី ឈ្លបហ្នឹងចាប់មនុស្សយកទៅ

សម្លាប់ ដែលបានអ្នកជនដែដល់ ដូចថាឃាតករគាត់ រងគ្រោះ ជនរងគ្រោះហ្នឹង គាត់មានសៀតកាំបិតនៅខ្លួនគាត់ហ្នឹង ក៏គាត់ចាក់ មិតខូ ហ្នឹងស្លាប់ទៅ។ គាត់ថាគាត់បានរួចខ្លួន។ ដែលតាមទៅរកខ្ញុំហ្នឹង កុំតែមិត្តហ្នឹងស្លាប់ គឺគាត់ក៏ស្លាប់ជំនាន់ហ្នឹងដែរ។ តែ មិត្តខូ ហ្នឹងក៏គាត់ស្លាប់បាត់ទៅ។ តែគេស្លាប់នៅកន្លែងណា គឺខ្ញុំអត់ដឹងទេ។ គ្រាន់ឮថាម្ដាយខ្ញុំបាន មិត្តសាត ហ្នឹងចាក់ស្លាប់ ដែលនាំមនុស្សទៅសម្លាប់ហ្នឹង មានតដែជាមួយឈ្លប បុកចំដើមទ្រូងមួយកាំបិត ហើយនិងគល់ត្រៀកមួយកាំបិត គឺឈ្លបហ្នឹងដែលទៅតាមខ្ញុំហ្នឹងគឺងាប់ ស្លាប់ក្នុងពេលសង្គ្រាមហ្នឹងដែរ ចាស មានគេតដៃគ្នា។

**ស៖** លោកស្រីអម្បាញ់មិញបាននិយាយពី មិត្តសាត។ មិត្តសាតហ្នឹងជាប្ដីរបស់លោកស្រី ឬក៏ជាអ្នកណា? ដែលលោកស្រីនិយាយអម្បាញ់មិញហ្នឹង ដែលតដៃជាមួយឈ្លបហ្នឹងអ្នកណាគេ?

**ឆ៖** គាត់ជានៅកន្លែងពាណិជ្ជ។ ខ្ញុំបានត្រឹមតែស្គាល់គេ ហើយក៏ឮសួរថាម្ដាយខ្ញុំនិយាយឈ្មោះហ្នឹង ចាស បានចាក់សម្លាប់ អាខូ ហ្នឹងងាប់ទៅ។ “បើសិនណាគេកុំចាក់ងាប់ ម៉ែស្លាប់តាំងពីសម័យកូនឯងរត់មករកម៉ែម្ល៉េះ” តែប៉ុណ្ណឹងលោកប្រធាន។ ហ្នឹងខ្ញុំបានឮផ្ទាល់ពីត្រចៀកខ្ញុំ ចាស។

**ស៖** បាទ អរគុណ។ ខ្ញុំអត់បានសួរពីដំបូងអំពីពេលវេលាដែលលោកស្រីត្រូវបានបង្ខំឲ្យគេរៀបការទេ។ លោកស្រីអាចបញ្ជាក់បានទេ ពេលវេលាដែលលោកស្រីត្រូវបានគេបង្ខំឲ្យរៀបការហ្នឹង ពេលណាដែរ? ហើយប្រៀបធៀបទៅនឹងពេលដែលបែកខ្មែរក្រហម ចូលដល់សន្តិភាពនេះ ថាតើពីពេលរៀបការហ្នឹងមកប៉ុន្មានខែ?

**ឆ៖** ចាស ខ្ញុំអត់យល់ លោកប្រធាន បញ្ជាក់ម្ដងទៀត ចាស។

**ស៖** រហូតទៅដល់ពេលដែលវៀតណាមចូល មានន័យថាបែកខ្មែរក្រហម១៩៧៩នេះ តើលោកស្រី ពេលដែលលោកស្រីរៀបការ បើប្រៀបធៀបទៅនឹងពេលហ្នឹង គឺលោកស្រីរៀបការនៅប៉ុន្មានខែមុនពេលដែល ០៧ មករា ១៩៧៩?

[១៥:១៥:៣៧]

**ឆ៖** ចាស លោកប្រធាន កាលនុ៎ង ប្រហែលជាចុងឆ្នាំ វៀតណាមចូល។ បើសិនដើមឆ្នាំ គឺខ្ញុំស្លាប់ហើយ។ ចុងឆ្នាំ វៀតណាមចូល កាលនុ៎ងយើងគ្មានចេះអក្សរ ហើយក៏យើងគ្មាននាឡិកាណា មានទូរស័ព្ទណាសម្រាប់មើលថ្ងៃខែ ដែលយើងចងចាំបានទេ លោកប្រធាន គឺខ្ញុំសន្និដ្ឋានខ្លួនខ្ញុំ ប្រហែលជាបើមិន៥ខែ ទៅ៦ខែ ហ្នឹងវៀតណាមចូល ចាស ដែលខ្ញុំរៀបការហើយ។

**ស៖** បាទ អរគុណ។ ខ្ញុំសួរសំណួរបន្ថែម ប្រហែលជា៥នាទីទៀតជូនដល់លោកស្រី ហើយ

បន្ទាប់មក ខ្ញុំនឹងសុំអនុញ្ញាតលោកប្រធាន ផ្ទេរជូនអ្នកបន្ត សហព្រះរាជអាជ្ញា។ លោកស្រីអាចនិយាយបានទេ នៅពេលសម័យខ្មែរក្រហម លោកស្រីមានធ្វើការអ្វីខ្លះដែរ ការងាររបស់លោកស្រី?

**ឆ៖** ក្នុងសម័យខ្មែរក្រហម ពីមុន ពីខ្ញុំចេញពីម្ដាយ គេយកខ្ញុំទៅដាក់កងកុមារ។ ខ្ញុំនៅកងកុមារហ្នឹងហើយ គេថាខ្ញុំនេះ ពេញវ័យហើយ ធំហើយ គេយកខ្ញុំទៅនៅកងចល័ត។ ទៅនៅកងចល័តហ្នឹង បានប្រហែលជា៣ខែ ឬ២ខែទេ យើងស្មានទៅ ចិត្តខ្ញុំដែលស្មាន។ រួចកាល១ខ្ញុំចេញទៅ ស្រូវខ្ញុំ ខ្ញុំធ្វើ ដល់ពេលអ៊ីចឹងទៅ ខ្ញុំថាប្រហែលជា៣ខែ ទៅនៅនឹងកងចល័ត។ គេប្រើខ្ញុំឲ្យលាយជីអាចម៍ និងជាមួយនឹងអាចម៍គោ ចាក់ទឹកចូល។ ដល់ពេលនោះ ខ្ញុំអត់បានធ្វើតាមវាទេ ព្រោះខ្ញុំខ្ពើមដែរ ព្រោះលាមក សុទ្ធតែដង្កូវ ហើយអាចម៍គោ ក៏សុទ្ធតែដង្កូវ អ៊ីចឹងវាឲ្យយើងកូរនឹងដៃ។ គេថា "អ៊ីចឹង សមមិត្តឯង មិនធ្វើផ្ទាល់ដៃ អ៊ីចឹង ចាត់តាំងមក មិត្តឯងប្រកែកឬ យកឈើកូរ។ ខ្ពើមអី អ៊ីចឹង១ហ្នឹង។" សមមិត្តអ៊ុំ ក៏លើកចបវាយនាងខ្ញុំនេះ នៅខ្នងក្បាល ទំពែកដល់សព្វថ្ងៃ អត់បានដុះសក់ទេ។ ហើយជើងរបស់នាងខ្ញុំ រលួយនឹងជាមួយជីអាចម៍ គ្មានសាច់បង្កើតទេ ចាស លោកប្រធាន។ រងកម្ម ប្រើខ្ញុំដួល ត្រឡប់ត្រឡិន។ គេជិះសេះវាយខ្ញុំ និងមិត្តអឿន ហ្នឹង។ គេមានសេះមួយ គឺខ្ញុំដើរយឺត ព្រោះជើងឈឺ។ គេវាយអ៊ីចឹងទៅ ខ្ញុំដួលទៅក្នុងភ្លឺម្ខាងទៅ គេក៏សេះហួសទៅ។ ដល់ពេលគេឃើញ សួរ វាថាវាធ្វើលេង។ នឹងពេលហ្នឹង គឺខ្ញុំអត់មានសាច់បង្កើតទេ ជើងទាំងស្ដាំ ទាំងឆ្វេងទាំងអស់ គ្មានសាច់ខ្ញុំបង្កើតទេ។ មានទាំងភស្តុតាង ហើយក្បាលអត់ដុះសក់ទេ លោកប្រធាន។

[១៥:១៨:៤៣]

**សៈ** បាទ ខ្ញុំចូលទៅសំណួរផ្សេងទៀត ពាក់ព័ន្ធទៅនឹងជីតា ឪពុក ហើយនិងពូរបស់លោកស្រី។ តើមានអ្វីកើតឡើងជាមួយនឹងពួកគាត់ដែរឬទេ ជីតា ឪពុករបស់លោកស្រី ហើយនិងពូរបស់លោកស្រី?

**ឆ៖** មាន ឪពុកខ្ញុំកាលនោះ គាត់ធ្វើទាហាន ហើយជីតារបស់ខ្ញុំ គាត់ធ្វើការនៅក្នុងវាំងស្ដេចយើងហ្នឹង ផ្ទះសម្បែងគាត់ គឺនៅច្បារអំពៅ លោកប្រធាន។ ឪពុកខ្ញុំធ្វើទាហាន គេបញ្ជូនតាំងពីព្រៃខ្មែររហូតទៅដល់ពោធិ៍សាត់។

**សៈ** តើមានអីកើតឡើងជាមួយពួកគាត់ទេ ពួកគាត់នៅរស់រានមានជីវិតទេ?

**ឆ៖** សម័យនេះ គ្មានឃើញគាត់ទេ ព្រោះកាលនោះ គេជម្លៀសចេញមក គេជម្លៀសគាត់ចេញមកពីពោធិ៍សាត់ គេយកគាត់មកដាក់នៅខ្នារទទឹង នៅឃុំខ្នារទទឹងហ្នឹង គេបានដាក់មីក្រូ គេធាក់មីក្រូ

កង់ៗហ្នឹង គេធាក់អ៊ីចឹង គេប្រកាសថា អ្នកណាដែលធ្វើទាហានស័ក្តិប៉ុន្មាន អ្នកណាធ្វើអ្វី ឯកសណ្ឋានចេញមក គេដឹកទៅធ្វើការនៅពោធិ៍សាត់វិញ ធ្វើទាហានតទល់ជាមួយខ្មាំងវិញ ហើយអ្នកណាចុះប្រវត្តិរូបធ្វើប្រវត្តិរូប ធ្វើការក្នុងវាំងនោះ ធ្វើខ្លួនយកខោអាវមក ទៅធ្វើការក្នុងវាំងវិញ ហើយតាខ្ញុំ គាត់លើកដៃមុនគេ ខ្ញុំនៅតូច ហើយពុកខ្ញុំ ក៏គាត់ឡើងស្លៀកពាក់ ឥវ៉ាន់អ៊ីចឹង ស្លៀកពាក់ខោអាវ គាត់តឹនុយទាហានហើយ ក៏ខ្ញុំនៅតូច ខ្ញុំថាខ្ញុំសុំទៅដែរ ក៏ម៉ែខ្ញុំចាប់ទាញខ្ញុំមកវិញ ឮខ្ញុំដឹង យ៉ាងម៉េចក៏ខ្ញុំមិនដឹងដែរ គ្រាន់ថា គេហៅគាត់ចេញទៅបាត់ តាមួយមកជើងមក ឪពុកខ្ញុំឡានមួយទៅត្បូងអ៊ីចេះទៅ។ អ៊ីចឹងខ្ញុំសន្និដ្ឋានថា មិនដឹងទៅណា។

[១៥:២០:៥៧]

**លោក ពេជ អង្គ៖**

បាទ ខ្ញុំអត់សំណួរហើយលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមអរគុណដែលលោកស្រីបានឆ្លើយនូវសំណួររបស់ខ្ញុំ។ សូមគោរពលោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ ជាបន្តនេះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារង តំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរដ្ឋប្បវេណីរូបនេះ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ អេនឌ្រូ ប៊ិយ ខ្ញុំមានសំណួរខ្លះដែលត្រូវសួរទៅលោកស្រីក្នុងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញាសម្រាប់រសៀលនេះ។ ខ្ញុំសូមសួរសំណួរលោកស្រីមួយសំណួរពីរសំណួរ<ពាក់ព័ន្ធនឹងវីដេអូឃ្លីប ដែលយើងបានមើលនោះ។> ប៉ុន្តែខ្ញុំមិនស្នើសុំឲ្យបញ្ចាំងវីដេអូនេះឡើងវិញទេ ដោយសារតែពេលវេលាខ្លី។ តើលោកស្រីអាចជម្រាបជូនតុលាការបានទេថា លោកស្រីនេះបានចូលរួមពាក់ព័ន្ធក្នុងការថតខ្សែវីដេអូនេះបានដោយរបៀបណាដែរ? ហេតុអីបានជាលោកស្រីមានវត្តមានចូលរួមថតខ្សែវីដេអូនេះ?

[១៥:២២:១៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស អង្គាល់មុន ខ្ញុំមុននឹងចូលខ្សែវីដេអូនេះ ខ្ញុំបានសម្ភាសនិយាយជាមួយអ្នកស្រីមេធាវីដាក់ដើមបណ្ដឹងពាក្យបណ្ដឹងកាលខ្ញុំនៅការ កាលពីសម័យខ្មែរក្រហមវ័យក្មេង លោកប្រធាន។

**ស៖** តើមេធាវីរបស់លោកស្រី គឺមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹងឬ ដែលណែនាំលោកស្រីឱ្យមានវត្តមានចូលរួមថតក្នុងខ្សែវីដេអូហៅថា "អាពាហ៍ពិពាហ៍ពណ៌ក្រហម" នេះ?

**ឆ៖** ចាស អត់ទេ គឺគ្រាន់តែខ្ញុំដាក់ពាក្យបណ្ដឹងតែប៉ុណ្ណោះ ដល់ប្រហែលជាគេធ្វើជាយ៉ាងម៉េចឃើញយើងការក្មេងអ៊ីចឹង គេធ្វើជាយ៉ាងម៉េច ក៏ខ្ញុំអត់ដឹងដែរ ដល់គេទៅសម្ភាសថត ក៏ខ្ញុំដាក់ដើមបណ្ដឹង ខ្ញុំដាក់ពាក្យបណ្ដឹងហើយ បានគេទៅថតខ្ញុំចាស។

**ស៖** តើវាមានកត្តាអ្វីដែលជំរុញឱ្យលោកស្រីនេះមានទឹកចិត្តចូលរួមនៅក្នុងការថតខ្សែវីដេអូនេះ?

**ឆ៖** ចាស ខ្ញុំមានកម្លាំងទឹកចិត្ត ព្រោះខ្ញុំបាត់បង់ច្រើន ខ្ញុំនឹកឃើញដល់ឪពុកស្លាប់ តាស្លាប់ ប្អូនស្លាប់ ខ្ញុំក៏នឹកឃើញ ក៏ខ្ញុំបានដាក់ពាក្យបណ្ដឹងតាមរយៈមេធាវីលោកស្រីឈ្មោះគាត់ សាវ៉ន។ ខ្ញុំបានដាក់ពាក្យបណ្ដឹងតាមគាត់ហ្នឹង ដល់ពេលហើយ ស្រាប់តែឃើញគេទៅសុំថតសុំអី ខ្ញុំក៏អត់បានដឹងថាយ៉ាងម៉េចដែរ លោកប្រធាន ក៏ខ្ញុំចេះតែតាមថតជាមួយគេទៅចាស។

[១៥:២៤:១៣]

**ស៖** សូមអរគុណ លោកស្រីបាននិយាយថា លោកស្រីអាយុប្រហែលជា១៥ ឬ១៦ឆ្នាំ នៅពេលដែលលោកស្រីរៀបការនោះ។ តើលោកស្រីដឹងថាអ្នកដែលលោកស្រីរៀបការជាមួយ គឺប្ដីរបស់លោកស្រីហ្នឹង តក់ សាត ហ្នឹងមានអាយុប៉ុន្មានដែរ ពេលរៀបការជាមួយលោកស្រី?

**ឆ៖** ចាស អាយុគេ ខ្ញុំដឹង គឺ២៥ឆ្នាំ លោកប្រធាន គឺខ្ញុំអាយុប្រហែលជា១៥, ១៦ឆ្នាំប៉ុណ្ណោះឯង។

**ស៖** តើលោកស្រីមានធ្លាប់បានស្គាល់ប្ដីរបស់លោកស្រីពីមុននោះមកឬទេ មុនពេលរៀបការនោះ?

**ឆ៖** ចាស អត់ទេ លោកប្រធាន មិនដែលឃើញមុខ ហើយក៏មិនដែលឃើញគាត់ធ្វើការនៅកន្លែងណា ក៏មិនដែលស្គាល់ដែរ ព្រោះមនុស្សកាលសម័យនោះ គេមិនដែលឱ្យមនុស្សប្រុស និងមនុស្សស្រីនៅជាមួយគ្នាទេ ចាស។ ប្រហែលជា៣គីឡូដីពីគ្នា បាននៅបាន ចាស។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានឬទេ ខ្ញុំបានសួររឿងនេះ ប៉ុន្តែសូមពន្យល់ទៅតុលាការផង ថាហេតុអ្វីបានជាលោកស្រីរៀបការជាមួយបុរសម្នាក់ដែលលោកស្រីមិនស្គាល់?

[១៥:២៥:៥៩]

**ឆ៖** ខ្ញុំបានប្រកែកដែរ សម័យហ្នឹង គេថា អង្គការកំណត់ លោកប្រធាន។ ទោះបីខ្ញុំមិនចង់រៀបការ ក៏ត្រូវតែការ។

**ស៖** សក្ខីកម្មរបស់លោកស្រីដំបូង ដែលលោកស្រីបាននិយាយថា គេគំរាមយកលោកស្រីយកទៅអប់រំកែប្រែ បើសិនណាជាបដិសេធមិនព្រមរៀបការ។ ខ្ញុំសូមអានផ្នែកមួយនៃពាក្យពេចន៍នៅក្នុងពាក្យសុំ គឺ E3/6034b, ERN អង់គ្លេស 01143732, ខ្មែរ 01049458។ លោកស្រីបានឆ្លើយថា៖ “ខ្ញុំត្រូវបានគេបង្ខំឲ្យរៀបការ ប្រសិនណាបើខ្ញុំបដិសេធ គេនឹងយកខ្ញុំទៅសម្លាប់ចោល។ អ៊ុំ ហើយនិងអឿន គឺបង្ខំឲ្យខ្ញុំរៀបការ។” បញ្ចប់ការដកស្រង់។ តើលោកស្រីអាចបញ្ជាក់ជូនតុលាការបានទេ ថាតើគេគំរាមកំហែងយកលោកស្រីទៅអប់រំកែប្រែ ឬក៏គំរាមយកទៅសម្លាប់ចោល ឬក៏គេគំរាមទាំងពីរចំណុចនេះ?

[១៥:២៧:២៨]

**ឆ៖** កាលនុំងសម្តីមិត្តអ៊ុំ ហ្នឹង បានមកកាន់នាងខ្ញុំថា កងប្រវត្តិសាស្ត្រគេរិលទៅមុខ មិត្តឯងមិនអាចឈប់បាននៅក្នុងនេះ គំរូមិនល្អ។ ត្រូវតែរៀបការ។ បើអ្នកឯងមិនរៀបការ អ្នកឯងមានតែស្លាប់។ ចាស លោកប្រធាន។

**ស៖** តើលោកស្រីដឹងថាមានអ្នកដទៃត្រូវបានគេគំរាមកំហែងយកទៅអប់រំកែប្រែ ឬក៏ដាក់ទណ្ឌកម្មណាមួយ ក្នុងករណីដែលអ្នកទាំងនោះ បដិសេធមិនព្រមរៀបការតាមការរៀបចំរបស់គេដែរឬទេ លោកស្រីស្គាល់អ្នកណាដែរទេ?

**ឆ៖** ហ្នឹងថ្ងៃនោះមួយ គឺបានរៀបការហើយ គឺដេកជុំគ្នាទាំងអស់ ទាំង១២គូហ្នឹង។ ខ្ញុំឃើញម្នាក់ឈ្មោះ ខុម ប្តីឈ្មោះ មុត។ ពេលគេមកហៅ គឺគាត់យំឱបខ្ញុំហើយ គាត់ថា បងដល់ពេលគេសម្លាប់ហើយ ព្រោះបងមិនបានដេកចូលគ្នាទេ។ ហើយខោអាវហ្នឹង ដេកជាមួយគ្នា។ ដេកជាមួយខ្ញុំហ្នឹង ដល់ពេលហើយ អត់ឃើញមកយកខោអាវហ្នឹងវិញ ក៏បាត់ខ្លួនទាល់តែសព្វថ្ងៃ ចាស មិនដឹងគេទៅណា។ ឃើញបាត់មួយគូហ្នឹង។ ដល់ក្រោយគូទីប៉ុន្មានទៀត គឺ៣ថ្ងៃហ្នឹង បាត់មួយគូ, ៤ថ្ងៃ គឺបាត់មួយ, ៥ថ្ងៃ គឺបាត់មួយគូ។ អ៊ីចឹងបានខ្ញុំថា ប្រហែលជាគេទៅណា ក៏ខ្ញុំមិនដឹង។ គេថា ចេះតែទៅកសាង ទៅវាល

ខាង។ ខ្ញុំសួរបងអ៊ុំ ហ្នឹង គាត់ឆ្លើយខ្ញុំ ទៅវាលខាង។ ដូចគាត់ឆ្លើយនៅក្នុងឃ្លីបវីដេអូហ្នឹង អ៊ីចឹងចា៎។

[១៥:២៩:៣២]

**ស៖** ចុះអ្នក<ផ្សេងទៀត?> លោកស្រីទើបលើកឡើងមកនិយាយ <បុគ្គលម្នាក់>ដែលគេយកទៅចេញទៅបាត់ដោយសារថាមិនបានរួមដំណេក<ក្រោយរៀបការ>។ លោកស្រីបានបញ្ជាក់ដែរហ្នឹងថាពីដំបូងនោះ គឺលោកស្រីបានបដិសេធមិនព្រមរៀបការ ហើយគេគំរាមកំហែងដែរ។ អ៊ីចឹងសំណួររបស់ខ្ញុំសួរថា លោកស្រីមានស្គាល់អ្នកណាម្នាក់ដែល<ពីដំបូងបដិសេធមិនព្រមរៀបការ ហើយត្រូវបានគេគំរាមកំហែង ឬក៏>ត្រូវគេចាត់វិធានការដាក់ទណ្ឌកម្មអប់រំកែប្រែ ដោយសារតែការបដិសេធមិនព្រមរៀបការដែរទេ?

**ឆ៖** កាលនោះ សម័យខ្មែរក្រហមទណ្ឌកម្មឃើញគេវៃ ឃើញគេសម្លាប់ ឃើញគេចងអូសនឹងសេះ អាហ្នឹងខ្ញុំមើលឃើញក៏ខ្ញុំមិនហ៊ានសួរកាលហ្នឹងខ្ញុំនៅវ័យក្មេង ប៉ុន្តែមេកងគេលើកឡើងគេយកគំរូឱ្យយើងមើល។ អ៊ីចឹងពេលប្រជុំអីគេលើកឡើងថា សមមិត្តណារឹងទទឹង សមមិត្តណារឹងនឹងកងប្រវត្តិសាស្ត្រគេកំពុងវិល គឺមិត្តហ្នឹងដូចមិត្តនោះអ៊ីចឹងឯង។ តែគេនិយាយប៉ុណ្ណឹងមក ខ្ញុំអត់ហ៊ានបញ្ជាក់ទៀតទេលោកប្រធាន គ្រាន់តែស្តាប់នៅពេលអង្គប្រជុំអ៊ីចឹងគេប្រជុំប្រាប់អ៊ីចឹង គឺយើងអត់ហ៊ានសួរថាម៉េចបានធ្វើដូចមិត្តហ្នឹង គឺក្រុមប្រជាពលរដ្ឋរងគ្រោះគ្មានហ៊ាន មានសិទ្ធិសួរទេលោកប្រធាន។

**ស៖** ខ្ញុំយល់ហើយ។ លោកស្រីបានលើកឈ្មោះបុគ្គលពីរបីនាក់យកមកនិយាយ ហើយនៅក្នុងឃ្លីបវីដេអូក៏មានការលើកឡើងដែរ ខ្ញុំចង់លើកឡើងចំណុចខ្លះៗ ពីព្រោះថាអាចមានការយល់ច្រឡំរវាងសំឡេងប្រុសស្រីដែលនេះតាមការបកប្រែជាភាសាអង់គ្លេស យើងមិនដឹងប្រុស ឬក៏ស្រីជាអ្នកនិយាយ។ អ៊ីចឹងតាមដែលខ្ញុំយល់គឺប្រធានកងរបស់លោកស្រី គឺប្រធានកងរបស់លោកស្រីជាស្រីទេ ហើយគាត់ឈ្មោះ អ៊ុំ នៅក្នុងខ្សែវីដេអូហ្នឹងមែនទេ?

[១៥:៣១:៣៨]

**ឆ៖** ជាមនុស្សស្រីហ្នឹងលោកប្រធាន ឈ្មោះ អ៊ុំ ចាស។

**ស៖** ហើយ អ៊ុំ នេះគឺជាប្រធានកងរបស់លោកស្រីមែនទេ?

**ឆ៖** ចាស លោកប្រធាន។

**ស៖** ហើយបុរសដែលឃើញនៅក្នុងឃ្លីបវីដេអូហ្នឹងឈ្មោះ អឿន ហើយ អឿន នេះគឺធំជាង អ៊ុំ ឋានៈធំជាង អ៊ុំ ត្រឹមត្រូវដែរក៏អត់ទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ចាស គាត់ធ្វើធំជាង បងអ៊ុំ។

**ស៖** លោកស្រីក៏បានឆ្លើយពីខាងដើមថា លោកស្រីបានទទួលព័ត៌មានពី អឿន ដែលថាលោកស្រីត្រូវទៅនិយាយជាមួយនឹង <រឹម> អំពីការទទួលបញ្ជាឲ្យរៀបការនេះ បើចង់ដឹងទៅសួរ <រឹម> ទៅ។ ហើយបើតាមដែលខ្ញុំដឹង រឹម នេះគឺជាស្ត្រី ហើយជាលេខាស្រុក ឬក៏ហៅថា ចៅហ្វាយស្រុក បាកាន អ៊ីចឹងមែនទេ?

**ឆ៖** ចាស គាត់ក្ដោបក្ដាប់ប៉ុន្មានសហករណ៍លើគាត់។ ចាស ចៅហ្វាយស្រុក ក្ដោបក្ដាប់។ ប្រហែលជាប្រាំប្រាំមួយសហករណ៍ដឹងលោកប្រធាន ព្រោះកាលហ្នឹងយើងនៅក្មេង អត់ដឹងថាគេធ្វើអ្វី ប៉ុន្តែយើងដឹងថាពី ទៅសួរគេៗឲ្យទៅសួរ មិត្តរឹម ហ្នឹងអ៊ីចឹងក៏ៗខ្ញុំថា ខ្ញុំធ្លាប់ស្គាល់អ៊ីចឹងដែរចាំ។ មិនមែនថាទេ គឺស្គាល់គាត់។ ខ្ញុំបានទៅសួរមិត្ត រឹម ហ្នឹងដល់ៗផ្ទះរបស់គាត់។

[១៥:៣៣:៤៤]

**ស៖** តើសមមិត្តនារី រឹម នេះឬដែលនិយាយទៅកាន់លោកស្រីថា គាត់ទទួលបានបញ្ជាហ្នឹងពី តាម៉ុក?

**ឆ៖** ចាស លោកប្រធាន គាត់ថាមកកាន់ប្រសាសន៍មកខ្ញុំ គាត់ថា "បើអែងចង់ដឹង ទៅសួរ តាម៉ុក ងាប់ ឬរស់អញមិនដឹងទេ ទៅកាយខ្មោចសួរក៏បានដែរ ព្រោះ អាម៉ុក ហ្នឹងវាអ្នកចាត់ចែងឲ្យធ្វើ" គាត់ថា។

**ស៖** តើ រឹម មានបានប្រាប់លោកស្រីថា គាត់ទទួលបានបញ្ជា<>ពី តាម៉ុក <ពាក់ព័ន្ធនឹងការរៀបការនៅក្នុងស្រុកបាកាន ដែរឬទេ>?

**ឆ៖** ចាស លោកប្រធាន គេអត់មាននិយាយល្អចំពោះយើងទេ គេអត់បានសារភាពថា ធ្វើអីក៏គេអត់បានធ្វើដែរចាស។ គេតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមកសាលាក្ដីខ្មែរក្រហមនេះដែរ។ នៅក្នុងឃ្លីបរីដែអូគឺ មានសម្ដីគាត់។

**ស៖** តើលោកស្រីស្គាល់ឈ្មោះដទៃទៀតទេ ដូចជាមានស្គាល់ឈ្មោះដទៃទៀតដែល យាយរឹម នេះគាត់លើកយកមកនិយាយដែរទេ?

**ឆ៖** ខ្ញុំអត់បានស្គាល់ទេលោកប្រធាន។ កាលហ្នឹងយើងអត់មានយកចិត្តទុកដាក់ចាស។

[១៥:៣៥:៣៤]

**ស៖** នៅក្នុងគឺឯកសារ E3/6034a, ERN អង់គ្លេស 00873734, បារាំង 01140085, ខ្មែរ

00579598។ លោកស្រីបានឆ្លើយសូមដកស្រង់៖ “អ្នកដែលបង្ខំឲ្យយើងហ្នឹងគឺឈ្មោះ នី, អឿន, អាត និង អ៊ុំ” បញ្ចប់ការដកស្រង់។ ខ្ញុំចាប់អារម្មណ៍ឈ្មោះបុគ្គលម្នាក់ឈ្មោះ អាត ដែលលោកស្រីនៅក្នុងពាក្យសុំនេះថាជាគឺជាស្រីបាទ។ តើឈ្មោះៗ <សេក> សំអាត ហៅ <យាយ>រឹម ដែលជាចៅហ្វាយស្រុកបាកានហ្នឹងមិនមែនទេ?

**ឆ៖** តា -- ខ្ញុំបាននិយាយគឺ នីរសាររបស់គាត់ចាស។ នីរសាររបស់ បងរឹម។ ខ្ញុំបាននាំនីរសារហ្នឹងទៅជាមួយគាត់ឆ្លើយថា គាត់មិនបានស្គាល់សមមិត្ត អាត ហ្នឹងទេ។

**ស៖** តើលោកស្រីដឹងទេថាគូស្រករទាំង១១គូ ដែលរៀបការនៅ<ថ្ងៃ>ជាមួយលោកស្រីហ្នឹងទាំង ខាងប្រុសទាំងខាងស្រីហ្នឹងមានធ្លាប់ដែលស្គាល់គ្នាដែរទេមុនរៀបការ?

**ឆ៖** ហ្នឹងដូចខ្ញុំបានបកស្រាយមកពីខាងដើមហើយលោកប្រធាន គឺអត់ដែលបានស្គាល់គ្នាទេលោកប្រធាន ព្រោះកន្លែងមិត្តនារីគេដាក់ប្រហែលជា៣គីឡូ។ ខាងប្រុសគេនៅឆ្ងាយអ៊ីចឹងទៅ គឺអត់បានស្គាល់គ្នាហើយក៏មិនបានពេញចិត្ត ហើយក៏គេមិនបានមកប្រាប់យើងថាមិត្តឯងនេះបានរៀបការជាមួយមិត្តនេះ។ ហើយមិត្តចាន់ បានរៀបការជាមួយមិត្ត តក់ សាត នេះ។ តើអ្នកឯងព្រមឬអត់ គឺគ្មានបានប្រាប់ទេលោកប្រធាន។ គឺគេចាប់ដាក់ៗគឺមកញ៉ាំហូបបាយទាំងអស់គ្នា ហូបទឹកបបរទាំងអស់គ្នា។ ហើយម៉ោងប្រាំ អ្នកៗអត់បានរៀបការគឺគេបានទៅញ៉ាំទឹកបបរហ្នឹងទៅ តែអ្នករៀបការអត់បានញ៉ាំទឹកបបរហ្នឹងទេចាស មួយកំប៉ុង២៥នាក់កាលហ្នឹងចាស។ នៅកងខ្ញុំមាន៤២នាក់ មួយខ្ទះឆ្នោតមានតែ ពីរកំប៉ុងទេចាស ហើយថ្ងៃការហ្នឹងគ្មានដឹងខ្លួន រៀបការហើយក៏អត់មានបាយហូបដែរចាស។

[១៥:៣៨:៣៤]

**ស៖** នៅរសៀលនេះលោកស្រីបាននិយាយថា លោកស្រីបានបដិសេធ មិនព្រមរៀបការទេពីដំបូងឡើយនោះ ប៉ុន្តែមានការគំរាមកំហែង នៅពេលនោះលោកស្រីនៅក្មេងមានការភ័យខ្លាច ហើយលោកស្រីគ្មានអារម្មណ៍អីជាមួយនឹងបុរសដែលលោកស្រីរៀបការជាមួយនោះទេ។ តើលោកស្រីអាចជម្រាបជូនតុលាការបានទេ ថាលោកស្រីមានអារម្មណ៍យ៉ាងដូចម្ដេចដែរចំពោះការរៀបការនេះ?

**ឆ៖** ចាសលោកប្រធាន ថ្ងៃនោះខ្ញុំនៅក្មេងអ៊ីចឹង គឺខ្ញុំនឹងចាញ់សំឡុតគេច្រើន ប៉ុន្តែគេគ្រាន់តែប្រាប់ខ្ញុំថាទៅកន្លែងហ្នឹងបានបាយហូបឆ្អែត។ ចាស ហើយបើសិនជាទៅគេបើកសំពត់ខោអាវឲ្យ។ ដល់ពេលខ្ញុំទៅឃើញខ្ញុំដៃជើងខ្ញុំរលួយ ដល់ពេលខ្ញុំទៅខ្ញុំចង់បានខោអាវ ដល់ពេលអ៊ីចឹងគេមិនមែនចែកខោអាវអី ខ្ញុំទៅឃើញគេតម្រៀបជួរហើយស្រេច ទន្ទឹមគ្នា ក៏យើងអត់ដឹងថាអ្នកណាគូណា ខាងស្រីក៏

យំខាងប្រុសក៏យំដូចគ្នារៀងខ្លួនៗ។ គូដែលចាប់តែពីរគូទាំងនាងខ្ញុំនោះ គឺគ្មានអ្នកណាមួយបានដឹងខ្លួនទុកជាមុនទេ ព្រោះបើដឹងខ្លួនមានខ្សឹបគ្នា មាននិយាយគ្នាប្រហែលជានាងខ្ញុំឮ ព្រោះធ្វើការជាមួយគ្នា។ ដល់ពេលចូលទៅដល់ម៉ោងប្រាំហ្នឹង អ្នកអត់រៀបការដូចខ្ញុំបានមានប្រសាសន៍ខាងដើមថា អ្នកអត់បានរៀបការគេបានទៅហូបទឹកបបរទៅ ដែលអ្នករៀបការហ្នឹងគេឲ្យទៅរៀបការសិន។ អ៊ីចឹងទេយើងអត់មានបានអីហូបទេ ការហើយ គេឲ្យមកដេក គឺខ្ញុំទៅសុំបបរគាត់។ នៅក្នុងឃ្លំបរិឌីអូហ្នឹងគឺមានហើយបងអ៊ុំ គាត់ថា បើគេបង្អត់ហើយ ឲ្យគាត់ទៅបានពីណា។ ខ្ញុំថាខ្ញុំឃ្លានណាស់ ខ្ញុំធ្វើការដែរ ម៉េចបានបង្អត់បាយខ្ញុំ។ គេថាបានមកពីណាជូនមិត្តឯង បើអស់ហើយ។ ចាស ហើយក៏គ្មានសិទ្ធិអីនឹងតវ៉ាដែរលោកប្រធាន។

[១៥:៤០:៣៤]

**ស៖** ឥឡូវនិយាយពាក់ព័ន្ធនឹងការរៀបការនេះផ្ទាល់តែម្តង តើលោកស្រីមានអារម្មណ៍យ៉ាងម៉េចដែរ មានអារម្មណ៍<សប្បាយចិត្ត ពិបាកចិត្ត> រំភើបញាប់ញ័រ ភ័យតក់ស្លុត ឬក៏យ៉ាងម៉េច អ៊ីចឹងអាចជម្រាបជូនតុលាការបានទេថាលោកស្រីមានអារម្មណ៍យ៉ាងម៉េចដែរចំពោះការរៀបការនេះផ្ទាល់តែម្តង?

**ឆ៖** ចាស អង្កាល់ហ្នឹង គេមិនប្រើសម្តីរៀបការនេះទេ កាលនោះគេឲ្យយើងទៅចាប់គូស្រករៀងៗខ្លួន តើមិត្តណាអង្គុយចំគូណា គឺបានគូហ្នឹង ខ្ញុំបានប្រកែកថាខ្ញុំអត់ទៅទេ ខ្ញុំអត់យកប្តីទេ ខ្ញុំអត់ដឹងខ្ញុំនៅតូចណាស់។ ដល់ពេលហើយ ក៏សមមិត្តអ៊ុំ ហ្នឹងសួរថា "នៅតូចក៏ដោយ មិត្តឯងគ្រប់ការនៅ?" ខ្ញុំក៏បានឆ្លើយតបទៅគាត់វិញដូចខ្ញុំនិយាយច្រំដែលដែរលោកប្រធាន ខ្ញុំបានថាខ្ញុំមិនទាន់គ្រប់ការ យ៉ាងណាខ្ញុំអត់ដឹងថាគ្រប់ការហ្នឹងយ៉ាងម៉េចទេ ខ្ញុំបានឆ្លើយអ៊ីចឹងដែរចាស។ គេសួរថាគ្រប់ការនៅ? ខ្ញុំសួរទៅគាត់វិញថាគ្រប់ការហ្នឹងយ៉ាងម៉េច? ព្រោះខ្ញុំអត់បានដឹងចាស។

**ស៖** ខ្ញុំជឿជាក់ថាពីខាងដើម។ លោកស្រីបាននិយាយថា នៅយប់ទី១ដែលគេឲ្យលោកស្រីដេកជាមួយប្តីរបស់លោកស្រី គេបានចងលោកស្រី ហើយវាយដំលោកស្រី អ៊ីចឹងមែនទេ ត្រឹមត្រូវទេ?

**ឆ៖** ចាស លោកប្រធាន យប់ទី១ គេមិនបានចងខ្ញុំទេចាស គ្រាន់តែបានវ៉ៃហែកខោ វ៉ៃហែកអាវចោល ក៏ខ្ញុំមានប្រសាសន៍នៅខាងហ្នឹងហើយ ខ្ញុំគ្រាន់តែថាគេបានចាប់ហែកអាវខ្ញុំ ខ្ញុំឡើងអង្គុយសំពះគេទៅ ក៏បានប្រតាយប្រតប់គ្នាហ្នឹង យប់យូរ ប្រហែលជាម៉ោងពីរ ក៏គេផ្លុំកញ្ចែ ខ្ញុំទៅឈរតម្រង់ជួរទៅធ្វើការទៅ ខ្ញុំអត់ទាំងបាយ អត់ទាំងបានដេក ចាស ថ្ងៃហ្នឹង។

[១៥:៤២:៥០]

**ស៖** លោកស្រីលើកឡើងពីខាងដើមថាប្ដីរបស់លោកស្រីបានទទួលការណែនាំឲ្យលោក -- បង្ខំលោកស្រីដើម្បីរួមដំណេកជាមួយ។ តើការបង្ខំនេះ គឺការដែលគេប្រាប់ប្ដីលោកស្រីហ្នឹងគេប្រាប់តាំងពីយប់ទី១ហ្នឹងឬ?

**ឆ៖** ចាស តាំងពីយប់ទី១ លោកប្រធាន។

**ស៖** ហើយចុះអ្នកណាជាអ្នកណែនាំមកប្រាប់ប្ដីលោកស្រីនេះ?

**ឆ៖** ពួកឈ្លបទាំងប្រាំនាក់ហ្នឹង ចាស។

**ស៖** ហើយតើលោកស្រីៗមានបានស្ដាប់ លបស្ដាប់ឮគេបង្គាប់ទៅប្ដីលោកស្រីនិយាយថាអ៊ីចឹងឬ?

**ឆ៖** កាលនោះ ខ្ញុំភ័យខ្លាចពេក ខ្ញុំស្ដាប់ឮខ្លះ អត់ខ្លះលោកប្រធាន។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានទេ លោកស្រីលបស្ដាប់គេនិយាយឮថាដូចម្ដេចដែរ?

**ឆ៖** ខ្ញុំឮគ្រាន់តែថាបើចាប់ដៃគ្នាហើយ គេមិនបានប្រើពាក្យរៀបការទេ លោកប្រធាន គេគ្រាន់តែថាបានចាប់ដៃគ្នា គឺប្ដីប្រពន្ធហើយ ត្រូវតែចាប់រំលោភឲ្យបាន ខ្ញុំឮតែប៉ុណ្ណឹងលោកប្រធាន ហើយក៏ខ្ញុំភ័យញ័រញាក់ដូចកូនកណ្ដុរបាត់ហើយ ខ្ញុំនៅតូចដែរ ព្រោះយើងចាំម៉ោងចាំពេលអត់បាន ចាស។

[១៥:៤៤:៤៦]

**ស៖** លោកស្រីបានលើកឡើងពីខាងដើមថា <នៅយប់ទី១> លោកស្រីបានដឹងថាឈ្លបនោះមកលបស្ដាប់ <និងតាមដាន>លោកស្រី ហើយលោកស្រីអាចមើលឃើញតាមប្រហោងជញ្ជាំងខ្ទមដែលលោកស្រីដេកហ្នឹង។ តើលោកស្រីបានឃើញឈ្លបហ្នឹង មកលបស្ដាប់នៅខាងក្រោម <ឬក៏ជិត> ខ្ទមហ្នឹង <ដែលលោកស្រីស្នាក់នៅជាមួយប្ដីរបស់លោកស្រី ឬ>?

**ឆ៖** ចាស ខ្ទមហ្នឹងធ្វើមិនបានខ្ពស់ទេ មិនចូលពីក្រោមទេ គឺនៅឈរពីជញ្ជាំងហ្នឹង វាធ្លាក់រហេករហែកពេញហ្នឹង។ យើងមិនបានថាប្រុងប្រយ័ត្នយ៉ាងណានឹងបិទបាំង។ គេឃើញ គឺក្រឡេកទៅគឺឃើញហើយ លោកប្រធាន។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ នៅថ្ងៃបន្ទាប់ អ៊ុំ ដែលជាមេកងរបស់លោកស្រី បាននិយាយជាមួយលោកស្រី ហើយប្រាប់លោកស្រីថាឈ្លបនេះបានមកប្រាប់គាត់ថា លោកស្រីហ្នឹងមិនបានរួមដំណេក

ជាមួយប្ដីលោកស្រីទេ អ៊ីចឹងមែនឬ?

**ឆ៖** ចាស ដែលល្ងាចហ្នឹងបានទៅប្រាប់ មិត្តអ៊ុំ ហ្នឹងអ៊ីចឹងមែន។ ឲ្យកសាងខ្ញុំលោកប្រធាន។

**ស៖** លោកស្រីថា នៅយប់ទី២ហ្នឹង គឺប្ដីរបស់លោកស្រីបានវាយដំលោកស្រី និងហែកខោអាវរបស់លោកស្រី។ តើការវាយដំ និងការហែកខោអាវរបស់លោកស្រីហ្នឹង គឺក្នុងគោលបំណងដើម្បីរួមដំណេកជាមួយលោកស្រីឬ?

**ឆ៖** ចាស លោកប្រធាន ដើម្បីរួមរ័ខ្ញុំ រួមដំណេកជាមួយ។ តែយប់ទី២ គាត់អត់បានខ្លួនខ្ញុំដែរ បានពូគាត់អង្វរថា បើអ្វែងវ៉ែវាតែយ៉ាងនេះងាប់ហើយ ធ្វើការយប់ផង ថ្ងៃផង។ គាត់ក៏បានសំពះ មិត្ត តក់ សាត ហ្នឹងក៏គេបានស្ដាប់។ គាត់ក៏បានដេកជាមួយ តក់ សាត ហ្នឹងមួយយប់។ ខ្ញុំមកដេកជាមួយប្រពន្ធគាត់បានមួយយប់ រួចខ្លួនបានយប់ទី២លោកប្រធាន ចាស។

[១៥:៤៧:១១]

**ស៖** តើលោកស្រីមានបានដឹងថា ប្ដីរបស់លោកស្រីមានត្រូវបានគេហៅទៅប្រជុំនៅកន្លែងណាមួយដែរទេ មុននឹងឈានចូលដល់យប់ទី២នោះ?

**ឆ៖** គឺភ្លឺឡើងខាងប្រុស គេទៅធ្វើការខាងប្រុស ខាងស្រីធ្វើការខាងស្រី លោកប្រធាន។ អត់ដឹងថា គេកសាងគាត់ ឬក៏គេធ្វើបាបគាត់យ៉ាងណានោះ ខ្ញុំអត់បានដឹងទេលោកប្រធាន ព្រោះឆ្ងាយពីគ្នាប្រហែលជា៣គីឡូ ទៅ២គីឡូ ចាស។

**ស៖** ប្រហែលជាសំណួរមិនច្បាស់ ខ្ញុំសុំអានសម្រង់មួយចេញពីឯកសាររបស់លោកស្រី គឺ E3/6034b, ERN អង់គ្លេស 01143726, ខ្មែរ 01049450។ នេះគឺអ្វីដែលលោកស្រីបានឆ្លើយនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ សុំដកស្រង់៖ “នៅថ្ងៃទី២ គេហៅប្ដីខ្ញុំទៅប្រជុំ។ ក្រោយពេលគាត់ត្រឡប់មកវិញ គាត់បង្ខំខ្ញុំរួមដំណេក។ ពេលខ្ញុំបដិសេធ គាត់ទះកំផ្លៀងខ្ញុំ ហើយខ្ញុំព្យាយាមរត់ទៅរកពូខ្ញុំឲ្យជួយ។” បញ្ចប់ការដកស្រង់។

តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកស្រីបានដែរឬទេ <ថា>ប្ដី របស់លោកស្រីត្រូវ<>គេហៅទៅប្រជុំ។ ហើយ<ក្រោយពីត្រឡប់មកពីប្រជុំវិញ គាត់បានទះកំផ្លៀងលោកស្រី និងប៉ុនប៉ងបង្ខំលោកស្រីឲ្យរួមដំណេក?>

**ឆ៖** អង្គាល់នុំង ខ្ញុំបាននិយាយមែន ប៉ុន្តែខ្ញុំនិយាយមានពីរចំណុចលោកប្រធាន។ ខ្ញុំថា ខ្ញុំមិនបានមើលឃើញគេកសាង ឬគេហៅគាត់ទៅណែនាំអ្វីមួយនោះទេ ព្រោះមកវិញគេធ្វើបាបខ្ញុំ ព្រោះ

កន្លែងនៅមិនបានជិតគ្នាលោកប្រធាន។ ខ្ញុំបានដាក់នៅពាក្យបណ្ដឹង គឺដាក់អ៊ីចឹងមែន ចាស។ ព្រោះមិនបានជិតគ្នា ខ្ញុំឆ្លើយហើយថា មិនដឹងគេធ្វើបាបគាត់យ៉ាងម៉េច ក៏ខ្ញុំអត់បានដឹងដែរ ចាស។

[១៥:៤៩:៣៦]

**ស៖** សូមអរគុណចំពោះការបញ្ជាក់បំភ្លឺនេះ។ លោកស្រីបានលើកឡើងថា នៅយប់ទី៣ គឺយប់ដែលលោកស្រីត្រូវបានប្ដីលោកស្រីរំលោភនោះគឺឈ្លបហ្នឹងឈរមើល។ ហើយលោកស្រីក៏បានលើកឡើងផងដែរថា ឈ្លបហ្នឹងបាននិយាយមកកាន់លោកស្រីថា "អើអ៊ីចឹងហើយ ធ្វើអ៊ីចឹងហើយ គឺថាដើម្បីបង្កើតកូនជូនអង្គការ ហើយពួកគេក៏បានសើច"។

ខ្ញុំសុំសួរលោកស្រី ប្រហែលជាចម្លែកបន្តិច ប៉ុន្តែតើមានឈ្លបណាម្នាក់<>មានបំណងចង់<ការពារលោកស្រី នៅពេលដែល>ប្ដីលោកស្រីរំលោភ <ឬក៏ក្រោយពេលរំលោភនោះ>ដែរឬទេ?

**ឆ៖** គឺគ្មានទេ គេឈរមើល គេសើច ហើយគេដើរចេញទៅ លោកប្រធាន គឺអ៊ីចឹងមែន។ គេស្រែកថា "អើអ៊ីចឹងបានធ្វើកូនបានជូនបក្ស" ហើយក៏គេសើចដើរចេញទៅ ចាស។

**ស៖** លោកស្រីបានឆ្លើយថា នៅពេលដែលលោកស្រីរត់ទៅផ្ទះម្ដាយលោកស្រី ម្ដាយលោកស្រីប្រាប់ឲ្យលោកស្រីត្រឡប់មកកងវិញ។ បើមិនដូច្នោះទេ បងប្អូនឪពុកម្ដាយ ទាំងគ្រួសារហ្នឹង ត្រូវគេយកទៅសម្លាប់ចោលហើយ។ តើ<ម្ដាយរបស់លោកស្រីបានប្រាប់លោកស្រីដែរឬទេថា គាត់គិតថា>លោកស្រី<អាចនឹងត្រូវគេសម្លាប់ចោល>បើលោកស្រីមិនត្រឡប់មករួមរស់ជាមួយប្ដីលោកស្រីវិញ<>?

**ឆ៖** កាលនោះ ខ្ញុំបាននិយាយអ៊ីចឹងមែន ព្រោះខ្ញុំបានរត់ទៅរកម្ដាយ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗឆ្លើយ។

[១៥:៥១:៣៧]

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន ខ្ញុំសូមបដិសេធចំពោះសំណួរនេះ ពីព្រោះវាជាសំណួរឧបមានវិធី ដែលសួរឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយស្មានទៅលើព្រឹត្តិការណ៍ដែលមិនមានកើតបែបនេះ។ សូមអរគុណ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

ប្រហែលជាមានបញ្ហាបកប្រែជាភាសាខ្មែរហើយ។ ខ្ញុំមិនបានសួរសំណួរឧបមានវិធីទេ ខ្ញុំយោង

ទៅសក្ខីកម្ម គឺសម្ដីដែលដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយពីមុននេះ ថាម្ដាយរបស់គាត់បានប្រាប់ថា បើនាងមិនត្រឡប់មករួមរស់ជាប្ដីវិញទេ ពេលហ្នឹង គឺថាបងប្អូននិងឪពុកម្ដាយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ នឹងត្រូវគេសម្លាប់ចោល។ ខ្ញុំសួរថា តើនៅពេលនោះ ម្ដាយរបស់គាត់ហ្នឹង មាននិយាយថា តើដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចនឹងត្រូវគេសម្លាប់ចោលដែរឬទេ?<ខ្ញុំមិនបានសួរសំណួរឧបមានវិធីនោះទេ។>

[១៥:៥២:៣៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺថាមិនមានពាក់ព័ន្ធនឹងសំណួរឧបមានវិធីទេ ខ្ញុំជឿថាចម្លើយនេះគឺត្រូវបានឆ្លើយរួចទៅហើយ <នៅមុនពេលដែលការជំទាស់ត្រូវបានលើកឡើង>។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលដែលម្ដាយរបស់លោកស្រីថា លោកស្រីត្រូវតែត្រឡប់មករស់ជាមួយប្ដីវិញ ក្រោយប្ដីលោកស្រីរំលោភលោកស្រីនោះ តើម្ដាយលោកស្រី មានប្រាប់លោកស្រីថា ជីវិតលោកស្រីហ្នឹង ក៏ត្រូវជួប<គ្រោះថ្នាក់>ដែរ <>បើមិនមករស់ជាមួយប្ដីវិញទេ មានប្រាប់អ៊ីចឹងទេ?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស បានប្រាប់អ៊ីចឹងមែន ហើយខ្ញុំប្រាប់គាត់ថា ខ្ញុំអត់ទាន់មានបាយហូបទេ គាត់ក៏បានស្រុសទងល្ពៅនោះ ឲ្យខ្ញុំហូបជាមួយទឹកអំបិល។ ខ្ញុំផឹកទឹកឆ្អែត ខ្ញុំក៏ឈរមើលឃើញប្អូន ឃើញបងដេកបាក់ពោះ ខ្ញុំនឹកឃើញថា ខ្ញុំត្រូវតែចុះចេញទាំងយប់មករកមិត្តភក្ដិ។ ចាស គាត់បានដេញចេញមែន។ ខ្ញុំអត់បាននិយាយថា សន្និដ្ឋានម៉ាត់ណា ក៏ខ្ញុំអត់ទាន់បាននិយាយទេ លោកប្រធាន។

[១៥:៥៤:00]

**ស៖** តើលោកស្រីដឹងទេ ហេតុអ៊ីបានម្ដាយរបស់លោកស្រី<ភ័យខ្លាចថា> បងប្អូន ទាំងប្រុសទាំងស្រី ឪពុកម្ដាយ រួមទាំងលោកស្រីហ្នឹង គឺថានឹងត្រូវគេយកទៅសម្លាប់ចោល បើលោកស្រីមិនវិល<ត្រឡប់ទៅរកប្ដីលោកស្រី>វិញទេ?

**ឆ៖** ចាស គាត់ដឹង ព្រោះប្ដីគាត់ទៅបាត់ហើយ អត់ឃើញមកវិញ។ បើអ៊ីចឹងគាត់ថា ប្អូនក៏នៅបងក៏នៅ ម៉ែក៏នៅ បើកូនមក គេអត់ដឹង កូនចេញទៅវិញសិនទៅ។ កូនរៀបការ ក៏ម៉ែអត់ដឹង។ ខ្ញុំ ម៉ែបានដេញ ខ្ញុំបានចេញវិញមែន លោកប្រធាន។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

ខ្ញុំស្តាប់អត់ឮមានការបកប្រែជាភាសាអង់គ្លេសទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ជាភាសាអង់គ្លេស គឺថាស្តាប់អត់ឮមានការបកប្រែទេ។

[១៥:៥៤:៥៨]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

<យើងអត់ទទួលបានការបកប្រែជាភាសាអង់គ្លេសទេ។>

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

<តើមីក្រូមានបើកដែរ ឬ>ទេ?

**<លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖>**

<មីក្រូដំណើរការ។ គឺថាមិនមានការបកប្រែ។>

*(មានបញ្ហាបច្ចេកទេស)*

[១៥:៥៥:២៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំយល់ឃើញថា<វាមិនមែនជាបញ្ហានោះទេ។> ដើមបណ្តឹងរដ្ឋប្បវេណី គាត់បានឆ្លើយហើយ ប៉ុនគ្រាន់ថា<យើងមិនទទួលបានការបកប្រែជាភាសាអង់គ្លេស>។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីស្តាប់ខ្ញុំឮទេ ឥឡូវនេះ? នៅតែ<>មិនមានការបកប្រែ។ <ខ្ញុំដឹងថា គាត់បានឆ្លើយហើយ-->

**លោកស្រី ប៉ែន សុចាន់៖**

ចាស! អត់រអាក់រអួលទេ គឺច្បាស់។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកស្រីចៅក្រម ហ្វេនស៍។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** បាទ ខ្ញុំសួរសំណួរចុងក្រោយរបស់ខ្ញុំឡើងវិញ ពីព្រោះខ្ញុំស្តាប់អត់ឮសួរចម្លើយទេ។ តើលោកស្រីមាន លោកស្រីមានដឹងទេថា ហេតុអីបានជាម្តាយលោកស្រី<ភ័យខ្លាច>ថា បើលោកស្រីមិន

ត្រឡប់<ទៅរកប្តីលោកស្រី>វិញទេ ពេលនោះបងប្អូនសមាជិកគ្រួសារទាំងអស់នឹងត្រូវគេសម្លាប់ចោល <រួមទាំងលោកស្រីផងដែរ>?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស គាត់ភ័យខ្លាច ព្រោះគាត់បាត់ប្តីគាត់ គាត់បាត់បងគាត់នឹងមុខៗគាត់ អត់ដែលឃើញវិលមកវិញ។ អ៊ីចឹងគាត់ថាកូនកុំបង្កហេតុរឿងដល់បងប្អូនទៀត បងប្អូនឪពុកគឺបាត់អស់ហើយ។ អ៊ីចឹងខ្ញុំគ្រាន់តែថា ខ្ញុំសូមហូបអីមួយម៉ាត់ ខ្ញុំហេវណាស់។ គាត់ក៏ចុះទាំងយប់ទៅវារបង្កាត់ កាត់ទងល្ពៅហ្នឹងមកស្រុសជាមួយទឹកអំបិលខ្លាចឃើញផ្សែង ខ្លាចឃើញភ្លើងទៀត គាត់ខ្លាចឃើញ។ អ៊ីចឹងគាត់មុននឹងធ្វើហ្នឹង គាត់រកស័ង្កសីបាំង អត់ឲ្យអណ្តាតភ្លើងហ្នឹងឃើញទេ ខ្លាចឈ្លបហ្នឹងមកតាមក្រោយខ្ញុំ។ ហើយធ្វើអីហូបអ៊ីចឹង គឺបានចាប់ទៅទាំងអស់ហើយ អ៊ីចឹងគាត់ធ្វើហើយអីហើយ ក៏ខ្ញុំស្រុស។ គាត់ចាក់អំបិលមក ខ្ញុំជ្រលក់ជាមួយគ្មានបបរ គ្មានបាយអីទេ។ ខ្ញុំជ្រលក់ជាមួយហើយ ខ្ញុំប្រាប់គាត់ ថាខ្ញុំឆ្ងាញ់ណាស់ម៉ែអើយ ដូចគុយទាវអ៊ីចឹង។ ក៏ខ្ញុំហូបហើយ ឲ្យខ្ញុំផឹកទឹកហើយ ក៏ខ្ញុំចុះចេញទៅ។ ខ្ញុំគោលដៅខ្ញុំអត់ដឹងទៅណាទេ គឺទៅរកមិត្តភក្តិ។ គឺមិត្តភក្តិខ្ញុំ មាននៅខ្សែវីដេអូឃ្លីបហ្នឹងមានចាស។ ដោយសារដំឡូងមួយដុំហ្នឹង។

[១៥:៥៧:៤៥]

**ស៖** លោកស្រីបានលើកឡើងនៅក្នុងខ្សែឃ្លីបវីដេអូទី៣ ដែលស្នើសុំឲ្យបញ្ចាំងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមដកស្រង់៖ "នៅយប់ទី៣ បើសិនណាលោកស្រីមិនចុះសម្រុងទេ គេនឹងចាប់លោកស្រីវាយទារុណកម្ម<។ លោកស្រីត្រូវបានគេធ្វើទារុណកម្មនៅ>ភូមិវាល<ឬវាលថ្នាង>ជាដើម។ល។" សូមបញ្ចប់ការដកស្រង់។ លោកស្រីក៏បានលើកឡើងអំពីទីតាំង<ទាំងអស់>នេះដែរ ពាក់ព័ន្ធទៅនឹងការគំរាមកំហែងមកលើលោកស្រី<អំពីការរៀបការ នៅមុននេះបន្តិច>។ ខ្ញុំចង់សួរលោកស្រី ថាតើលោកស្រីធ្លាប់ឮ<ពី>ទីកន្លែងនេះពីមុនៗមកដែរឬទេ <គឺនៅមុនពេលដែលលោកស្រីឮ>ពាក់ព័ន្ធទៅនឹងការគំរាមកំហែង<នេះ>។ តើទីកន្លែងនោះ លោកស្រីធ្លាប់ឮឈ្មោះវាពីមុនមកដែរទេ?

**ឆ៖** យើងកាលនុំងយើងនៅក្មេង យើងនៅកងកុមារ និងកងចល័ត។ កន្លែងនុំង ខ្ញុំអត់ដែលឮទេ ទើបតែពេលដែលថតឃ្លីបវីដេអូហ្នឹង ខ្ញុំបានទៅសួរគាត់ ដែលមនុស្សបាត់ខ្លួនហ្នឹង គឺគេថាវាលខ្វាង ក៏ភូមិវាលហ្នឹង គឺអត់ដឹងទេលោកប្រធាន អត់ដែលឃើញ ទើបតែពេលខ្ញុំទៅសួរហ្នឹង បានឮថាវាលខ្វាង

វាលអីហ្នឹង ចេះតែបាត់ៗទៅហ្នឹង គេថាយកទៅកសាងនៅវាលខ្វាងវាលអីហ្នឹង។ ខ្ញុំក៏មិនបានដឹងក្នុងពេលនោះដែរ លោកប្រធាន ទើបតែចតឃ្លីបវីដេអូនេះ បានដឹងឮសូរគេកសាង មានគេសម្លាប់នៅវាលខ្វាង នៅវាលអីហ្នឹង ទើបឮតាមមេកងអ៊ុំ ហ្នឹងទេចាស។

[១៥:៥៩:៤៥]

**ស៖** ខ្ញុំសូមអានចម្លើយមួយ គឺឯកសារ E3/9832 ជាចម្លើយឆ្លើយជូនសហចៅក្រមស៊ើបអង្កេតដោយអតីតឈ្លបម្នាក់មកពីស្រុកបាកាន នៅត្រង់ចម្លើយលេខ៤៦។ "មន្ទីរអប់រំស្រុកមានទីតាំង<នៅថ្វាង>។ សូមដកស្រង់<ចម្លើយ២៩១៖> "ហើយវាល<ថ្វាង> មានទីតាំងនៅភូមិបាក់ចិញ្ចៀន" បញ្ចប់ការដកស្រង់។ តើចំណុចនេះ វាជួយដល់ការចងចាំអំពីមន្ទីរអប់រំកែប្រែស្រុកដែលខ្ញុំលើកឈ្មោះអម្បាញ់មិញដែរឬទេ លោកស្រីធ្លាប់ឮទេនៅសម័យខ្មែរក្រហម?

**ឆ៖** កាលសម័យខ្មែរក្រហម ខ្ញុំអត់ដែលឮទេ វាលខ្វាង។ ខ្ញុំទើបឮ ដូចខ្ញុំបានបញ្ជាក់ហើយ។ ខ្ញុំអត់ដែលបានដឹងទេ។ គ្រាន់តែថាពួកខ្ញុំធ្វើខុស គេដាក់ឲ្យខ្ញុំរែកដី ១២ម៉ែត្រគូប លោកប្រធាន ដែលទាំងខ្ញុំវ័យក្មេងនោះ ខ្ញុំរែកអត់ដែលហើយទេ ចាស។

**ស៖** ខ្ញុំសូមដកស្រង់មួយ<នៃកំណត់ហេតុស្តាប់ចម្លើយ>ឈ្មោះ <កុល សែត> ដែលជាឈ្លប<ឃុំខ្មែរក្រហម ដែលមកពី>ស្រុកបាកាន <ប្រចាំការ>នៅភូមិបាកាន គាត់រៀបរាប់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់<ជាមួយសហចៅក្រមស៊ើបអង្កេត> គឺ E3/9821 នៅចម្លើយលេខ១១៤ គាត់បានឆ្លើយដូចតទៅ សូមដកស្រង់៖ "គេបញ្ជាឲ្យខ្ញុំឲ្យទៅតាមលបស្តាប់ និងស៊ើបអង្កេតមើលអ្នករៀបការថ្មីៗ ហើយខ្ញុំមករាយការណ៍ជូនពួកគេវិញ។ ពួកគេចង់ដឹងថាអ្នកណានិយាយអំពីអង្គការ ហើយអ្នកណាបដិសេធមិនព្រមរួមដំណេកជាមួយគ្នា ក្រោយការរៀបការរួចមក។" បញ្ចប់ការដកស្រង់ ។ តើលោកស្រីស្គាល់<ស្រុក>ដំណាក់កន្សែង <ដែលឈ្លបនេះនៅដែរ ឬទេ>? សូមទោសម្តងទៀត សូមកែប្រែ គឺឃុំដំណាក់កន្សែង។

**ឆ៖** មានៗដំណាក់កន្សែង គឺមាន លោកប្រធាន។ តែមិនមានឃុំទេ គឺភូមិ ភូមិដំណាក់កន្សែង គឺមានចាស។ ប៉ុនសម័យ សូមទោស ក្រែងសម័យខ្មែរក្រហម គេដាក់ឃុំក៏ខ្ញុំមិនដឹងទេ តែបើសម័យនេះ ខ្ញុំនិយាយសម័យនេះ គឺមិនមានឃុំទេ ចាស។ សម័យរាល់ដងនេះ សព្វថ្ងៃនេះ គឺគេប្រើភូមិដំណាក់កន្សែង ចាស។ បើសម័យខ្មែរក្រហម គេដាក់ភូមិអីៗ គឺខ្ញុំអត់ដឹងទេ ចាស។

[១៦:០៣:០៣]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមើលទៅឃើញដល់ពេលដែលត្រូវឈប់ហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី១៣ ខែតុលា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បញ្ចប់ ហើយថ្ងៃស្អែកនេះ ក៏អង្គជំនុំជម្រះនឹងផ្តើមធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-960 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកស្រី ប៉ែន សុចាន់ សវនាការស្តាប់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោកស្រី ប៉ែន សុចាន់ វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់មកកាន់ -- ផ្តល់សក្ខីកម្មនៅថ្ងៃស្អែក ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*